ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-Jul-2013, 15:51
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី២០០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

កញ្ញា មីរាម ម៉ាហ្វេសាន់ទិ

*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក សេង ប៊ុនឃាង

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក  គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSÉ)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៃ ជុនធី

លោក វ៉ែន ពៅ

កញ្ញា អេលេន័រ ហ្វឺណាន់ដេស

*(Ms. Eleonor FERNANDEZ)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ច័ន្ទ តារារស្មី | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |

 

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមានអវត្តមានភាគីដែលអង្គជំនុំជម្រះបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន។ សូមកត់សម្គាល់ថា ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមសាលសវនាការនេះ តាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមូលហេតុបញ្ហាសុខភាព។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារពាក់ព័ន្ធជាមួយនឹងអង្គសហឧក្រិដ្ឋកម្មរួម។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោកមេធាវី។

នៅពេលដែលយើងឈប់សម្រាកកាលពីម្សិលមិញនេះ ខ្ញុំបានធ្វើបទបង្ហាញដែលបង្ហាញនូវឯកសារមួយដែលបង្ហាញពីគោលនយោបាយដែលផ្ដោតគោលដៅទៅលើមន្ត្រី និងទាហានរបស់របបសាធារណរដ្ឋ លន់ នល់។ ហើយខ្ញុំក៏បានធ្វើបទបង្ហាញអំពីប្រភេទមួយនៃឯកសារដែលបញ្ជាក់អំពីគោលនយោបាយដែលក្នុងនោះគឺមានបញ្ជីអ្នកទោសនៅ ស-២១ គឺនៅរយៈពេលដំបូងនៃមន្ទីរឃុំឃាំងនេះ។ ហើយនៅក្នុងលិខិតនោះបានបង្ហាញថាអ្នកទោសមួយចំនួនធំគឺជាមន្ត្រី និងយោធារបបលន់ នល់។ ហើយខ្ញុំក៏បានបង្ហាញឯកសារមួយដែលបង្ហាញផងដែរ អំពីអ្នកទោស១៦២នាក់ ដែលជាអតីតមន្ត្រី និង

យោធា លន់ នល់ ព្រមទាំងសមាជិករបស់គាត់ ហើយដែលត្រូវបានស្លាប់តែ១ខែប៉ុណ្ណោះ គឺខែមីនា ឆ្នាំ៧៦។ ហើយខ្ញុំសូមបញ្ជាក់ថាវាមានបញ្ជីមួយចំនួនទៀតនៅស-២១ ដែលបានបង្ហាញអំពីការផ្តោតគោលដៅទៅលើក្រុមមន្ត្រី និងទាហាន។ ឯកសារ E3/2189 គឺឯកសារ E3/2189 ជាបញ្ជីឈ្មោះអ្នកទោសដែលមានចំណងជើងថា "បញ្ជីឈ្មោះអ្នកទោសដែលជាមន្ត្រីរដ្ឋបាល"។

[០៩:០៦:០៤]

ឯកសារទាំងអស់នេះគឺមានភាពពាក់ព័ន្ធ។ គឺថាជាបញ្ជីឈ្មោះដែលគេដាក់ឈ្មោះទៅលើបញ្ជីដែលជាការផ្តោតគោលដៅទៅលើអ្នកទោសដែលជាផ្នែករដ្ឋការរបស់របប លន់ នល់។ ហើយខ្ញុំក៏សូមធ្វើការកត់សម្គាល់ផងដែរ វាមានឯកសារដែលទទួលដោយអង្គជំនុំជម្រះផងដែរ គឺE3/3597។ ហើយនេះគឺជាបញ្ជីឈ្មោះអ្នកទោស ស-២១ ដែលគេបានបញ្ជាក់នូវចំនួនអ្នកទោស១៨៨នាក់ ជាបញ្ញវន្ត អតីតទាហាន និងមន្ត្រី លន់ នល់ ដែលត្រូវបានសម្លាប់នៅ ស-២១ នៅក្នុងឆ្នាំ១៩៧៦។

ឥឡូវនេះ ខ្ញុំសូមលើកយកឯកសាររបស់គណៈអចិន្ត្រៃយ៍ គឺឯកសារ E3/197។ E3/197 ដែលជាកំណត់ត្រានៃការប្រជុំរបស់គណៈអចិន្ត្រៃយ៍ដែលធ្វើនៅថ្ងៃទី១១ ខែមីនា ឆ្នាំ៧៦ ពាក់ព័ន្ធទៅនឹងការលាលែងរបស់សម្តេច សីហនុ។ កិច្ចប្រជុំហ្នឹងចូលរួមដោយ ប៉ុល ពត, នួន ជា, ខៀវ សំផន, សុន សេន, វន វេត ហើយនិង ខឿន។

នៅផ្នែក -- នៅចំណុចដំបូងនៃផ្នែកទី២នៃកំណត់ហេតុនៃការប្រជុំនេះ ដូចដែលពីម្សិលមិញ គឺថាសហការីរបស់ខ្ញុំបានបង្ហាញរួចហើយនៅក្នុងការបទបង្ហាញនេះ។ ខ្ញុំសូមអនុញ្ញាតនូវផ្នែកដំបូងនៃផ្នែកទី២ គឺថាមានទស្សនៈដូចតទៅរបស់អង្គការដែលនិយាយអំពីមូលហេតុវែងឆ្ងាយ គឺទាក់ទងទៅនឹងមូលហេតុដែលនាំឲ្យ សីហនុ លាលែង។

[០៩:០៨:០១]

ខ្ញុំសូមធ្វើការដកស្រង់៖ "គឺទំនាស់ជាមូលដ្ឋានរវាងបដិវត្តន៍ និងគាត់ ព្រមទាំងគ្រួសារគាត់។ គាត់រស់នៅជាមួយយើងមិនបាន កន្លងមក គាត់រស់នៅបាន ជាយុទ្ធវិធីទេ"។ សូមបញ្ចប់ការដកស្រង់។ ហើយនៅក្នុងឯកសារដដែលនេះ គឺនៅពេលដែលកិច្ចប្រជុំបន្តថែមទៀត នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ៧៦ កំណត់ត្រានៃការប្រជុំបានបញ្ជាក់អំពីអ្វីដែលគេបានសម្រេចថាឲ្យអនុញ្ញាតឲ្យសម្តេច សីហនុ រស់នៅ ប៉ុន្តែមិនអនុញ្ញាតឲ្យគាត់ចាកចេញពីប្រទេសកម្ពុជា។

ពាក់ព័ន្ធទៅនឹងបុត្ររបស់សម្តេច សីហនុ កិច្ចប្រជុំហ្នឹងបានសរសេរដូចតទៅនេះ -- នៅក្នុង

កថាខណ្ឌទី៣ ដែលខ្មែរមានលេខ 00000747, ភាសាអង់គ្លេសមានលេខ 00182641, ហើយបារាំងមានលេខ 00334963។ កំណត់ត្រាបានបញ្ជាក់ដូចតទៅនេះ៖ "វាយខ្សែល្អសឲ្យកូនគាត់មកភ្លាម ដោយបញ្ជាក់ថាឲ្យមករួមចូលឆ្នាំ និងបុណ្យឯករាជ្យ។ យើងចង់ដោះស្រាយបញ្ហានេះឲ្យស្អាត"។ សូមបញ្ចប់ការដកស្រង់។

ហើយពីរបីកថាខណ្ឌចុះទៅក្រោមទៀត នៅកថាខណ្ឌលេខ៥ គឺគណៈអចិន្ត្រៃយ៍បានបញ្ជាក់នូវសេចក្តីសម្រេចចិត្តដូចតទៅនេះ គឺសេចក្តីសម្រេចចិត្តពាក់ព័ន្ធទៅនឹងសម្តេច សីហនុ។ ខ្ញុំសូមធ្វើការដកស្រង់៖ "យើងត្រូវបញ្ចប់សក្តិភូមិយ៉ាងដូច្នេះ។ ក្រឡាអុកវាចេញមកដល់ត្រង់ហ្នឹងហើយ របបសក្តិភូមិទាំងមូលត្រូវបដិវត្តន៍កម្ទេច និងគាស់រំលើងជាស្ថាពរ។ ស្តេចដែលមានមក២០០០ឆ្នាំហើយ ទីបំផុតត្រូវស្អាត។ យើងគ្មានផ្លូវអីចេញក្រៅពីនេះទេ"។

[០៩:១០:២០]

ឯកសារបន្តដែលខ្ញុំនឹងធ្វើការបង្ហាញនៅពេលនេះ គឺជាឯកសារដែលមកពីខាងទាហាន គឺឯកសារដែលមានលេខ E3/1162៧ ដែលជារបាយការណ៍ពីលេខាកងពល៣១០ គឺឈ្មោះ អឿន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៦។ ឯកសារនេះបានបង្ហាញអំពីប្រវត្តិរបស់កម្មាភិបាលកងពល ដែលត្រូវបានគេត្រួតពិនិត្យមើល ហើយនិងបង្ហាញពីការកំណត់កម្មាភិបាលដែលមានសាច់ញាតិជាទាហាននៅក្នុងរបបចាស់ដែលគេត្រូវបានរាយការណ៍ទៅខាងមជ្ឈិម។

ប្រសិនបើយើងមើលនៅកថាខណ្ឌទី៧ ខ្ញុំសូមធ្វើការដកស្រង់ -- នេះគឺជាកថាខណ្ឌ៧នៃរបាយការណ៍របស់កងពល៖ "នៅក្នុងកងពិសេស២១២ នៅមានកម្មាភិបាលបីរូបដែលនៅលាក់ប្រវត្តិរូប មិនបានប្រាប់ការពិតអំពីប្រវត្តិរូបរបស់ពួកគេ។ ទី១ឈ្មោះ ហៀក គាត់ដាក់និន្នាការនយោបាយគ្មានអ្វីទេ ដល់តាមដានដល់ផ្ទះឃើញឪពុកធ្វើទាហានកងឆ្មក់នៅកំពង់ធំ។ ខ) ឈ្មោះ ចាន់ មានបងធ្វើទាហាន១ឆ្នាំ។ គ) គឺឈ្មោះ ស៊ី ឪពុកធ្វើទាហាន ហើយបានបាត់ខ្លួនដល់ឥឡូវ"។

[០៩:១២:២៨]

ឯកសារ E3/813 គឺជាកំណត់ហេតុនៃការប្រជុំជាមួយនឹងកងពល១៦៤ ដែលធ្វើឡើងនៅថ្ងៃទី០៩ ខែ៩ ឆ្នាំ៧៦។ គឺឯកសារដែលមានលេខ E3/813 ខ្ញុំសូមធ្វើការអាននូវសម្រង់នៅត្រង់ផ្នែកទី៣.២នៃកំណត់ហេតុនៃការប្រជុំនេះ ដែលកំណត់ហេតុនៃការប្រជុំនេះរៀបរាប់ដូចតទៅនេះ គឺទាក់ទងទៅនឹងស្ថានភាពខ្មាំងនៅក្នុងតំបន់របស់ខ្លួន។ ខ្ញុំសូមធ្វើការដកស្រង់ "ភាគច្រើនប្រជាជនស៊ីវិលគឺល្អ ប៉ុន្តែមាន

ចលនាអាក្រក់នៅក្នុងទាហាន។ ក្នុងពេលថ្មីៗនេះគឺមានអតីតទាហាននៃរបបចាស់ត្រូវបានគេរកឃើញ ហើយចាប់ខ្លួន"។ ជាការឆ្លើយតបនៅចុងបញ្ចប់កំណត់ហេតុការប្រជុំ សុន សេន បានណែនាំដូចតទៅនេះ គឺថាត្រូវតែកម្ទេច ត្រូវតែកម្ចាត់ទាហាន សមាសភាពទាហាននេះ។

[០៩:១៣:៣៨]

ឯកសារបន្ត គឺឯកសារដែលមានលេខ E3/807ៗ ដែលជាកំណត់ហេតុនៃការប្រជុំរបស់លេខា និងអនុលេខារបស់កងពល ដែលធ្វើឡើងនៅថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៧។ ឥឡូវនេះខ្ញុំសូមធ្វើការអានន្ទូវសម្រង់ដ៏ខ្លីមួយដែលដកចេញពីការប្រជុំនេះ ដែលមានលេខជាភាសាខ្មែរ 00052305, ភាសាអង់គ្លេសមានលេខ 00183949, ភាសាបារាំងមានលេខ 00323923។ ហើយនៅក្នុងកំណត់ហេតុនៃការប្រជុំនេះ គឺលេខា ឈិន ប្រធានកងពល៩២២ បានរាយការណ៍ដូចតទៅនេះ ខ្ញុំសូមធ្វើការដកស្រង់ "បន្ទាប់ពីបានរៀនសូត្រ បានសម្រិតសម្រាំងពួតចេញពីវៀតណាម កូនរបស់ទាហាន មេឃុំ ឬប៉ូលិសឲ្យបង្កបង្កើនផលមួយដុំ"។ សូមបញ្ចប់ការដកស្រង់។

ឯកសារបន្តគឺពាក់ព័ន្ធទៅនឹងការផ្តោតគោលដៅទៅលើទាហាន លន់ នល់ និងមន្ត្រី លន់ នល់ នៅក្នុងតំបន់ ក៏ដូចជានៅក្នុងភូមិភាគស្វយ័ត។ ខ្ញុំសូមលើកឡើងនូវឯកសារមួយចំនួនពីស្រុកត្រាំកក់ គឺនៅក្នុងភូមិភាគនិរតី។

ឯកសារបន្តទៀតគឺ E3/2438។ ឯកសារ E3/2438 គឺជារបាយការណ៍ដែលមានចំណងជើងថាបញ្ជីឈ្មោះប្រជាជនខ្មែរកម្ពុជាក្រោមមកពីគូស មកពីឃុំគូស ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ៧៧។ ហើយសារៈសំខាន់នៃឯកសារនេះ ដែលខ្ញុំលើកយកមកបង្ហាញនៅពេលនេះ គឺថាមានបញ្ជីដែលរៀបរាប់ពីប្រវត្តិរូបរបស់មនុស្សដែលមកពីឃុំគូសនេះ។ ហើយនៅក្នុងកូឡោនមួយហ្នឹង គឺថាមានចំណងជើងដែរគេដាក់ថា "តួនាទី មុខងារ" គឺនៅខាងស្តាំ។ ទី២ បន្ទាប់ពីខាងស្តាំ។ ហើយនៅក្នុងកូឡោនហ្នឹង គឺគេបញ្ជាក់ថាតើមនុស្សទាំងអស់ហ្នឹងគាត់មានតួនាទីអ្វីនៅក្នុងរបបខ្មែរសាធារណរដ្ឋ។

[០៩:១៦:៣៣]

ខ្ញុំលើកជាឧទាហរណ៍មួយ។ បុគ្គលទី១ គឺថា ដែលគេកត់ត្រាថាប្តីស័ក្តិ១ គឺថាគាត់ហ្នឹងមានប្តីស័ក្តិ១។ ហើយបន្ទាប់មកគឺថា កូឡោនទី២ គឺថាប្តីស័ក្តិ២។ ខ្ញុំគិតថាបញ្ជីទាំងអស់នេះ គឺថាវាមានធ្វើផងដែរពីឃុំដទៃទៀតនៅក្នុងស្រុកត្រាំកក់ ដែលវាជាការអនុវត្តជារួមគ្នា។ ហើយខ្ញុំសូមធ្វើការដកស្រង់នូវបញ្ជីពីរបន្តទៅទៀត។

គឺឯកសារដែលមានលេខ E3/2049 គឺជាបញ្ជីដដែល ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាគឺនៅក្នុងឃុំសំ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ៧៧។

ហើយឧទាហរណ៍មួយទៀតគឺ E3/2281។ E3/2281 គឺជាបញ្ជីមកពីឃុំត្រពាំងធំ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ៧៧។ ហើយបន្ថែមពីលើបញ្ជីទាំងអស់នេះទៀត នៅមានឯកសារមួយចំនួនទៀតដែលជារបាយការណ៍នៅក្នុងស្រុកត្រាំកក់ ដែលឯកសារទាំងអស់នេះបានឆ្លុះបញ្ចាំងអំពីអ្វីដែលបានកើតឡើងចំពោះអតីតទាហាន លន់ នល់ នៅពេលដែលគេរកឃើញ។

[០៩:១៨:០៧]

ឯកសារដែលមានលេខ E3/2048។ E3/2048 គឺជារបាយការណ៍ដែលរៀបចំ ដែលមានឯកសារជាច្រើនរបស់ថ្នាក់ស្រុក។ ហើយខ្ញុំនឹងលើកបង្ហាញនូវឯកសារចំនួនបី គឺបង្ហាញពីរបាយការណ៍ចំនួន៣។ ទី១គឺមានលេខភាសាខ្មែរ 00079089, ភាសាអង់គ្លេសមានលេខ 00276562 ដល់ 63, និងភាសាបារាំងមានលេខ 00611659។ ហើយនៅត្រង់ទំព័រនេះ គឺថាយើងឃើញថាវាជាសេចក្ដីរាយ-ការណ៍មកពីស្រុកជើងធំ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ៩៧ *(ស៊ីក)*។ ស្នើសុំៗធ្វើរបាយការណ៍ជូនអង្គការស្រុកត្រាំកក់ជាទីគោរពស្នេហា។ សកម្មភាពខ្មាំងនៅក្នុងមូលដ្ឋានយើងខ្ញុំ ក្រោយពីបានការណែនាំជាបន្តបន្ទាប់ពីអង្គការក្នុងការប្រុងប្រយ័ត្នខ្មាំង និងបោសសម្អាតពួកទាហានខ្មាំងដែលមានបណ្ដាស័ក្តិ ក្នុងនោះបានតាមដានពិនិត្យឃើញមានឈ្មោះដូចខាងក្រោម៖

"ទី១ ឈ្មោះ ឈិត ប៊ុល ជាទាហានពាក់ស័ក្តិ១ ចេញពីភ្នំពេញមុនឆ្នាំ៧០ នៅអង្គតាសោម។ បុគ្គលទី២ ឈ្មោះ ខៀវ សុខា ហើយរបាយការណ៍បានរាយការណ៍ថា យើងសាកសួរវា វាឆ្លើយអំពីតួនាទីរបស់វា។ វាឆ្លើយថាវារកស៊ីលក់បាយ។ តែដល់ថ្ងៃនេះបានតាមដានជាក់ស្ដែងទៅ ឈ្មោះនេះធ្វើការងារខាងក្រសួងអភិវឌ្ឍសហគមន៍"។ ហើយរបាយការណ៍បានបញ្ចប់ដោយបញ្ជាក់ដូចតទៅនេះ "សេចក្ដីរាយការណ៍ដូចខាងលើនេះសូមអង្គការជ្រាប ព្រមជាមួយនេះយើងខ្ញុំសូមបញ្ជូនឈ្មោះទាំងពីរនេះទៅនគរបាលជាមួយដែរ សូមអង្គការទទួលផងចុះ"។

[០៩:២០:៤៦]

ហើយនៅក្នុងឯកសារ E3/2048 ដដែលនេះគឺនៅត្រង់ខ្មែរមានលេខ 00079090, ភាសាអង់គ្លេសមានលេខ 00276563 ដល់ 64 និងភាសាបារាំងមានលេខ 00611660។ ហើយនៅត្រង់ឯកសារដែលមានលេខ ERN បែបនេះគឺជាសេចក្ដីរាយការណ៍អំពីឃុំពពេល ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ

១៩៧៧។ “ឯកសារនេះបានជម្រាបទៅដល់គណៈកម្មការស្រុកដែលថាមានគ្រួសារទាហាន១៦៦នាក់ដែលជាសរុប គឺមានប្រជាជន៣៩៣នាក់ត្រូវបានកម្ទេចដោយអង្គការ។ ហើយគ្រួសារទាហាន២៣១នាក់នៅសល់ទៀត ដែលក្នុងចំណោមនោះគឺមានមនុស្សចំនួន៨៩២នាក់ ហើយនៅមានគ្រួសារបន្ថែមទៀតដែលមិនទាន់ត្រូវបានសម្រេចថាតើពួកគេហ្នឹងជាគ្រួសារទាហាន ឬក៏មិនមែន”។ សូមបញ្ចប់ការដកស្រង់។

ហើយនៅក្នុងរបាយការណ៍ដដែលនេះនៅត្រង់ខ្មែរមានលេខ 00079091, អង់គ្លេសមានលេខ 00276564, ភាសាបារាំងមានលេខ 00611661។ គឺជាឯកសារមួយដែលផ្ញើចេញពីប្រធានឃុំតាភេមចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៧៧ ដែលឯកសារហ្នឹងបានសរសេរដូចតទៅនេះ៖ “យើងខ្ញុំក្នុងសាខាមូលដ្ឋានសហករណ៍ឃុំតាភេម បានពិនិត្យនិងបោសសម្អាតខ្មាំងដែលមានបណ្ដាស័ក្តិ។ ក្រោយពីបានទទួលនូវមតិណែនាំរបស់បក្សចុះពិនិត្យជិតដល់ យើងឃើញថា នៅមានអ្នកបណ្ដាស័ក្តិប្រាំមួយនាក់ទៀត។ ហើយឈ្មោះនេះធ្វើសកម្មភាពផ្ទាល់របស់ខ្លួនជារៀងរាល់ខែ។ ឈ្មោះទាំងប្រាំមួយនាក់មានដូចខាងក្រោមនេះ...”។ ហើយបន្ទាប់មក គឺគេរាយនឹងបញ្ជីឈ្មោះប្រាំមួយនាក់ដែលមានឋានន្តរសក្តិជាអនុសេនីយ៍ត្រី ឬក៏អនុសេនីយ៍ទោ។ “...ហើយឈ្មោះទាំងអស់នេះគឺសូមធ្វើការរាយការណ៍ជូនអង្គការជ្រាប។ អង្គការសម្រេចយ៉ាងណាស្នើមតិណែនាំ”។ សូមបញ្ចប់ការដកស្រង់។

[០៩:២៣:៤៤]

ឯកសារបន្តទៀតនេះគឺឯកសារដែលមានលេខ D157.38។ D157.38 គឺជាឯកសារមួយទៀតដែលជាឯកសាររបស់ស្រុកត្រាំកក់ ហើយចំណុចដែលពាក់ព័ន្ធគឺខ្មែរមានលេខ 00143476, ភាសាអង់គ្លេសមានលេខ 00322133, ភាសាបារាំងមានលេខ 00612838។ ហើយនេះគឺជាសំណើសុំមតិណែនាំដែលស្នើឡើង “ដោយឃុំពពេល ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ គឺផ្ញើជូនបងគណៈស្រុកជាទីគោរព។ សម្រាប់មនុស្សទាំងអស់នេះដែលមានឋានៈដូចខាងក្រោម យើងនឹងបញ្ជូនពួកគេទៅជូនបងជាបន្តបន្ទាប់។ ចំពោះទាហាននិងគ្រូដែលព្យាយាមចង់បំផ្លាញបដិវត្តន៍របស់យើង សូមបងជួយផ្ដល់មតិយោបល់ថាតើយើងត្រូវធ្វើយ៉ាងណា? ឬមួយក៏អនុញ្ញាតឲ្យយើងធ្វើការសម្រេចដោយផ្អែកទៅលើមូលដ្ឋាន?” ហើយលិខិតនេះបានចុះហត្ថលេខា ដោយមានការតាំងចិត្តយ៉ាងម៉ឺងម៉ាត់ដើម្បីកម្ទេចពួកខ្មាំងទាំងអស់នេះដើម្បីជាប្រយោជន៍ដល់បដិវត្តន៍ ជូនបក្ស និងធ្វើជូនប្រជាជនផងដែរ។

[០៩:២៥:៤៥]

លោក លោកស្រី ចៅក្រមគឺថាខ្ញុំបានបង្ហាញនូវឯកសារមួយចំនួនមកពីស្រុកត្រាំកក់។ ឥឡូវនេះ ខ្ញុំសូមធ្វើការអាននូវសម្រង់ដ៏សង្ខេបមួយទៀតពីការសម្ភាសរបស់អតីតមន្ត្រីនៅក្នុងស្រុកត្រាំកក់។ ខ្ញុំសូមមិនបញ្ជាក់ឈ្មោះរបស់គាត់ទេ។ ឯកសារនោះគឺមានលេខ E125/128 -- D125/128 ដែលធ្វើឡើងនៅខែតុលា ឆ្នាំ២០០៧។ គឺជាប្រធានយុវជននៅក្នុងស្រុកត្រាំកក់។ ខ្ញុំសូមធ្វើការអាន ខ្មែរមានលេខ 00163493, ភាសាអង់គ្លេស មានលេខ 00223476, ភាសាបារាំងគឺមានលេខ 00651259។ "សំណួរ៖ តើអ្នកទោសហ្នឹងមកពីខាងណាដែរ? ហេតុអ្វីបានជាគេឃុំនៅទីនោះ? គឺគេចង់និយាយទៅលើមន្ទីរក្រាំងតាចាន់នៅក្នុងស្រុកត្រាំកក់។ ភាគច្រើននៃបងប្អូនទាំងអស់នេះត្រូវបានគេជម្លៀសចេញ ពីទីក្រុងដែលគេហៅថាជាប្រជាជន១៧ មេសា។ គឺវាមានការច្របល់ចូលគ្នារវាងអតីតទាហាននិងប្រជាជនមូលដ្ឋាន។ សំណួរ៖ តើអ្នកណាជាអ្នកបង្គាប់ឲ្យឃុំខ្លួនប្រជាជន ១៧ មេសា ដែលបញ្ជូនទៅទីនោះ? ចម្លើយ៖ តាមអ្វីដែលខ្ញុំដឹងជាទូទៅការសម្លាប់ត្រូវធ្វើឡើងភ្លាមបន្ទាប់ពីថ្ងៃ១៧ មេសា។ ហើយពួកទាហានគឺជាអ្នកសម្លាប់មុនពេលដែលចូលមកដល់ទីក្រុងភ្នំពេញ។ សំណួរ៖ តើក្រុមប្រជាជន ១៧ មេសា ដែលត្រូវបានពួកឈ្លបចាប់ហើយបញ្ជូនមកមន្ទីរក្រាំងតាចាន់ហ្នឹងជាអ្នកណា? ចម្លើយ៖ ខ្ញុំមិនដឹងថាកម្រិតណាជាអ្នកសម្រេចផែនការនោះទេ។ នៅពេលដែលពួកគេមកដល់ពួកគេឲ្យប្រជាជនធ្វើប្រវត្តិរូប ហើយអ្នកណាដែល -- ប្រវត្តិរូបសរសេរថាខ្លួនជាទាហាន គឺត្រូវបាត់ខ្លួន"។ សូមបញ្ចប់ការដកស្រង់។

[០៩:២៨:២៨]

លោក លោកស្រីចៅក្រម! ឥឡូវនេះខ្ញុំសូមបង្ហាញនូវទស្សនាវដ្តីទង់បដិវត្តន៍ខែមិថុនាឆ្នាំ១៩៧៧ គឺឯកសារដែលមានលេខ E3/135 ។។ ហើយផ្នែកទី១ នៃទស្សនាវដ្តីទង់បដិវត្តន៍លេខមួយនេះគឺថាបង្ហាញដូចតទៅនេះ៖ វាជាការប្រកាសដែលថាគណៈមជ្ឈិមរបស់បក្សបានសម្រេចថា ស្រុកណាដែលមានសមត្ថភាពល្អបំផុតក្នុងការការពារប្រទេស ហើយនិងបន្តនូវនយោបាយសង្គមនិយមព្រមទាំងកសាងសង្គមនិយមត្រូវទទួលនូវទង់ក្រហមកិត្តិយស។ ហើយបន្តមកទៀតគឺពីរកថាខណ្ឌនៅខាងក្រោមនៅក្នុងរយៈពេលនៅក្នុងឆ្នាំ៧៦ ហ្នឹងគឺបក្សបានធ្វើការវាយតម្លៃហើយឃើញថា ស្រុកបីមានគុណសម្បត្តិជាគំរូទាក់ទងទៅនឹងការពារប្រទេស ក៏ដូចជាការធ្វើបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយម។ ស្រុកទាំងបីហ្នឹងគឺមាន ទី១ គឺស្រុកប្រាសាទ នៅក្នុងភូមិភាគបូព៌ា។ ទី២ គឺកំពង់ត្រឡាចលើ នៅក្នុងភូមិភាគបូព៌ា ដែលគេហៅជាស្រុក១២។ ហើយនិងទី៣ គឺស្រុកត្រាំកក់ នៅក្នុងភូមិភាគនិរតី។ ហើយស្រុកទាំងបី

ហ្នឹង គឺត្រូវទទួលទង់បដិវត្ត -- គឺទង់ក្រហមកិត្តិយស”។

[០៩:៣០:២៥]

នៅត្រង់ឯកសារដែលមានលេខ ជាភាសាខ្មែរគឺមានលេខ 00062795, ភាសាអង់គ្លេសមានលេខ 00446850, និងភាសាបារាំង 00487712។ ទស្សនាវដ្ដីទង់បដិវត្តបានបញ្ជាក់ថា ស្រុកទាំងនេះត្រូវបានគេលើកកិត្តិយសជាគំរូសម្រាប់អ្នកដទៃនៅក្នុងប្រទេស សម្រាប់ឲ្យអ្នកដទៃធ្វើ។ ហើយនៅត្រង់កថាខណ្ឌទី៣ ខ្ញុំសូមធ្វើការដកស្រង់៖ “ដោយជួយទៅដល់ការតស៊ូវណ្ណៈដ៏រឹងមាំ និងខ្លាំងក្លានៅក្នុងស្រុកទាំងមូល ក៏ជួយទៅដល់បក្សទាំងមូលតែម្ដង”។

ឥឡូវនេះ ខ្ញុំបានបង្ហាញឯកសារក៏ដូចជាចម្លើយរបស់សាក្សីនៅក្នុងស្រុកមួយដែលស្រុកទាំងអស់ហ្នឹងគេចាត់ទុកថាជាស្រុកគំរូ។ ហើយបន្តទៅនេះ ខ្ញុំសូមធ្វើការអាននូវកំណត់ហេតុស្ដាប់ចម្លើយសាក្សីរបស់ដទៃទៀត ដែលជាមនុស្សនៅក្នុងស្រុកដែលគេចាត់ទុកថាជាស្រុកគំរូ ដូចជានៅក្នុងស្រុកកំពង់ត្រឡាចលើ នៅភូមិភាគបូព៌ាជាដើម។

ឥឡូវនេះ ជាដំបូងខ្ញុំសូមអាននូវឯកសារដែលមានលេខ E232/44 -- D232/44 គឺជាកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលធ្វើនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩។ ហើយត្រូវធ្វើការសម្ភាសអនុឈ្លបនៅក្នុងស្រុកកំពង់ត្រឡាចលើ ឃុំក្រាំងល្វា។ ខ្ញុំសូមធ្វើការដកស្រង់នូវសំណួរចម្លើយទី៥ នៃការសម្ភាសនេះ៖

“សំណួរ៖ តើប្រជាជនជម្លៀសមកពីភ្នំពេញពេលនោះមានយកទៅសម្លាប់ដែរឬទេ? សូមលោកបញ្ជាក់អំពីព្រឹត្តិការណ៍នៅពេលនោះយ៉ាងណាខ្លះ? ឆ្លើយ៖ តាមខ្ញុំដឹងប្រជាជនជម្លៀសទាំងនោះ មានយកទៅសម្លាប់។ ពេលនោះ គេប្រមូលប្រជាជនទាំងនោះទៅប្រជុំភូមិជំទាវជ្រែង ក្នុងឃុំក្រាំងល្វានេះ។ ការប្រជុំមានច្រើនលើក ពេលដែលប្រជាជនមកដល់ម្ដងៗ ពេលខ្លះប្រជុំនៅកន្លែងសហករណ៍។ អ្នកដែលដឹកនាំប្រជុំតាមខ្ញុំចាំ គឺ តាយឹម, តាវង់ និង តាសារុន។ ពេលប្រជុំ ពួកគាត់ណែនាំឲ្យប្រជាជនថ្មីខិតខំធ្វើការក្នុងសហករណ៍។ ហើយមានសួរឈ្មោះម្នាក់ៗដែលមានអ្នកកត់ត្រា។ តើអ្វីនៅភ្នំពេញ? ហើយធ្លាប់ធ្វើទាហានដែរឬទេ? ចំពោះអ្នកធ្លាប់ធ្វើជាទាហាន លន់ នល់ ក្រោយមកត្រូវបានបាត់ខ្លួនអស់ពីក្នុងសហករណ៍។ ចំណែកអ្នកមិនធ្លាប់ធ្វើទាហានមាននៅរស់ខ្លះ”។

[០៩:៣៤:០៥]

ឯកសារបន្ទាប់ គឺឯកសារលេខ D125/91។ ឯកសារនេះ គឺជាកំណត់ហេតុស្ដាប់ចម្លើយដែល

ធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៨។ អ្នកដែលត្រូវបានស្តាប់ចម្លើយនេះគឺជាទាហាននៅស្រុក១២នៅដើមរបបនោះ ហើយក្រោយមកត្រូវបានគេឃុំ ហើយក្លាយទៅជាអ្នកទោស។ ខ្ញុំនឹងអាននូវចំណុចដកស្រង់ចេញពីមកកំណត់ហេតុនេះ ដំបូងនៅត្រង់ខ្មែរលេខ 00212109, អង់គ្លេស 00275111, បារាំង 00342628។

"សំណួរ៖ តើលោកអាចបញ្ជាក់ទេ ពាក្យថាអ្នកទោសនេះមានន័យយ៉ាងម៉េច? ឆ្លើយ៖ អ្នកទោសគឺជាអ្នកដែលគេចោទថាជាខ្មាំង ដូចជាប្រជាជន១៧មេសា ដែលជាប្រជាជនទើបជម្លៀសមកពីភ្នំពេញចូលមកស្រុក១២ និងប្រជាជនមូលដ្ឋានជាដើម។ អ្នកធ្វើខុសគេចោទថាជាខ្មាំង ដូចជាកំហុសខូចសីលធម៌ ដែលជាការប៉ះពាល់ផ្លូវភេទ ស្នូងច្រឡំពូជ លួចដំឡូង អ្នកដែលគេចោទថាជាទាហាន លន់ នល់ ក៏ជាខ្មាំង សេ.អ៊ី.អា...។ល។ ក៏ជាខ្មាំងដែរ"។

[០៩:៣៦:០៦]

ហើយមានសំណួរមួយចំនួនទៀត ក្រោយមកបានសួរដូចតទៅ៖ "តើលោកបានសួរចម្លើយពួកគេប៉ុន្មានដង? ហើយឮប៉ុន្មានដង? ខ្ញុំឮគេសួរចម្លើយច្រើនដង។ ថាតើអ្នកឯងជាទាហាន លន់ នល់ ឬក៏មិនមែន? តើមានជាប់ខ្សែ សេ.អ៊ី.អា ឬក៏អត់? បើអ្នកទោសឆ្លើយថាមិនមែនគឺ អែម ជាអ្នកវាយអ្នកទោស"។

បន្ទាប់មកមានសំណួរចំនួនពីរទៀតបានសួរដូចតទៅ៖ "សំណួរ៖ តើសាកសពដែលស្លាប់ដោយមូលហេតុអ្វីខ្លះត្រូវបានគេកប់ក្នុងរណ្តៅទាំងនោះ? ឆ្លើយ៖ មានអ្នកស្លាប់ដោយសារជំងឺ ដូចជាខ្វះថ្នាំសង្កូវ ហូបមិនគ្រប់គ្រាន់។ ក្នុងឆ្នាំ៧៥ ខ្ញុំបានឃើញគេបណ្តើរមនុស្សរាប់រយនាក់យកទៅសម្លាប់ចោលនៅភ្នំគ្រេច ស្ថិតក្នុងភូមិក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ដោយគ្មានការសួរចម្លើយទេ។ អ្នកទាំងនោះគឺប្រជាជន១៧មេសា និងជាទាហាន លន់ នល់។ ខ្ញុំមិនដឹងថាគេយកទៅកន្លែងណានោះទេ ខ្ញុំចូលរួមបណ្តើរមនុស្សទាំងនេះយកទៅវៃចោលនៅភ្នំគ្រេចនេះ ដែលមានទាហានមួយកងប្រហែល៣០នាក់ ជាទាហានស្រុក១២ មានឈ្មោះ សួន ជាមេគេ"។

[០៩:៣៧:៤៤]

លោក លោកស្រីចៅក្រមជាទីគោរព ខ្ញុំឈប់អានចេញពីកំណត់ហេតុស្តាប់ចម្លើយនេះហើយមានចម្លើយហ្នឹងច្រើនណាស់ ដែលយើងខ្ញុំបានកំណត់អត្តសញ្ញាណឯកសារទាំងអស់នេះនៅក្នុងសំណុំឯកសាររបស់យើង បង្ហាញអំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ ហើយខ្ញុំនឹងបន្តទៅដល់

ឯកសារផ្សេងទៀត ដែលពាក់ព័ន្ធនឹងការកំណត់គោលដៅខ្មាំង។

[០៩:៣៨:០៦]

ឯកសារបន្ទាប់ដែលខ្ញុំសូមបង្ហាញ គឺឯកសារ E3/193 គឺទស្សនាវដ្ដីទង់បដិវត្ត ខែសីហា ឆ្នាំ ១៩៧៧ បានចុះផ្សាយសេចក្តីថ្លែងរបស់អ្នកតំណាងអង្គការបក្ស នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧០។ ជាពិសេសនៅក្នុងសន្និបាតកម្មាភិបាលភូមិភាគបស្ចិម។ នៅចាប់ផ្តើមបទសេចក្តីថ្លែងនោះ គឺគេលើកឡើងថា៖ “ខ្ញុំសូមធ្វើការបង្ហាញពាក់ព័ន្ធទៅនឹងការណែនាំរបស់បក្ស លើការបញ្ហាសំខាន់ៗមួយចំនួននៅក្នុងការអនុវត្តក្នុងឆមាសទី២ ឆ្នាំ១៩៧៧។

ផ្នែកជាក់លាក់ដែលខ្ញុំសូមឲ្យអង្គជំនុំជម្រះពិចារណាពិនិត្យមើល គឺខ្មែរមានលេខ 00062960, អង់គ្លេស 00399232 និងបារាំងមានលេខ 00611826។ នេះគឺជាចំណុចជាក់លាក់នៅក្នុងសុន្ទរកថានេះ ដែលតំណាងអង្គការបក្សបានរម្លឹរទាំថា “សហករណ៍នៅភូមិភាគបស្ចិមត្រូវបានគ្រប់គ្រងដោយទាហានសាធារណរដ្ឋខ្មែរពីមុន។ នៅស្រុក១៨ មិនមែនមានចំនួនតិចនោះទេ។ អ្វីដែលខ្ញុំដឹងសហករណ៍ខ្លះមានអតីតទាហាន មិនមែនជាសមាជិក ជាទាហានទទួលខុសត្រូវ សមាសភាពក្រោយរំដោះទូទាំងប្រទេស គឺមិនមែនតិចទទួលខុសត្រូវដឹកនាំក្នុងសហករណ៍ កំពង់លែងក៏មិនមែនតិចដែរ។ ពញាឮក៏មិនមែនជាខុសគ្នាប៉ុន្មានទេ។ បរិបូណ៍ខាងក្រោម រលាំង្អៀរខាងក្រោមក៏ត្រូវពិនិត្យដែរ។ តំបន់៣៧ សំបូរជាងទៅទៀត។

[០៩:៤០:១៥]

នៅផ្នែកខាងក្រោយៗ កម្មាភិបាលត្រូវបានគេណែនាំឲ្យធ្វើការវាយកម្ទេចខ្មាំង និងសមាសភាពមិនល្អដែលបង្កប់នៅក្នុងសហករណ៍។

នៅចំណុចចុងក្រោយនៃឯកសារនេះ គឺគេលើកឡើងថា “នៅចុងឆ្នាំ៧៧ មានប្រហែលជា៥០ភាគរយត្រូវបានគេគិតថាជាសមាសភាពល្អ យោងតាមមាគ៌ាបក្ស”។

ឯកសារបន្ទាប់គឺបង្ហាញពីការកំណត់ការគោលដៅទាហាន មន្ត្រីរដ្ឋការ លន់ នល់ នៅភូមិភាគកណ្តាល។ ហើយនេះគឺជាឯកសារចុះខែមេសា ឆ្នាំ៧៦។ ឯកសារលេខ E3/952។ ឯកសារនេះគឺជាសារទូរលេខមកពីលេខាភូមិភាគកណ្តាល កែ ពក ផ្ញើជូនបង ប៉ុល។ ចម្លងជូន នួន ជា និង សុន សេន។

ផ្នែកទី១មានចំណងជើងថា “សភាពការណ៍ខ្មាំងនៅភូមិភាគឧត្តរទាំងមូល”។ ហើយខ្ញុំនឹងអានចំណុចនេះ។ សូមដកស្រង់ “ជារួមមកសភាពការណ៍នៅមានសភាពហ្នឹងនរ ក៏ប៉ុន្តែពួកគេបានធ្វើសកម្ម

ភាពខ្លះ។ ឧទាហរណ៍ ពួកគេធ្វើការឃោសនាថា បដិវត្តន៍នេះរឹងប៊ឹងណាស់ ហើយពួកគេធ្វើឃោសនាការប្រឆាំងនឹងសហករណ៍ធ្វើស្រូវ។ ពួកគេធ្វើការឃោសនាអំពីការអត់ឃ្លាន ជាពិសេសសកម្មភាពមួយចំនួនបង្ហាញថាកើតឡើងនៅចម្ការលើ ស្រុកចម្ការលើ។ ពួកអាខ្មាំងជាទាហានចាស់ រួមផ្សំជាមួយពួកចាម និងពួករបស់អាឈឹង"។

[០៩:៤២:៣២]

បន្តទៅកថាខណ្ឌមួយទៀតលើកឡើងថា៖ "ពាក់ព័ន្ធនឹងសភាពខ្មាំងខាងលើ ភូមិភាគបានចាត់វិធានការ ហើយណែនាំតំបន់ឲ្យធ្វើការពិនិត្យស្វែងរកសកម្មភាពទាំងអស់នេះ។ ដូច្នេះ នៅពេលដែលពិនិត្យមើលសកម្មភាពទាំងអស់នេះ យើងបានចាប់យកសមាភាពរបស់ពួកអាឈឹង។ រួមជាមួយគ្នាដែរ យើងឃើញមានភ្នាក់ងារបង្កប់នៅខាងក្នុង។ យើងបានស៊ើបការណ៍តាមដានពួកវា ហើយចាត់វិធានការដើម្បីចាប់តាមការងារជាក់ស្ដែង"។

លោក លោកស្រីចៅក្រម ឯកសារ E3/179 គឺជារបាយការណ៍មកពីភូមិភាគពាយ័ព្យ។ មន្ទីរម-៥៦០ ផ្ញើជូនអង្គការ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧។ លេខ--ផ្នែកដែលពាក់ព័ន្ធត្រង់ខ្មែរមានលេខ ERN 00008498, អង់គ្លេស 00183011 ដល់ 12, បារាំងគឺលេខ 00236768 ដល់ 69។ នៅត្រង់ទំព័រដូចដែលខ្ញុំលើកឡើងនេះ មន្ទីរភូមិភាគបស្ចិម -- ភូមិភាគពាយ័ព្យលើកឡើងអំពីការចាប់ខ្លួនមនុស្ស ៤២នាក់នៅតំបន់៣។ ដោយលើកឡើងដូចតទៅ៖ "យើងសង្កេតឃើញថាសកម្មភាពទាំងអស់នេះ កើតចេញពីទាហានយុទ្ធជនចាស់ និងអ្នកមានស័ក្តិ២ និងស័ក្តិ១ ស័ក្តិ៣ និងស័ក្តិ៤ ដែលពួកគេបង្កប់ខ្លួននៅក្នុងសហករណ៍ ហើយដែលយើងមិនធ្លាប់រកឃើញពីមុនមក។ ថ្មីៗនេះសកម្មភាពរបស់ពួកវាបានលេចចេញច្បាស់។ យើងបានចាប់វិធានការ ហើយចាប់ពួកវាអស់ហើយ"។ បញ្ចប់ការដកស្រង់។

[០៩:៤៤:៣៨]

ឯកសារពីរចុងក្រោយដែលខ្ញុំនឹងបង្ហាញអំពីគោលនយោបាយទាំងនេះ គឺឯកសារចេញមកពីភូមិភាគឧត្តរ។ ឯកសារ E3/1144 ជាសារទូរលេខមកពីលេខាភូមិភាគឧត្តរឈ្មោះ សេ ផ្ញើជូនគណៈ ៨៧០ ចុះថ្ងៃទី០៥ កញ្ញា ឆ្នាំ១៩៧៧។ សារទូរលេខនេះចម្លងជូនអ៊ំ, អ៊ំនួន, អ៊ំវ៉ាន់, បងវន, បងខៀវ។

នៅចុងក្រោយផ្នែកទី១ នៃសារទូរលេខត្រង់ខាងក្រោមទំព័រខ្មែរ 00069447, អង់គ្លេស 00517923, បារាំង 00532726។ នៅក្នុងទំព័រនេះនៅខាងក្រោម យើងឃើញមានរបាយការណ៍មួយរៀបរាប់អំពីសភាពការណ៍ខ្មាំងផ្ទៃក្នុងដែលលេខាភូមិភាគបានរាយការណ៍ដូចតទៅនេះ៖ "នៅតាមមូលដ្ឋាន មន្ទីរ

ក្រសួង និងយោធា យើងបានរកឃើញខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជាបន្តបន្ទាប់ ទាំងការតាមដានសកម្មភាពក្បត់ប្រឆាំងបដិវត្តន៍ ទាំងតាមចម្លើយ។ ឯពួកខ្មាំងជារដ្ឋការ និងប៉ូលិស ទាហានចាស់ យើងរកឃើញជាបន្តបន្ទាប់"។ បញ្ចប់ការដកស្រង់។

[០៩:៤៦:១៧]

ឯកសារចុងក្រោយបង្ហាញអំពីគោលនយោបាយនេះគឺឯកសារ E3/996។ ឯកសារសាទូរលេខចុះថ្ងៃទី១៩ មីនា ឆ្នាំ៧៨ ផ្ញើជូនពីលេខាភូមិភាគឧត្តរ ជូនទៅគណៈកម្មាធិការ៨៧០។ នៅចុងក្រោយសារទូរលេខ គឺរាយការណ៍អំពីសភាពការណ៍ខ្មាំងស៊ីរូងផ្ទៃក្នុងដែលមានសរសេរដូចតទៅ៖ "នៅក្នុងរដូវប្រាំងខ្មាំងដែលនៅសល់លេចឡើង ហើយចាត់វិធានការប្រឆាំងយើង និងការដ្ឋានការងាររបស់យើង។ ខ្មាំងទាំងអស់នេះទាក់ទងជាមួយនឹងអតីតប៉ូលិសជំនាន់មុន ទាហាន និងរដ្ឋការជំនាន់មុន។ ពួកគេប្រមូលផ្តុំគ្នាហើយបង្កើតទៅជាប្រជាជនថ្មី។ ក្រោយពួកគេប្រឆាំងនឹងយើង យើងដឹងស្គាល់ពួកវាច្បាស់ ហើយយើងបានកម្ទេចបោសសម្អាតពួកវាជាលក្ខណៈប្រព័ន្ធ"។ បញ្ចប់ការដកស្រង់។

លោកប្រធាន គឺយើងខ្ញុំបានបញ្ចប់ឯកសារបង្ហាញអំពីគោលនយោបាយកំណត់ទិសដៅកម្ទេចមន្ត្រីរដ្ឋការ និងទាហានរបប លន់នល់។ ហើយបន្ទាប់មកសហសេវិករបស់ខ្ញុំ ខាងជាតិនឹងបង្ហាញអំពីឯកសារពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ!

[០៩:៤៧:៥៥]

**លោក ច័ន្ទ តារាស្មី៖**

បាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គជំនុំជម្រះក៏ដូចជាលោក លោកស្រីដែលជាទស្សនិកជនដែលបានចូលរួមសវនាការថ្ងៃនេះ។

ក្នុងនាមខ្ញុំតំណាងឲ្យសហព្រះរាជអាជ្ញា ខ្ញុំសូមបង្ហាញជូននូវគោលនយោបាយដែលទាក់ទិនទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាគោលនយោបាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំពោះគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យស្តីពីការរៀបអាពាហ៍ពិពាហ៍ ឬនិយាយឲ្យកាន់តែច្បាស់ជាងនេះទៅទៀត គឺការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ វាជាការសំខាន់ណាស់ដែលជាដំបូងយើងខ្ញុំសូមបង្ហាញឯកសារទាំងឡាយដែលទាក់ទិនទៅនឹងគោលដៅខ្ពស់បំផុតរបស់របបនេះ ហើយក៏

ទាក់ទិននឹងផងដែរទៅនឹងកំណើនប្រជាជន។ បន្ទាប់មកទៀត យើងនឹងបង្ហាញឯកសារដែលទាក់ទិននឹងគោលគំនិតនៃគ្រួសារបដិវត្តន៍។

លោកប្រធានជាទីគោរព! ក្នុងពេលដែលខ្ញុំបង្ហាញទាក់ទងនឹងគោលនយោបាយរបស់របបខ្មែរក្រហមដែលទាក់ទិនទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ខ្ញុំក៏សូមបង្ហាញផងដែរនូវឯកសារមួយចំនួននៅលើអេក្រង់កំព្យូទ័រ ហើយមុនពេលដែលខ្ញុំបង្ហាញ ខ្ញុំនឹងជម្រាបជូនអំពីឈ្មោះឯកសារ និងលេខទំព័រ ERN ជាភាសាខ្មែរ ជាភាសាបារាំង និងជាភាសាអង់គ្លេស។

ជាដំបូងនេះខ្ញុំសូមលើកឡើងនូវឯកសារមួយដែលមានឈ្មោះឯកសារ E3/25 ឬ D243/2.1.9 ស្ដីពីទង់បដិវត្តន៍លេខពិសេសដែលចេញផ្សាយនៅខែធ្នូ ដល់ខែមករា នៅចន្លោះឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧។ អត្ថបទនៅក្នុងទង់បដិវត្តលេខពិសេសនេះគឺមានចំណងជើងថា “បទឧទ្ទេសនាមរបស់សមមិត្តតំណាងអង្គការបក្សក្នុងឱកាសបុណ្យខួបទី៩ នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជាដ៏អង់អាចក្លាហាន និងខ្លាំងពូកែមហាអស្ចារ្យ”។

[០៩:៤៩:៥៣]

អត្ថបទនេះគឺបានលើកឡើងនូវការថ្លែងដោយលោក នួន ជា។ នៅក្នុងអត្ថនោះ យើងបានផ្ដោតទៅលើចំណងជើងសំខាន់ គឺត្រង់ចំណងជើងលេខរ៉ូម៉ាំងទីIV ដែលមានខ្លឹមសារថា “អំពីភារកិច្ចបន្តពង្រឹងពង្រីកបន្តកសាងកងទ័ពបដិវត្តន៍របស់បក្សយើងតទៅទៀត”។ ឯកសារយោងនេះគឺជាភាសាខ្មែរ ERN លេខ 00063054, ERN ជាភាសាអង់គ្លេស 00491435, ERN ជាភាសាបារាំង 00504063។ លោក នួន ជា បាននិយាយថា៖ “ដូច្នេះ សារៈសំខាន់នៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមមានទិសដៅកសាងប្រទេសបានល្អ ការពារប្រទេសបានល្អ និងដោះស្រាយជីវភាពប្រជាជនបានឆាប់រហ័ស។ យើងត្រូវការប្រជាជនពី១៥ទៅ២០លាន ទើបគ្រប់គ្រាន់ និងយើង ដីយើងគឺប្រជាជនត្រូវការចំនួនប៉ុណ្ណោះទើបគ្រប់គ្រាន់។ ដើម្បីឲ្យប្រជាជនយើងកើតបានឆាប់ទាល់តែជីវភាពកើនឡើង សុខភាពល្អ។ ដូច្នេះមានតែបង្កបង្កើនផលឲ្យបានឆាប់រហ័ស”។

ឯកសារមួយទៀតគឺ E3/1586 ឬ IS20.10 នៅសម័យប្រជុំពេញអង្គលើកទី២៨ នៃមហាសន្និបាតអង្គការរបស់អង្គការសហប្រជាជាតិ ដែលសរសេរជាភាសាអង់គ្លេស គឺបានជជែកដេញដោលអំពីរបបកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧២ ដែលថ្លែងសុន្ទរកថាដោយលោក អៀង សារី។

[០៩:៥២:០២]

ឯកសារនេះបាន *ហាយឡាយ* គឺទាក់ទិនជាពិសេសទៅនឹងហេតុការណ៍ដែលរបបនេះត្រូវការកម្លាំងមនុស្សកាន់តែច្រើនថែមទៀត ដើម្បីឲ្យស្របនឹងទំហំទឹកដីរបស់ប្រទេស។ ការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជន គឺមិនចាំបាច់ធ្វើឲ្យល្អប្រសើរនូវសុខមាលភាពរបស់បុគ្គលម្នាក់ៗនោះទេ ប៉ុន្តែគឺដើម្បីឲ្យឈានទៅដល់គោលដៅនៃប្រជាសាស្ត្រជាសមូហភាព។

ឯកសារនេះគឺគ្មានការបកប្រែជាភាសាខ្មែរទេ ក៏ប៉ុន្តែមានការបកប្រែ សរសេរជាភាសាបារាំង និងជាភាសាអង់គ្លេស។ ដែលខ្ញុំសូមបង្ហាញជូន ERN ជាភាសាអង់គ្លេស គឺលេខ 00079813, ERN ជាភាសាបារាំង 00617795។ លោក អៀង សារី បាននិយាយថា -- ខ្ញុំសូមដកស្រង់នៅក្នុងកថាខណ្ឌទី៤៥ ត្រង់ចំណុចទី២ និងទី៣ គឺដកស្រង់ត្រង់ ERN ដែលមានជាភាសាខ្មែរ ERN 00291028, ERN ជាភាសាអង់គ្លេស 00079815, ERN ជាភាសាបារាំង 00617798 និង 99។

សូមដកស្រង់កថាខណ្ឌទី៦០ "គោលដៅយើងកំពុងខិតខំព្យាយាមធ្វើឲ្យប្រសើរឡើង យ៉ាងឆាប់រហ័សនូវស្ថានភាពរស់នៅ និងសុខមាលភាពរបស់ប្រជាជនយើង ពីព្រោះយើងត្រូវការប្រជាជនចំនួន ១៥ ទៅ២០លាននាក់ក្នុងរយៈពេល១០ឆ្នាំខាងមុខ។ អំពើអបាយមុខ បទល្មើស ពេស្យាចា អំពើលួចប្លន់ និងអំពើអាក្រក់ក្នុងសង្គមគ្រប់"។

[០៩:៥៤:០៧]

ក្នុងកថាខណ្ឌទី៦៣ ខ្ញុំសូមដកស្រង់បន្ថែម៖ "គឺយើងត្រូវដើរលើផ្លូវដ៏វែងឆ្ងាយដើម្បីសម្រេចបានបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនយើង។ យើងត្រូវបង្កើនការខិតខំប្រឹងប្រែងឲ្យបានទ្វេដង។ យើងកំពុងខិតខំប្រឹងប្រែងឲ្យបានខ្លាំងកាន់តែតាមដែលអាចធ្វើទៅបាន ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងថែមទៀតនូវស្ថានភាពរស់នៅរបស់ប្រជាជនយើង ដើម្បីឲ្យយើងមានកម្លាំងគ្រប់គ្រាន់ និងសុខភាពល្អ និងការស្នេហាជាតិយ៉ាងក្លៀវក្លា និងដើម្បីឲ្យប្រជាជនទាំងអស់មានការរីកចម្រើនឥតឈប់ឈរ និងបន្តការការពារជាតិ និងកសាងប្រទេសកម្ពុជា ឲ្យបានសំបូររុងរឿងយ៉ាងឆាប់រហ័ស។ យើងគ្មានហេតុផលដើម្បីកាត់បន្ថយចំនួនប្រជាជន ឬនៅកម្រិតបច្ចុប្បន្នដែលយើងមានប្រជាជនជិត៨លាននាក់តែប៉ុណ្ណោះ។ ចំនួនប្រជាជនយើងនៅខ្វះច្រើនណាស់ ធៀបនឹងសមត្ថភាពរបស់ប្រទេសយើង ដែលត្រូវការប្រជាជនជាង២០លាននាក់។ ហេតុនេះហើយ ទិសដៅរបស់យើងគឺធ្វើឲ្យមានការកើនឡើងចំនួនប្រជាជនយើងឲ្យបានឆាប់រហ័ស។

នៅក្នុងលិខិតមួយទៀតដែលបានបញ្ជូនទៅអង្គការសហប្រជាជាតិ ៦ខែក្រោយមក ក្នុងខែមេសា ឆ្នាំ១៩៧៨ លោក អៀង សារី បាននិយាយអំពីលទ្ធផលជោគជ័យនានា អំពីការកើនឡើងនៃចំនួនប្រជាជនដែលត្រូវបានរៀបរាប់ថា ជាគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ។

[០៩:៥៦:០៣]

លោក លោកស្រីចៅក្រម ជាទីគោរព របបកម្ពុជាប្រជាធិបតេយ្យបានផ្តល់ស្ថិតិនានាដែលគ្រាន់តែជាការស្មាន់ដែលទាក់ទិននឹងការកើនឡើងនៃចំនួនប្រជាជនតែប៉ុណ្ណោះ។

ខ្ញុំសូមលើកឯកសារមួយទៀត គឺឯកសារលេខ E3/686, D56-Doc.234 សេចក្តីរាយការណ៍របស់ ប៊ី.ប៊ី.ស៊ី អេស.ដាប់បែលយូ.ប៊ី ដែលមានចំណងថា “បទសម្ភាសន៍ជាមួយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ស្តីគោលនយោបាយប្រជាជន និងការតស៊ូប្រឆាំងនឹងវៀតណាម ថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៨១”។

សេចក្តីដកស្រង់ចេញបទសម្ភាសន៍ដែលត្រូវបានថតសំឡេងជាមួយនឹង នួន ជា ប្រធានសភាតំណាងប្រជាជនកម្ពុជា និងប្រធានគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ ដែលចូលរួមនៅក្នុងសន្និសីទសភាអាស៊ីដែលត្រូវបានប្រារព្ធឡើងនៅទីក្រុងប៉េកាំង ស្តីពីប្រជាជននិងការអភិវឌ្ឍ។ ឯកសារនេះគឺមានជាភាសាខ្មែរ។ ខ្ញុំសូមដកស្រង់ដែលមាន ERN លេខ000644682, ERN ជាភាសាអង់គ្លេស 0003 0349, ERN ជាភាសាបារាំង 00599792។

[០៩:៥៧:៤០]

ក្នុងលេខទំព័រនៃអត្ថបទនេះលោក នួន ជា បាននិយាយថា៖ “យើងប្រឈមមុខនឹងបញ្ហានៃរបាយប្រជាជនតិច។ មានន័យថា ទំហំនៃចំនួនប្រជាជនរបស់យើងមិនសមស្របទៅនឹងទំហំផ្ទៃក្រឡារបស់ប្រទេសកម្ពុជា។ ធនធានធម្មជាតិរបស់យើងដែលអាចត្រូវបានយកមកប្រើប្រាស់សម្រាប់ការកសាងជាតិ ឬតម្រូវការរបស់ខ្លួនក្នុងការការពារទឹកដី។ ចាប់តាំងពីឆ្នាំ១៩៧៥មក កម្ពុជាប្រជាធិបតេយ្យជានិច្ចកាលត្រូវការឲ្យមានកំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាជនរបស់ខ្លួន។ ដូចនេះហើយ ផែនការរយៈពេល៤ឆ្នាំ គឺឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៨០ មានគោលបំណងបង្កើនចំនួនប្រជាជនឲ្យឡើងដល់យ៉ាងហោចណាស់១៥លាននាក់នៅក្នុងរយៈពេលពី៥ ទៅ១០ឆ្នាំ។ ជាផលិតផលនៃផែនការនេះ ចំនួនប្រជាជនរបស់យើងបានកើនឡើងដូចតទៅចាប់ពីខែមីនា ដល់ខែធ្នូ ឆ្នាំ១៩៧៦ កម្ពុជាបានបង្កើនប្រជាជនចំនួន១៦០ពាន់នាក់ ឬស្មើនឹងពីរភាគរយ។ នៅក្នុងឆ្នាំ១៩៧៧ កម្ពុជាបានបង្កើនចំនួនប្រជាជន២២០ពាន់នាក់ ឬស្មើនឹង

២.៨ភាគរយ និងនៅក្នុងឆ្នាំ១៩៧៨ កម្ពុជាបានបង្កើនចំនួនប្រជាជន២៦០ពាន់នាក់ ឬស្មើនឹង៣.២ ភាគរយ។ កំណើននេះ គឺជាផលិតផលនៃគោលនយោបាយនៃកម្ពុជាប្រជាធិបតេយ្យដើម្បីការពារជីវិតប្រជាជន ពិសេសតាមរយៈការដោះស្រាយ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជន”។

[០៩:៥៩:៣៥]

លោក លោកស្រីចៅក្រម ជាទីគោរព! ទស្សនៈអំពីគ្រួសារក្រោមសម័យរបបកម្ពុជាប្រជាធិប-តេយ្យ គឺមានខ្លឹមសារដូចតទៅ៖ “នៅក្នុងឈុតឯកសារនានារបស់កម្ពុជាប្រជាធិបតេយ្យបានពន្យល់អំពីថាតើគោលគំនិតតាមប្រពៃណីគ្រួសារត្រូវបានផ្លាស់ប្តូរមកជាគ្រួសារបដិវត្តន៍យ៉ាងដូចម្តេច? និងពីការគិតគូរផលប្រយោជន៍ផ្ទាល់របស់គ្រួសារគឺស្មើនឹងអំពើក្បត់”។

ខ្ញុំសូមអនុញ្ញាតដកស្រង់ឯកសារ ដែលមានឈ្មោះ E3/10, D243/2.1.7។ ឯកសារនេះស្តីអំពីទង់បដិវត្ត លេខពិសេសចេញផ្សាយខែកញ្ញា ខែតុលា ឆ្នាំ១៩៧៦ ដែលអត្ថបទនោះមានចំណងជើងថា “សម្រួចសតិអារម្មណ៍នៃវណ្ណៈអធនឲ្យមុតស្រួច និងខ្លាំងក្លាបំផុត”។ ឯកសារនេះគឺមានលេខ ERN ជាភាសាខ្មែរ 00063104, ERN ជាភាសាអង់គ្លេស 00450538, ERN ជាភាសាបារាំង 00491904 និង 05។ ក្នុងឯកសារដែលមានលេខទំព័រដូចបានជម្រាបជូនអម្បាញ់មិញនេះ គឺខ្ញុំផ្តោតទៅលើចំណងជើងត្រង់ចំណុចទីIV ស្តីពីការតស៊ូវណ្ណៈរវាងកម្មសិទ្ធិឯកជន។ របស់វណ្ណៈផ្សេងៗ ប្រឆាំងនឹងកម្មសិទ្ធិសមូហភាពរបស់វណ្ណៈអធន។

[១០:០១:២៨]

នៅក្នុងឯកសារនេះបានលើកឡើងអំពីបាតុភូតកម្មសិទ្ធិឯកជន។ ខ្ញុំសូមដកស្រង់ “បាតុភូតខ្លះទៀត កម្មសិទ្ធិឯកជនក្នុងការចាត់តាំង ចាត់តាំងតាមមនោសញ្ចេតនារបស់ខ្លួន គ្រួសាររបស់ខ្លួន បក្សពួករបស់ខ្លួន មិនឈរលើមាគ៌ានយោបាយសតិអារម្មណ៍ចាត់តាំងរបស់បក្ស។ ដូច្នេះខុសហើយ”។ សូមបញ្ចប់ការដកស្រង់។

នៅក្នុងឯកសារនេះខ្ញុំសូមបញ្ជាក់ចំណុចទី២ នៅក្នុងចំណុចទីIV ថាបច្ច័យអាក្រក់ និងគ្រោះអាសន្ននៃកម្មសិទ្ធិឯកជន។ ឯកសារទង់បដិវត្តនេះក៏បានចង្អុលបង្ហាញថា៖ “កម្មសិទ្ធិឯកជនមិនដែលឲ្យបច្ច័យល្អទេ ក្នុងបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យក៏ដូច្នេះ។ តាំងពីដំណើរការតស៊ូរបស់យើងជាបន្តបន្ទាប់មក ពេលតស៊ូនយោបាយក៏ដោយ ពេលតស៊ូអាវុធក៏ដោយ ពេលសង្គ្រាមក៏ដោយ កម្មសិទ្ធិឯកជនវាប៉ះពាល់ដល់ផលប្រយោជន៍បដិវត្តន៍។ ឧទាហរណ៍ អ្នកណាគិតគូរផលប្រយោជន៍គ្រួសារច្រើន តែង

តែប្រាសចាកបដិវត្តន៍ លះបង់បដិវត្តន៍ រស់នៅដោយឡែក តើសុភមង្គលក្នុងគ្រួសារវិញមិនរកសុភមង្គលក្នុងបក្សនេះទេ គឺគេរកសុភមង្គលក្នុងគ្រួសារវិញ មិនស្វែងរកសុភមង្គលក្នុងបក្សទេ។ មួយរយៈណាមួយវាប្រែប្រួលជាគុណភាពទំនាស់ជាមួយបក្ស។ ខ្មាំងសត្រូវវាអូសទាញសមាសភាពខ្លះ កម្មសិទ្ធិឯកជនតែល្មម មិនទៅធ្វើការឲ្យខ្មាំងទេ គ្រាន់តែសម្ងំសុខ តែសមាសភាពខ្លះទៅធ្វើការឲ្យខ្មាំងហើយក្បត់បដិវត្តន៍។ សូមបញ្ចប់ការដកស្រង់បាទ។

[១០:០៣:២៩]

អង្គជំនុំជម្រះជាទីគោរព ឯកសារបន្ទាប់មកនេះគឺជាឯកសារដែលទាក់ទងជាពិសេសទៅនឹងការលើកទឹកចិត្តឲ្យមានការលះបង់គ្រួសារ ឪពុកម្ដាយ បងប្អូន កូន ដើម្បីបម្រើបក្ស ហើយសមាជិកគ្រួសារត្រូវបានចាត់ទុកថាជាកម្មសិទ្ធិឯកជន។

ជាបន្តទៅនេះខ្ញុំសូមលើកយកឯកសារដែលមានលេខ E3/750 ឬ D243/2.1.21 ស្ដីពីទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្ត លេខ១១ ចេញផ្សាយខែវិច្ឆិកា ឆ្នាំ១៩៧៥។ ក្នុងនោះគឺមានអត្ថបទទី២ដែលមានចំណងជើងថា៖ “កម្ចាត់កម្មសិទ្ធិបុគ្គលស្វនតួឲ្យជ្រះស្រឡះ ហើយពង្រឹងនិងពង្រីកកម្មសិទ្ធិសមូហភាពឲ្យខ្លាំងក្លា”។ បាទ សូមបញ្ចប់ការដកស្រង់ចំពោះឯកសារនេះ។

[១០:០៤:៣៦]

ហើយខ្ញុំសូមបន្តលេខទំព័រ ERN ជាភាសាខ្មែរ 00063614 ដល់ 15, ERN ជាភាសាអង់គ្លេស 00522460, ERN ជាភាសាបារាំង 00525856 ដល់ 57។ ក្នុងឯកសារដែលមានលេខ ERN នេះ គឺនិយាយអំពីចំណុចទី២ធំ និយាយអំពី “សមាសភាពកម្មសិទ្ធិនៅក្នុងជួរបដិវត្តន៍យើង។ នៅក្នុងជួរបដិវត្តន៍យើង យុវជន យុវនារី និងកម្មាភិបាលទាំងអស់សុទ្ធតែបានលះបង់កម្មសិទ្ធិផ្ទាល់ខ្លួន ជាផ្ទះសម្បែងស្រែចម្ការ ច្បារដំណាំ ជាគ្រួសារម៉ែឪ បងប្អូន កូនចៅ និងជាទ្រព្យសម្បត្តិផ្សេងៗទាំងអស់ ដើម្បីបម្រើបក្ស បម្រើបដិវត្តន៍ និងប្រជាជន។ ចូលមកក្នុងជួរបដិវត្តន៍ហើយ ដោយបានបក្សឃោសនាអប់រំកែប្រែតម្រង់ជាប់។ មិត្តយើងទាំងអស់ក៏បានខិតខំកសាងនូវគោលជំហរលះបង់ ទាំងខាងសម្ភារៈ ទាំងខាងសតិអារម្មណ៍ និងមនោសញ្ចេតនាខ្ពស់ថែមទៀត។ តែទោះបីជាយ៉ាងណាក៏ដោយ កម្មសិទ្ធិខាងមនោសញ្ចេតនាគិតគូរ ឬអាណិតអាសូរ អាណិតស្រណោះ ស្រលាញ់តែក្រុមគ្រួសារខ្លួន ញាតិមិត្តខ្លួនបងប្អូនខ្លួន ឪពុកម្ដាយខ្លួន។ តែបើចំពោះប្រជាជន ទាំងអស់នេះសុទ្ធសឹងជាបាតុភាពខុសឆ្គង ដែលស្ដែងចេញមកអំពីគោលជំហរកម្មសិទ្ធិបុគ្គលស្វនតួទាំងអស់ ដែលជាសតិអារម្មណ៍របស់វណ្ណៈជិះជាន់ មាន

ចក្រពត្តិ សក្តិភូមិ និងនាយទុនជាដើម។ យុវជន យុវនារីបដិវត្តន៍យើង ត្រូវឃើញ ហើយមានទស្សនៈឲ្យបានច្បាស់លាស់ថា សតិអារម្មណ៍កម្មសិទ្ធិបុគ្គលស្វនត្ថវាមាននៅក្នុងជួរបដិវត្តន៍ ក្នុងជួរយុវជនយុវនារីបដិវត្តន៍យើងក៏ដូចក្នុងខ្លួនយើងនៅឡើយដែរ។ យើងឃើញយ៉ាងនេះ មិនមែនដើម្បីទុទិដ្ឋិនិយមអស់សង្ឃឹម ឬអនុគ្រោះបណ្តែតបណ្តោយទុកឲ្យវារស់រានមានជីវិត ពួនសម្ងំនៅក្នុងខ្លួនយើងក៏ដូចនៅក្នុងជួរបដិវត្តន៍ និងជួរយុវជនយុវនារីយើងតទៅទៀតនោះឡើយ។ យើងឃើញសភាពសត្យានុម័តិយ៉ាងនេះ ដើម្បីប្រុងប្រយ័ត្នជាប់ តស៊ូនឹងវាជានិច្ច ហើយមានវិធានការជាក់ស្តែងទប់ទល់នឹងវាយកម្ទាត់វាឲ្យបានជាដាច់ខាត"។ សូមបញ្ចប់ការដកស្រង់។

[១០:០៨:០៣]

ជាបន្តទៀត ខ្ញុំសូមលើកយកឯកសារមួយទៀត គឺឯកសារ E3/766 ឬ D248/4.11។ ឯកសារនេះនិយាយអំពីយុវជន និងយុវនារីបដិវត្តន៍ លេខ១១ ចេញផ្សាយខែវិច្ឆិកា ឆ្នាំ១៩៧៨។ អត្ថបទដែលមានចំណងជើងថា "រឿងបដិវត្តន៍: កុមារកូនបក្ស"។ នៅក្នុងរឿងឃោសនាដល់យុវជនមានក្មេងប្រុសម្នាក់អាយុ១៥ឆ្នាំ ត្រូវបានសម្ភាស ហើយត្រូវបានផ្តល់ជាឧទាហរណ៍ក្នុងការសម្រេចរបស់ខ្លួន ក្នុងការកម្ទេចយួនទាំងអស់។ នេះគឺជាអ្វីដែលកូនរបស់បក្សបាននិយាយអំពីគ្រួសារនិងឪពុកម្តាយរបស់ខ្លួន។

ខ្ញុំសូមដកស្រង់ឯកសារដែលមាន ERN លេខជាភាសាខ្មែរ 00376532, ERN ជាភាសាអង់គ្លេស 00524181, ERN ជាភាសាបារាំង 00593981។ ខ្ញុំសូមដកស្រង់ដូចតទៅ៖ "ខ្ញុំគ្មានឪពុកម្តាយទេ គ្មានបងប្អូនទេ។ ខ្ញុំជាកូនបក្សកុម្មុយនីស្តកម្ពុជា។ ឪពុកម្តាយខ្ញុំ បងប្អូនខ្ញុំត្រូវខ្មាំងយួនវាសម្លាប់ចោលខ្ទេចខ្ទីអស់ហើយ។ កាលវាចូលឈ្លានពានពីឆ្នាំ១៩៧៦ ភូមិករណ៍ ផ្ទះសម្បែងខ្ញុំ ស្រែចម្ការខ្ញុំក៏ត្រូវខ្មាំងយួនវាដុតបំផ្លាញ និងឆក់ប្លន់ ដឹកជញ្ជូនយកទៅស្រុកវាអស់ហើយ។ ឥឡូវនេះ ខ្ញុំរស់នៅក្នុងគ្រួសារថ្មី គឺក្រុមកុមារកងទ័ព ហើយឪពុកម្តាយខ្ញុំ គឺបក្សកុម្មុយនីស្តកម្ពុជានេះឯង។ ឥឡូវខ្ញុំខំរើស្រុក"។ សូមបញ្ចប់ការដកស្រង់។

[១០:១០:២៤]

អង្គជំនុំជម្រះជាទីគោរព លោក លោកស្រីចៅក្រមជាទីគោរព! ជាបន្តទៅនេះ ខ្ញុំសូមលើកបន្ថែមទៀតទាក់ទងទៅនឹងឯកសារមួយចំនួនបន្តទៀតបាទ។ នេះជាឯកសារសហកាលិកភាពសំខាន់បំផុត ដូចទៅនឹងគោលគំនិតអំពីគ្រួសារ និងបទប្បញ្ញត្តិអំពីអាពាហ៍ពិពាហ៍។ ទោះបីជាការបោះពុម្ពនេះគឺធ្វើដើមខែកុម្ភៈ ឆ្នាំ១៩៧៤ក៏ដោយ ក៏វាបានបោះពុម្ពក្រោមសម័យនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបង្ហាញ

ខ្លឹមសាររបស់វានៅតែមានការទាក់ទង ហើយឆ្លុះបញ្ចាំងទៅលើគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យយ៉ាងពិតប្រាកដនៅក្នុងសម័យកាលនោះ។

ខ្ញុំសូមបន្តដកស្រង់ឯកសារមួយចំនួនទៀតដែលទាក់ទិននឹងគ្រួសារជាទូទៅ និងទាក់ទិនទៅនឹងបទប្បញ្ញត្តិនៃអាពាហ៍ពិពាហ៍។ ឯកសារ E3/775 ឬ D267/3.36, ការបោះផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមានចំណងជើងថា "លោកទស្សនៈបដិវត្តន៍ និងមិនបដិវត្តន៍ចំពោះបញ្ហាកសាងគ្រួសារ"។ ក្នុងឯកសារនេះគឺបានបោះពុម្ពបន្តត្រឹមត្រូវតាមយុវជនយុវនារី លេខ២ កុម្ភៈ ឆ្នាំ១៩៧៤ ដោយក្រសួងនយោបាយ យោធា ភូមិភាគបូព៌ាទិសនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៧៥។ បោះផ្សាយលើកទី២ ខែកញ្ញា ឆ្នាំ១៩៧៥ ចំនួន១000ក្បាល។

[១០:១២:២៣]

លោកប្រធានខ្ញុំសូមដកស្រង់ឯកសារនេះ គឺដែលមានលេខ ERN ទំព័រជាភាសាខ្មែរ 00407098, ERN ជាភាសាអង់គ្លេស 00392451, ERN ជាភាសាបារាំង 00611526 និង 27។ ខ្ញុំសូមដកស្រង់ដូចតទៅ៖ "ដូច្នេះហើយបានជាកាលពីនៅក្នុងសង្គមចាស់មុនពេលរំដោះ និងនៅក្នុងតំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្ន សព្វថ្ងៃយុវជនយុវនារីយើងជាច្រើន--

**ប្រធានអង្គជំនុំ៖**

បាទ លោកតំណាងមានបញ្ហាអីទេ?

សូមបន្តទៀតបាទ!

[១០:១៣:២៤]

**លោក ច័ន្ទ តារាស្មី៖**

ខ្ញុំសូមបន្តទៀតលោកប្រធាន អរគុណ។ ខ្ញុំសូមបន្តជាថ្មីឡើងវិញ។ "ដូច្នេះហើយបានជាកាលពីនៅក្នុងសង្គមចាស់ មុនពេលរំដោះ និងនៅក្នុងតំបន់ខ្មាំងកាន់កាប់បណ្តោះអាសន្ន សព្វថ្ងៃយុវជនយុវនារីយើងជាច្រើនដែលជ្រួតជ្រាបនូវលោកទស្សនវណ្ណៈជិះជាន់នេះ គេរើសគ្រួសារ ឬកសាងគ្រួសារសុទ្ធតែដើម្បីបានលាភសក្ការៈផ្ទាល់ខ្លួន ពោលគឺគេស្វែងរកផលប្រយោជន៍ ឬសុភមង្គលគ្រួសារដោយផ្តាច់ចេញស្រឡះពីផលប្រយោជន៍ ពីជោគវាសនានៃប្រទេសជាតិ និងប្រជាជនទាំងមូល"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

ហើយសូមចូលទៅទំព័រ ERN ថ្មីមួយទៀតឯកសារដដែល គឺERN ជាភាសាខ្មែរ 00407100,

ERN ជាភាសាអង់គ្លេស 00417942, ERN ជាភាសាបារាំង 00593929។ ក្នុងឯកសារ ERN ដែលមានលេខទំព័រខាងលើនេះ គឺខ្ញុំសូមអានដកស្រង់ត្រង់ចំណុចII ដែលនិយាយអំពីលោកទស្សនៈបដិវត្តន៍ចំពោះបញ្ហាការកសាងគ្រួសារ។ ខ្ញុំសូមដកស្រង់ដូចតទៅ៖

[១០:១៥:១៥]

“ចំពោះយើងជាយុវជន យុវនារីបដិវត្តន៍ យើងទុកបញ្ហាគ្រួសារជាផ្នែកមួយបេះមិនដាច់ពីបញ្ហាប្រទេសជាតិនិងប្រជាជនទាំងមូល។ បើប្រជាជនយើងត្រូវចក្រពត្តិ សក្តិភូមិ នាយទុនប្រតិកិរិយាជិះជាន់ សង្កត់សង្កិន រងទុក្ខវេទនា ឥតត្រើយត្រាណនោះគ្រួសារយើងក៏នឹងត្រូវទទួលការជិះជាន់ដូចគ្នាដែរ។ ដូច្នេះ ដើម្បីឲ្យគ្រួសារយើងស្គាល់សុភមង្គលពិតប្រាកដ មានសេចក្តីសុខសាន្តចម្រុងចម្រើនបានលុះត្រាតែប្រទេសជាតិ និងប្រជាជនយើងទាំងមូលត្រូវបានរំដោះរួចផុតពីការជិះជាន់គ្រប់បែបយ៉ាងរបស់ចក្រពត្តិសក្តិភូមិ នាយទុកប្រតិកិរិយាសិន។ ដូច្នេះ ការកសាងគ្រួសារបដិវត្តន៍យើងគឺមិនមែនគ្រាន់តែដើម្បីផលប្រយោជន៍ស្វនតួបានសុខ បានសប្បាយ មានកូនមានចៅសម្រាប់បន្តពូជពង្សខ្លួនប៉ុណ្ណោះទេ តែសំខាន់គឺដើម្បីធ្វើបដិវត្តន៍សម្រេចភារកិច្ចដ៏ឧត្តុង្គឧត្តម រំដោះប្រទេសជាតិប្រជាជន និងវណ្ណៈក្រីក្រឲ្យឈានទៅកសាងសង្គម សង្គមនិយម និងកុម្មុយនីស្តនិយមដែលជាសង្គមគ្មានមនុស្សជិះជាន់មនុស្សទៀត”។ សូមបញ្ចប់ការដកស្រង់។

[១០:១៧:១៨]

ជាបន្តទៅនេះខ្ញុំសូមដកស្រង់ទៅលើទំព័រ ERN ដែលមានលេខ ERN ជាភាសាខ្មែរ 0040 7102, ERN ជាភាសាអង់គ្លេស 00417944, ERN ជាភាសាបារាំង 00593931។ ខ្ញុំសូមដកស្រង់ត្រង់ចំណុចទី២ ដែលនិយាយអំពីផលវិបាកនៃការកសាងគ្រួសារមិនបានត្រឹមត្រូវ។ ខ្ញុំសូមដកស្រង់ដូចតទៅ “ម្ល៉ោះហើយខ្មាំង ទាំងខ្មាំងជាយុទ្ធសាស្ត្រ ទាំងខ្មាំងជាយុទ្ធវិធី ទាំងខ្មាំងវណ្ណៈដែលរស់នៅក្នុងតំបន់រំដោះនៅឡើយវាមានឧបាយកលចង់រើយើងពីក្នុងពោះវៀនយើងទៅវិញ។ ដោយបញ្ចូលគ្នាវាមកស៊ីរូងបំផ្លិចបំផ្លាញនៅក្នុងជួរយើងតែម្តង។ ដោយទាក់ទាញឲ្យកូនឲ្យចៅភ្ជាប់ជាសាច់ញាតិ ហើយអូសទាញតាមមនោសញ្ចេតនាគ្រួសារ ញុះញង់ បំបែកបំបាក់យើងពីបដិវត្តន៍ឲ្យប្រឆាំងនឹងបដិវត្តន៍ ឬឲ្យក្បត់ផលប្រយោជន៍បដិវត្តន៍ និងប្រជាជនទៅបម្រើផលប្រយោជន៍គ្រួសារគេ ការពារវណ្ណៈគេទៅវិញ។ល។” សូមបញ្ចប់ការដកស្រង់ត្រង់ចំណុចនេះ។ ហើយខ្ញុំបន្តអានបន្តទៀតត្រង់ចំណុច កថាខណ្ឌទី២ នៃចំណុចទី២ដដែលហ្នឹង ក្នុងទំព័រដដែល។

[១០:១៩:២១]

"ដូច្នេះ មិត្តយុវជនយុវនារីបដិវត្តន៍យើងត្រូវចាប់អារម្មណ៍ហើយប្រុងប្រយ័ត្នឲ្យមែនទែនចំពោះបញ្ហាកសាងគ្រួសារនេះ។ បើសិនជាយើងមិនគោរពអង្គការវិន័យ មិនគោរពសមូហភាព មិនប្រកាន់គោលជំហរបដិវត្តន៍រឹងប៉ឹង ហើយសេរីខាងសីលធម៌ ពាសវាលពាសកាលនោះមុខជាកសាងគ្រួសារមិនបានត្រឹមត្រូវល្អតាមគន្លងមាគ៌ាបដិវត្តន៍យើងឡើយ។ នោះមុខជានឹងប៉ះទៅលស់មាសភាពមិនល្អ ឬរហូតដល់ប៉ះទៅលើភ្នាក់ងារបង្កប់របស់ខ្មាំងទៀតក៏មានដែរ"។

អង្គជំនុំជម្រះជាទីគោរព ខ្ញុំសូមបន្តទៅអានលេខទំព័រខ្មែរឯកសារដដែល គឺលេខទំព័រ ERN ជាភាសាខ្មែរ 00407103, ERN ជាភាសាអង់គ្លេស 00417945, ERN ជាភាសាបារាំង 00593932។ ខ្ញុំសូមដកស្រង់ដូចតទៅ៖ "បច្ច័យអាក្រក់ដែលបណ្ដាលមកពីការកសាងគ្រួសារដោយសេរី មិនគោរពអង្គការវិន័យ មិនប្រកាន់គោលជំហរបដិវត្តន៍ មានច្រើនបែបច្រើនយ៉ាងណាស់ ហើយដែលសុទ្ធតែមានគ្រោះមហន្តរាយដល់បក្ស ដល់ចលនាបដិវត្តន៍ និងដល់ខ្លួនទាំងអស់។ បើកសាងគ្រួសារប៉ះទៅលើសមាសភាពមិនល្អ យ៉ាងហោចណាស់ក៏វាអូសទាញឲ្យអសកម្មក្នុងភារកិច្ចបដិវត្តន៍ដែរ។ ខ្លះទៀតរហូតដល់សុំចេញពីបក្ស ចេញពីចលនាបដិវត្តន៍"។ បាទសូមបញ្ចប់ការដកស្រង់ត្រង់ចំណុចនេះ។

[១០:២១:៤៥]

ហើយខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត គឺទាក់ទិននឹងការរៀបការដោយបង្ខំ។ បាទ ខ្ញុំសូមលើកយកឯកសារដែលមានលេខសម្គាល់លេខ E3/775 ឬ D267/3.36 មានខ្លឹមសារថ្លែងថា "អង្គការនិងសេចក្ដីសម្រេចជាសមូហភាពចំពោះការជ្រើសរើសជាប្ដីប្រពន្ធ ដែលត្រូវតែដាច់ខាតគោរព ដោយពួកគេដឹងច្បាស់ថាអ្នកណាត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកណា"។

ខ្ញុំសូមអនុញ្ញាតដកស្រង់ឯកសារដែលមាន ERN ជាភាសាខ្មែរ 00407100 និង 01, ERN ជាភាសាអង់គ្លេស 00417943, ERN ជាភាសាបារាំង 00593930។ ខ្ញុំសូមដកស្រង់ដូចតទៅទាក់ទងចំណុចទី១ ដែលនិយាយអំពី "តើយុវជន យុវនារីបដិវត្តន៍យើងត្រូវរើសគ្រួសារបែបណា ដើម្បីសម្រេចភារកិច្ចបដិវត្តន៍ដោយជោគជ័យ ហើយឈានទៅដល់ទិសដៅដ៏ឧត្ដុងឧត្ដមដូចពោលខាងលើ។ យុវជនយុវនារីបដិវត្តន៍យើងត្រូវប្រុងប្រយ័ត្នឲ្យមែនទែនក្នុងការជ្រើសរើសគ្រួសារនេះ។ ទី១ ត្រូវប្រុងប្រយ័ត្នខាងសីលធម៌ស្រីញី ប្រុសឈ្មោល កុំសេរីផ្ដេសផ្ដាសពាសវាលពាសកាល។ បើមានការអីត្រូវលើកស្នើដល់អង្គការ ដល់សហមូភាពដោយស្មោះត្រង់ ឲ្យជួយដោះស្រាយ។ ទី២ ត្រូវគោរពអង្គការវិន័យ

ដាច់ខាត ក្នុងបញ្ហាកសាងគ្រួសារនេះបើអង្គការសហមូភាពពិនិត្យឃើញយ៉ាងណា សម្រេចយ៉ាងណា ត្រូវគោរពតាមដាច់ខាត កុំទោមនស្ស កុំថ្នាំងថ្នាក់ ព្រោះមានតែអង្គការ មានតែសមូហភាពទេដែលអាចពិនិត្យមើលបានហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយបាន។ ទី៣ កុំតក់ក្រហល់ ប្រញាប់ប្រញាល់ពេក កុំអន្ទះអន្ទែងតាមតែចិត្តខ្លួននឹកឃើញ ត្រូវពិនិត្យមើលប្រវត្តិរូបឲ្យបានច្បាស់លាស់សិន ពោលគឺត្រូវស្អាតទាំងសីលធម៌រស់នៅ ស្អាតទាំងខាងនយោបាយ គ្មានជំពាក់វាក់វិននឹងខ្សែខ្លាំង ឬជាមួយពួកសមាសភាពមិនល្អនោះ។ ទី៤ បើនៅក្នុងជួរដូចគ្នាគឺត្រូវរើសអ្នកដែលមានគោលជំហរបដិវត្តន៍រឹងប៉ឹងទោះជាមិត្តនោះឯងទទួលនាទីជាអ្វីក៏ដោយ ឲ្យតែគេមានគោលជំហរប្រយុទ្ធដាច់ខាត បំពេញភារកិច្ចបដិវត្តន៍ជូនបក្សជូនបដិវត្តន៍ និងប្រជាជនបានល្អជានិច្ច។ ដូច្នេះយើងមិនមែនរើសរកអ្នកណាដែលមានរូបសម្បត្តិល្អ ចេះស្លៀកពាក់តុបតែងកាយ ហ៊ឺហា ទាន់សម័យចក្រពត្តិ ឬក៏ជាកូនអ្នកមានសម្បត្តិទ្រព្យ ឬជាអ្នកមានសមត្ថភាពវប្បធម៌សង្គមចាស់ខ្ពង់ខ្ពស់ ឬអ្នកមានវោហារ ព្រោកប្រាជ្ញ ឬជាសមមិត្តដែលមានកាំភ្លើងខ្លីកាំភ្លើងវែង ឬមាននាទីតំណែងខ្ពង់ខ្ពស់នោះទេ"។ សូមបញ្ចប់ការដកស្រង់លោកប្រធាន។

[១០:២៦:៣៩]

ជាបន្តទៅនេះសូមទាក់ទងទៅនឹងផ្នែកមួយទៀតនៅក្នុងឯកសារដដែលនេះ គឺទាក់ទងជាមួយនឹងទំនាក់ទំនងប្ដីប្រពន្ធក្រោយការរៀបអាពាហ៍ពិពាហ៍។ ខ្ញុំសូមអនុញ្ញាតដកស្រង់ទៅលើឯកសារដែលមានលេខទំព័រ ERN ជាភាសាខ្មែរ 00407104 - 05, និង ERN ជាភាសាអង់គ្លេស 00417945 ដល់ 46, រីឯ ERN ជាភាសាបារាំងគឺមានលេខ ERN ជាភាសាបារាំងលេខ 00593932។ ត្រង់ចំណុចទី៣នៅក្នុងឯកសារដដែលនេះបាននិយាយអំពីទស្សនៈកសាងអប់រំគ្រួសារក្រោយពេលដែលរៀបការរួចហើយ។

ខ្ញុំសូមអនុញ្ញាតដកស្រង់លោកប្រធាន "យើងត្រូវមានទស្សនៈឲ្យច្បាស់លាស់ថា គ្រួសារជាផ្នែកមួយបេះមិនដាច់ពីមហាគ្រួសារបដិវត្តន៍។ ដូច្នេះ ប្ដី ឬប្រពន្ធយើងក៏ជាមហាជនម្នាក់របស់បក្ស។ ជាសមាជិកម្នាក់នៃចលនាបដិវត្តន៍ដែរ។ ដើម្បីឲ្យគ្រួសារយើងបានទៅជាគ្រួសារបដិវត្តន៍ល្អ អាចបំពេញភារកិច្ចបដិវត្តន៍ជូនបក្ស បដិវត្តន៍ និងប្រជាជនបានល្អជារៀងរហូតទៅ ចាំបាច់ត្រូវអប់រំកសាងគេឲ្យយល់នូវមាគ៌ានយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ជាបណ្ដើរៗ។ កុំទុកគេចោល ទុកគ្រាន់តែដាំបាយ មើលកូន មើលផ្ទះ ដូចតែគ្រួសារនៅក្នុងសង្គមចាស់ទៀត។ ម្យ៉ាង យើងជាប្ដីត្រូវយកចិត្តទុកដាក់ឃោសនាអប់រំកសាងគេទៅតាមកន្លងមាគ៌ារបស់បក្ស តែសំខាន់បំផុតគឺត្រូវប្រគល់គេជូនអង្គការជូនសមូហភាពជួយអប់រំកសាង។ មហាជនដើម្បីកសាងខ្លួនក្នុងចលនាក្ដៅ។ ត្រូវចៀសវាងដាច់ខាត

កុំទម្រើសគ្រួសារមិនប៊ានឲ្យចុះប្រលូកធ្វើពលកម្មជាមួយមហាជនដោយខ្លាចហត់នឿយ ខ្លាចថោកទាប ខ្លាចបាក់មុខបាក់មាត់ ឬក៏កុំចាត់ទុកគ្រួសារខ្លួនជាមហាជនពិសេសម្នាក់ ដែលមានតែខ្លួនទេទើបអប់រំកសាងបាន។ ហើយត្រូវចៀសវាងដាច់ខាត កុំកសាងអប់រំគ្រួសារទៅតាមតែមនោសញ្ចេតនាបុគ្គលស្ងួនគួរបស់ខ្លួនឲ្យសោះ។ តាមពិសោធជាហូរហែកន្លងមកឃើញថា ការកសាងអប់រំគ្រួសារក្នុងក្របខ័ណ្ឌរួញ ក្តោបតែក្នុងគ្រួសារឯង មិនស្រួវបានរីកចម្រើនទេ។ មានតែការប្រគល់គ្រួសារជូនអង្គការ ជូនសមូហភាព ជួយអប់រំកសាងនិងឲ្យចុះប្រលូកក្នុងចលនាមហាជនទេ ទើបអាចកសាងគ្រួសារយើងបានល្អ បានរីកចម្រើនទៅតាម ទិសដៅរបស់បក្ស"។

[១០:៣០:៥០]

លោកប្រធានជាទីគោរព ខ្ញុំមានបំណងចង់បង្ហាញឯកសារបីចុងក្រោយទៀត បាទមុននឹងបញ្ចប់ការបង្ហាញឯកសាររបស់ខ្ញុំនៅពេលនេះបាទ។

ឯកសារជាបន្តនេះគឺឯកសារ E3/681, D56-Doc.209 គឺទាក់ទងទៅនឹងសុន្ទរកថារបស់លោក អៀង សារី នៅក្នុងញ៉ូវយ៉កថាមស៍។ អត្ថបទព័ត៌មានសរសេរដោយលោក ហែនរី ខាំ។ ចំណងជើងរបស់អត្ថបទនេះគឺ "អង្គរក្សរបស់ ប៉ុល ពត ស្វែងរកជំនួយពិភពលោក" ឌីញូវយ៉កថាមស៍ ចេញផ្សាយថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៨០។ នៅក្នុងបទសម្ភាសន៍នេះ អៀង សារី បានពន្យល់ថាចាប់តាំងពីឆ្នាំ១៩៨០ទៅ សេរីភាពខ្លះនឹងត្រូវផ្តល់ទៅដល់ប្រជាជនក្រោមការត្រួតពិនិត្យរបស់កម្ពុជាប្រជាធិបតេយ្យ រួមបញ្ចូលទាំងសិទ្ធិសេរីភាពអាពាហ៍ពិពាហ៍ ដោយសេរី និងសិទ្ធិសម្រាប់គ្រួសាររស់នៅជាមួយគ្នា គឺដូចពីមុន។

បាទ ឯកសារនេះគឺជាឯកសារដែលមាន -- ខ្ញុំសូមដកស្រង់លេខទំព័រ ERN ជាភាសាខ្មែរ 000651246, ERN ជាភាសាអង់គ្លេស 00122194, ERNជាភាសាបារាំង 006393 ដល់ 94។ បាទនៅក្នុងឯកសារនេះ គឺខ្ញុំសូមដកស្រង់ "គឺលោកឧបនាយករដ្ឋមន្ត្រីបានបង្ហាញបទអត្ថាធិប្បាយលម្អិតអំពីកម្មវិធីថ្មីក្រោមការគ្រប់គ្រងសហសេវិករបស់លោក។ លោក អៀង សារី បាននិយាយថា "ឥឡូវនេះយើងអនុញ្ញាតឲ្យមានគណៈបក្សនយោបាយច្រើន"។ លោកអៀង សារី បានបន្តទៀតថា "យើងនឹងអនុញ្ញាតឲ្យមាន-- យើងនឹងអនុញ្ញាតឲ្យមានសេរីភាពសម្រាប់ការប្រតិបត្តិសាសនាទាំងអស់ និងការអប់រំ។ ការរៀបអាពាហ៍ពិពាហ៍នឹងធ្វើដោយសេរី ហើយគ្រួសារទាំងអស់រស់នៅជួបជុំគ្នា។ ដើម្បីសន្សំសំចៃ"។ ឧបនាយករដ្ឋមន្ត្រីបាននិយាយថា "យើងនឹងណែនាំឲ្យមានការការពារទ្រព្យសម្បត្តិឯកជន

សម្រាប់ប្រជាជនយើង និងជនបរទេសដែលចង់ធ្វើការវិនិយោគនៅក្នុងប្រទេសកម្ពុជា”។លោកបានបន្ថែមទៀតថា យើងនឹងមានសហករណ៍ស្ម័គ្រចិត្តដោយគ្មានការបង្ខិតបង្ខំដូចមុន និងមានការសហការជាមួយក្រុមហ៊ុនបរទេស។ ទោះយ៉ាងណាក៏ដោយប្រទេសយើង នៅតែជាប្រទេសមិនទាន់អភិវឌ្ឍនៅឡើយ”។

[១០:៣៣:៣១]

លោកប្រធាន ខ្ញុំសូមអានឯកសារមួយទៀតដែលទាក់ទងទៅនឹងសៀវភៅរបស់លោក ហ្វីលីព ស្សូត ដែលមានចំណងជើងថា “ប៉ុល ពត: ប្រវត្តិសុបិនអាក្រក់មួយ”។ សូមជម្រាបលោកប្រធានផងដែរថា ឯកសារនេះគឺខ្ញុំរកពុំមានឃើញឯកសារបកប្រែជាភាសាខ្មែរទេ គឺមានតែជាភាសាអង់គ្លេស និងជាភាសាបារាំង។ ហេតុដូច្នេះដើម្បីបង្ហាញជូនអង្គសវនាការនៅពេលនេះ ខ្ញុំសូមអានអត្ថបទជាភាសាបារាំងទាំងស្រុង ហើយខ្ញុំសូមអានលេខទំព័រឯកសារនេះ គឺឯកសារ E3/9 ។ ហើយឯកសារនេះមាន ERN ជាភាសាអង់គ្លេស 00396533 ដល់ 34, ERN ជាភាសាបារាំង 00639883។ បាទខ្ញុំសូមអានជាភាសាបារាំង។

(អានជាភាសាបារាំង) “គ្រួសារនៅតែបន្តមានអត្ថិភាព ប៉ុន្តែគោលដៅចម្បងគឺដើម្បីបង្កើតកូនជូនបក្ស។ ទំនាក់ទំនងរវាងសមាជិកគ្រួសារបានរលាយបាត់នៅក្នុងសហគមន៍។ ប៉ុល ពត បានប្រាប់គណៈមជ្ឈិមថាម្ដាយមិនគួរជាប់ជំពាក់ជំពិនជាមួយកូនច្រើនពេកទេ។ ទន្ទឹមនឹងនេះប្រសិនបើបុរសណាម្នាក់មានអារម្មណ៍ថា ខ្លួនចាប់ចិត្តប្រតិព័ទ្ធនារីណាម្នាក់នោះ គឺត្រូវប្រកាន់ជំហរសមូហភាព និងដោះស្រាយវា។ បើធ្វើផ្ទុយពីនេះ គឺមានជំហរឯកជនពេញទី។ ការរៀបការរវាងបក្ខជន និងរវាងបុគ្គលពីរនាក់ជាភារកិច្ចរបស់បក្ស មិនមែនជាកិច្ចការឯកជននោះទេ។ ការជ្រើសរើសប្ដីប្រពន្ធដោយខ្លួនឯង គឺត្រូវផ្ដន្ទាទោសជាចំហ។ ដើម្បីគូសបញ្ជាក់អំពីទិដ្ឋភាពសង្គម ការរៀបការត្រូវធ្វើឡើងជារួមគឺម្ដង ១០គូយ៉ាងតិច។ ក្រោយពីរៀបការរួចប្ដីប្រពន្ធច្រើនតែរស់នៅបែកគ្នា។ ការទាក់ទងគ្នាខុសច្បាប់គឺត្រូវកាត់ទោសប្រហារជីវិត”។ (បញ្ចប់ការអានជាភាសាបារាំង)

[១០:៣៦:៣៤]

អង្គជំនុំជម្រះជាទីគោរព! ការបង្ហាញជូនប្រធានបទដែលទាក់ទងនឹងការរៀបការដោយបង្ខំ ដែលជាគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យនៅពេលនេះ ខ្ញុំសូមបញ្ចប់ត្រឹមតែប៉ុណ្ណេះ។ សូមអរគុណលោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំអានជូននៅពេលនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៧នាទី ដល់ម៉ោង ១១:០២នាទី)*

[១១:០២:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសដាក់បង្ហាញនូវឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុសហឧក្រិដ្ឋកម្មរួម។

សូមអញ្ជើញលោកស្រីមេធាវី ការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

បាទ សូមអរគុណលោកប្រធាន ដែលផ្តល់ឱកាសឲ្យខ្ញុំឡើងមានមតិ។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

ខ្ញុំសោកស្តាយណាស់ដែលបានងើបឡើងបែបនេះ។ ក៏ប៉ុន្តែដោយយោងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះកាលពីម្សិលមិញនេះ។ យើងបានពិនិត្យមើលបញ្ជីឯកសារដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចង់បង្ហាញនៅក្នុងសវនាការនៅថ្ងៃនេះ ពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម។ ខ្ញុំនៅតែរក្សាការជំទាស់របស់ខ្ញុំកាលពីម្សិលមិញ ក៏ប៉ុន្តែយោងតាមសេចក្តីសម្រេចដែលបានប្រកាសកាលពីម្សិលមិញ ដោយលោកចៅក្រម ឡាវែន៍ គឺកាលពីម្សិលមិញនោះ គឺនៅម៉ោងប្រាំបួនម្ភៃពីរ លោកចៅក្រម ឡាវែន៍ បានប្រកាសតាងនាមអង្គជំនុំជម្រះថាអង្គជំនុំជម្រះយល់ឃើញថាឯកសារដែលបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងសេចក្តីណែនាំ ដែលត្រូវអនុវត្តនៅក្នុងក្របខ័ណ្ឌ

គោលនយោបាយសហករណ៍ និងសេចក្ដីណែនាំដែលធ្វើឡើងដោយមជ្ឈិមបក្ស។

[១១:០៥:០៨]

ដូច្នេះ វាមិនបានជាការអនុវត្តនៅតាមមូលដ្ឋាននោះទេ ហើយការអនុវត្តនៅតាមមូលដ្ឋាននោះ គឺថាវាស្ថិតនៅក្នុងក្របខ័ណ្ឌនៃឯកសារគន្លឹះនោះទេ។ ដូច្នេះ ខ្ញុំសូមអន្តរាគមន៍នៅក្នុងដំណាក់កាលនេះ ពីព្រោះថា នៅក្នុងបញ្ជីដែលបានផ្ញើជូនដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនោះ ឯកសារភាគច្រើនពាក់ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលនិយាយអំពីបទពិសោធន៍ នៅតាមមូលដ្ឋាន ហើយនិងការអនុវត្តគោលនយោបាយនៅតាមូលដ្ឋាន។ ដូច្នេះ ឯកសារភាគីច្រើន គឺមិនចូលទៅក្នុងក្របខ័ណ្ឌដែលកំណត់ដោយអង្គជំនុំជម្រះនោះទេ។ នេះជាការយល់តាមការសម្រេច របស់អង្គជំនុំជម្រះកាលពីម្សិលមិញ។ ដូច្នេះខ្ញុំកត់សម្គាល់ជាបឋមនេះ ហើយខ្ញុំមិនដឹងថាតើសហមេធាវីនាំមុខបានកែប្រែបញ្ជីរបស់ខ្លួនទៅតាមការសម្រេចរបស់អង្គជំនុំជម្រះកាលពីម្សិលមិញហើយ ឬក៏នៅទេ។ ដូច្នេះ ខ្ញុំធ្វើការកត់សម្គាល់នេះដើម្បីឲ្យអង្គជំនុំជម្រះដឹងថាមានឯកសារដែលមិនពាក់ព័ន្ធទៅនឹងការសម្រេចរបស់ជំនុំជម្រះ។ យើងដឹងហើយថា យើងនៅក្នុងក្របខ័ណ្ឌនៃសវនាការដែលសច្ចភាពផ្លូវច្បាប់នោះ វាតម្រូវឲ្យយើងគោរពទៅតាមដីកាដំណោះស្រាយ។

ដូច្នេះប្រសិនបើឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីងាកចេញពីអ្វីដែលបានសម្រេចដោយអង្គជំនុំជម្រះ ដែលបានប្រកាសដោយចៅក្រម ឡាវែន៍ នោះ យើងខ្ញុំសូមបដិសេធ។ នេះជាការជម្រាបជូនអង្គជំនុំជម្រះជាមុន។ សូមអរគុណដែលបានផ្ដល់ឱកាសឲ្យយើងខ្ញុំមានមតិ។

[១១:០៦:០៣]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមលើកឡើងបន្ថែមទៅលើសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដី ខៀវ សំផន ហើយក៏ខ្ញុំលើកការសង្កេតផងដែរ។ ប្រហែលជាយើងខ្ញុំលើកឡើងយឺត ជាពិសេសយោបល់របស់ខ្ញុំលើបញ្ហានេះ ក៏ប៉ុន្តែយើងត្រូវតែលើកឡើង។ របៀបដែលសហព្រះរាជអាជ្ញាបង្ហាញឯកសារពាក់ព័ន្ធទៅនឹងគោលនយោបាយទាំងបីពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួមនេះ។ គឺវាអាចឲ្យមានផលប៉ះពាល់ខ្លាំងណាស់ ប្រសិនបើយើងមិនអាចឲ្យយោបល់ទៅលើតម្លៃនៃភស្តុតាងពាក់ព័ន្ធទៅនឹងឯកសារនៃគោលនយោបាយទាំងបី។

យើងខ្ញុំសូមឲ្យមានការណែនាំពីអង្គជំនុំជម្រះ ថាតើយើងខ្ញុំគួរដំណើរការយ៉ាងម៉េច ជាពិសេស

អាចផ្តល់យោបល់ទៅលើតម្លៃនៃភស្តុតាងឯកសារដែលសហព្រះរាជអាជ្ញាលើកឡើងអំពីគោលនយោបាយទាំងបីនោះដែរឬទេ? ដែលគោលនយោបាយទាំងបីនោះមិនមែនជាកម្មវត្ថុនៃរឿងក្តីរបស់យើងផ្អែកលើមូលដ្ឋានឧក្រិដ្ឋកម្មនោះឡើយ។ ចំពោះទួលពោធិ៍ជ្រៃ សហព្រះរាជអាជ្ញាយល់ឃើញថា ការអនុវត្តគោលនយោបាយ។ គោលដៅទៅលើខ្មាំងមុនពេលជម្លៀសប្រជាជនពីក្រុងភ្នំពេញនោះ ក៏គេយល់ឃើញថាជាគោលនយោបាយមួយពាក់ព័ន្ធទៅនឹងបញ្ហាជាក់លាក់នេះ។ ក៏ប៉ុន្តែខ្ញុំសូមលើកឡើងអំពីតម្លៃភស្តុ-តាងនៃឯកសារដែលបង្ហាញដោយសហព្រះរាជអាជ្ញា ជាពិសេសពាក់ព័ន្ធទៅនឹងគោលនយោបាយទាំងបីផ្សេងទៀតដូចដែលបានលើកឡើង។

[១១:០៧:៤៥]

ប្រសិនបើយើងខ្ញុំពុំអាចមានលទ្ធភាពផ្តល់ការយល់ឃើញ យោបល់របស់យើងខ្ញុំលើតម្លៃនៃភស្តុតាងនោះទេ ផលវិបាកនោះគឺថាវាពិបាកនៅពេលដែលអង្គជំនុំជម្រះធ្វើការសម្រេចនូវដំណាក់ចុងក្រោយនៃសំណុំរឿង០០២/០១នេះ។ ដូចដែលខ្ញុំលើកឡើង ខ្ញុំយឺតពេល លើកចំណុចនេះយឺតពេល ក៏ប៉ុន្តែយើងមានការភ័ន្តភាំងទៅលើការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា អំពីគោលនយោបាយទាំងបីនោះ។ ជាពិសេសចំណុចនេះ គឺវាមិនមែនជាមូលដ្ឋាននៃឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង០០២/០១របស់យើងនៅក្នុងសវនាការនេះទេ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ខ្ញុំសូមឆ្លើយតបទៅនឹងការជំទាស់ និងការកត់សម្គាល់របស់មេធាវីការពារក្តីដែលមានលក្ខណៈខុសគ្នា ហើយខ្ញុំគិតថាសហព្រះរាជអាជ្ញាក៏នឹងអាចឆ្លើយតបដែរ។

[១១:០៩:០៧]

ខ្ញុំនឹងពន្យល់អំពីរបៀបធ្វើការរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ យើងខ្ញុំត្រូវបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយទាំងប្រាំដែលបង្កើតបានជាសហឧក្រិដ្ឋកម្មរួម។ គឺអត្ថិភាពទ្រឹស្តី គឺមិនមែនជាការអនុវត្តនោះទេ។ គឺមានន័យថា យើងនឹងមិនចូលលម្អិតទៅនឹងការអនុវត្តនោះទេ។ កាលពីម្សិលមិញ និងម្សិលម្ង៉ៃ ហើយនិងថ្ងៃនេះ សហព្រះរាជអាជ្ញាបានបង្ហាញពីខ្លឹមសារសំខាន់នៃគោលនយោបាយហើយ ហើយនិងគោលគន្លឹះ ហើយនិងកម្មវត្ថុ ឬក៏គោលដៅនៃគោលនយោបាយ ហើយនិងពាក្យពេចន៍ដែលប្រើប្រាស់ដោយអង្គការ ដើម្បីបង្ហាញអំពីគោលនយោបាយទាំងអស់នេះ។

សហព្រះរាជអាជ្ញាបានលើកឡើងលម្អិតរួចមកហើយ ពួកគាត់បានបង្ហាញអំពីឯកសារដែលលើកឡើងអំពីសេចក្តីណែនាំរបស់មជ្ឈិមបក្សដែលមាននៅក្នុងឯកសារមួយចំនួនរបស់អង្គការ។ ចំពោះខាងដើមបណ្តឹងរដ្ឋប្បវេណីយើង យើងនឹងលើកឡើងអំពីសេចក្តីណែនាំដូចគ្នាដែលចេញពីមជ្ឈិមបក្សនិងធាតុផ្សំដែលបង្កើតបានជាគោលនយោបាយទាំងអស់នេះ ក៏ប៉ុន្តែខ្ញុំលើកឡើងនោះគឺតាមរយៈពាក្យពេចន៍ តាមរយៈសម្តី ហើយនិងតាមរយៈការស្តាប់ឮរបស់បុគ្គលមួយចំនួន។ គឺវាពាក់ព័ន្ធទៅនឹងគោលនយោបាយដដែល។ គឺវាមិនពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយទេ។ វាពាក់ព័ន្ធតែអត្ថិភាពនៃគោលនយោបាយ។ ដូច្នេះខ្ញុំនឹងសង្កត់ធ្ងន់ទៅលើទិដ្ឋភាពនេះ។

[១១:១០:៥៥]

ក៏ប៉ុន្តែខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះផងដែរថា ក្នុងសេចក្តីសម្រេចមានសេចក្តីរបស់អង្គជំនុំជម្រះកាលពីម្សិលមិញនេះគឺថាមានចំណុចពីរ នៅម៉ោងប្រាំបួនជាង ចៅក្រម ឡាវែន៍ បានបញ្ជាក់ថាយើងលើកឡើងអំពីសេចក្តីណែនាំរបស់មជ្ឈិមបក្ស យើងអាចលើកឡើងតែសេចក្តីណែនាំរបស់មជ្ឈិមបក្ស។ ចំពោះយើងខ្ញុំនោះ យើងខ្ញុំគិតថាមានសេចក្តីសម្រេចបន្ថែម ជាក់លាក់ ពីព្រោះថាកាលពីម្សិលមិញនេះ សហព្រះរាជអាជ្ញាបានបង្ហាញនូវធាតុផ្សំនៃការអនុវត្តតាមរយៈរបាយការណ៍ តាមរយៈទូរលេខតាមរយៈកំណត់ហេតុកិច្ចប្រជុំនៅតាមមូលដ្ឋាន តាមរយៈបញ្ជីឈ្មោះអ្នកទោស តាមរយៈឧទាហរណ៍ជាក់ស្តែងនៃបុគ្គលដែលត្រូវបានចាប់ខ្លួន ត្រូវបានសម្លាប់ ឬត្រូវបានធ្វើទារុណកម្ម។ ដូច្នេះសហព្រះរាជអាជ្ញាបានប្រើធាតុផ្សំទាំងអស់នេះ គឺខ្លួនមិនមែនចង់បង្ហាញការអនុវត្តគោលនយោបាយនោះទេ គឺគ្រាន់តែបង្ហាញឲ្យឃើញថាការពាក់ព័ន្ធ -- ការអនុវត្តហ្នឹងវាមានភាពពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធយ៉ាងទៅនឹងអត្ថិភាពនៃគោលនយោបាយទាំងអស់នេះ។ ដូច្នេះយើងមិនឃើញមានការជំទាស់ពីខាងមេធាវីការពារក្តីទេនៅពេលសហព្រះរាជអាជ្ញាបង្ហាញឯកសារនោះ។ ហើយអង្គជំនុំជម្រះក៏មិនបានធ្វើអន្តរាគមន៍ក្នុងរយៈពេល២ម៉ោងដែលសហព្រះរាជអាជ្ញាបានប្រើឯកសារទាំងអស់នោះដែរ។

[១១:១២:៣៦]

ដូច្នេះចំពោះយើងខ្ញុំ យើងខ្ញុំយល់ឃើញថាប្រសិនបើខ្ញុំលើកឡើងនូវសម្តី ឬក៏ប្រើប្រាស់នូវឯកសារដោយសារតែយើងមានការលំបាកក្នុងការកាត់ផ្តាច់អត្ថិភាព និងការអនុវត្តគោលនយោបាយនោះខ្ញុំគិតថាវាជាបញ្ហាដូចគ្នាទៅនឹងសហព្រះរាជអាជ្ញាដែលបានលើកឡើងម្សិលមិញ។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាធ្វើដូចម្សិលមិញ គឺអនុញ្ញាតឲ្យអង្គជំនុំជម្រះ -- ឲ្យសហព្រះរាជអាជ្ញាប្រើឯកសារ

ទាំងអស់នោះ។

ដូច្នេះខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះជាមុនថា ការជ្រើសរើសដកស្រង់ឃ្លាណាមួយនោះ គឺថា យើងខ្ញុំមានគោលដៅគ្រាន់តែចង់បង្ហាញអំពីអត្ថិភាពជាទ្រឹះស្ដីនៃគោលនយោបាយទាំងអស់នោះ។ ដូច្នេះ ខ្ញុំគឺសង្កត់ធ្ងន់តែទៅលើអត្ថិភាពតែប៉ុណ្ណោះ។

ច្បាស់ណាស់ថា ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺជួនកាលទៅមានទាំងអត្ថិភាពនៃគោលនយោបាយ មានទាំងការអនុវត្តគោលនយោបាយផងដែរ។ ដូច្នេះ ឃ្លាដែលខ្ញុំនឹងដកស្រង់គឺសុទ្ធសឹងតែជាឃ្លាខ្លីៗ ហើយដែលខ្ញុំនឹងផ្ដោតតែលើអត្ថិភាពប៉ុណ្ណោះ។ ក៏ប៉ុន្ដែជួនកាលទៅ វាអាចមានភាពជាក់ពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធរវាងអត្ថិភាព និងការអនុវត្ត គឺវាដូចជាទៅនឹងករណីដែលសហព្រះរាជអាជ្ញាបានបង្ហាញអីចឹង។

[១១:១៤:១៤]

ខ្ញុំសូមបន្ថែមជាចុងក្រោយថា គោលនយោបាយណាមួយនោះ មិនមែនមានត្រឹមតែការបង្កើតទេ គឺវាមានលក្ខណៈជាប្រព័ន្ធ និងលក្ខណៈទូលំទូលាយ។ នេះគឺជាអាទិភាពនៃគោលនយោបាយ។ ដូច្នេះ ច្បាស់ណាស់ថាជួនកាលទៅ គឺថាដូចសហព្រះរាជអាជ្ញាបានប្រើឯកសារកាលពីម្សិលមិញអីចឹង។ ជួនកាលវាមាន វាបង្ហាញអំពីលក្ខណៈជាប្រព័ន្ធ។ អីចឹងវាអាចពាក់ព័ន្ធទៅនឹងអត្ថិភាពផង និងការអនុវត្តគោលនយោបាយផង។

ដូច្នេះខ្ញុំគិតថា ការជ្រើសរើសយកឃ្លាដកស្រង់មកនោះ គឺថាវាស្ថិតនៅក្នុងក្របខ័ណ្ឌដែលអនុញ្ញាតដោយអង្គជំនុំជម្រះ គឺដូចទៅនឹងអ្វីដែលសហព្រះរាជអាជ្ញាបានធ្វើពីម្សិលមិញអីចឹង។ ខ្ញុំក៏សូមអនុញ្ញាតធ្វើដូចគ្នាដែរដូចសហព្រះអាជ្ញាកាលពីម្សិលម្ង៉ៃ ម្សិលមិញ និងថ្ងៃនេះ គឺថាសុំកុំឲ្យមានការរឹតត្បិតចំពោះយើងខ្ញុំ ពីព្រោះថាសហព្រះរាជអាជ្ញាបានធ្វើរួចមកហើយ។ ដូច្នេះកុំឲ្យមានការរឹតត្បិតចំពោះយើងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១១:១៥:៣៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាក្នុងសវនាការនេះ យើងដឹងច្បាស់ណាស់ថា យើងបង្ហាញ

អំពីឯកសារដែលពាក់ព័ន្ធទៅនឹងអត្ថិភាពនៃគោលនយោបាយ គឺថាខ្ញុំត្រូវតែនិយាយឡើងវិញ។ គឺថាជាគោលនយោបាយដែលផ្សព្វផ្សាយ -- មិនផ្សព្វផ្សាយទៅដល់មូលដ្ឋានទេ គឺថាវាជាគោលនយោបាយជាលក្ខណៈទ្រឹស្តីដែលបង្កើតឡើងដោយមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា។ ក៏ប៉ុន្តែត្រង់ចំណុចនេះ គឺថាអង្គជំនុំជម្រះមិនចង់បាននោះទេ អ្វីដែលយើងចង់បាននោះគឺថា ជាសេចក្តីណែនាំដែលត្រូវបានធ្វើឡើង និងផ្សព្វផ្សាយដែលត្រូវតែអនុវត្ត។ ទី២ គោលនយោបាយដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ដូចដែលខ្ញុំបានបញ្ជាក់កាលពីម្សិលមិញអ៊ីចឹង គឺថាមិនមានកាលបរិច្ឆេទច្បាស់លាស់ទេ គឺថាមានការវិវត្តនទៅមុខ ហើយជួនកាលទៅមានសេចក្តីលម្អិតដែលមិនមានគ្រោងនៅពេលដំបូងនោះទេ ដោយសារតែវាមានការវិវត្តន៍។ ដូច្នេះមានសេចក្តីណែនាំបន្ថែមពាក់ព័ន្ធទៅនឹងគោលនយោបាយដែលបានបង្កើតឡើងពីដំបូង ដែលបានបញ្ជូនទៅកាន់មូលដ្ឋាន។

[១១:១៧:០៥]

ហេតុអ្វីបានជាមានការវិវត្តន៍នៃគោលនយោបាយ? ពីព្រោះថាវាមានភាពទាក់ទងគ្នាទៅវិញទៅមករវាងមេដឹកនាំមជ្ឈិមបក្ស និងទំនាក់ទំនង -- និងរបាយការណ៍ដែលចេញមកអំពីមូលដ្ឋាន។ របាយ-ការណ៍នេះពាក់ព័ន្ធនឹងការអនុវត្ត ក៏ប៉ុន្តែវាជួយឲ្យមានការអភិវឌ្ឍគោលនយោបាយ ហើយនិងឲ្យមានចំណុចរបត់ផ្សេងទៀត។ ដូច្នេះចំពោះខ្ញុំ វាមានការទាក់ទងគ្នាទៅវិញទៅមកទាំងស្រុងរវាងគោលនយោបាយផ្ទាល់ និងការអនុវត្តគោលនយោបាយគោលនយោបាយទាំងអស់នោះ។ ហើយការអនុវត្តគោលនយោបាយទាំងអស់ វាអាចឲ្យគោលនយោបាយទាំងអស់នោះមានការអភិវឌ្ឍ។ នេះគឺជាគោលនយោបាយដែលមានលក្ខណៈជាក់ស្តែង។

ទី៣ អត្ថិភាពនៃគោលនយោបាយទាំងអស់នេះអាចមានលក្ខណៈផ្សេងគ្នា ខ្ញុំនិយាយតែពីអត្ថិភាពទេ ខ្ញុំមិននិយាយពីការវិវត្តន៍ ការអនុវត្តនោះទេ។ ដូចឯកសារមជ្ឈិមបក្សបានបង្ហាញអ៊ីចឹង គឺថាយើងឃើញថាមានសេចក្តីណែនាំជាផ្លូវការរបស់បក្សដែលមានបង្ហាញនៅក្នុងទង់បដិវត្ត នៅក្នុងកំណត់ហេតុកិច្ចប្រជុំ នៅក្នុងរបាយការណ៍ នៅក្នុងទូរលេខ នៅក្នុងសេចក្តីប្រកាសរបស់មេដឹកនាំ នៅក្នុងសុន្ទរកថា ដើម្បីបង្ហាញថាពិតជាមានគោលនយោបាយមែន ហើយពិតជាមានការផ្សព្វផ្សាយមែន ហើយគោលនយោបាយទាំងអស់នោះត្រូវតែអនុវត្តជាដាច់ខាត។

[១១:១៨:៣៦]

ដូច្នេះ យើងមិនមែនបង្ហាញពីគោលនយោបាយពីខាងលើទេ គឺថាគឺជាការអនុវត្តពីថ្នាក់ក្រោម។

ហើយសេចក្តីសម្រេចរបស់តុលាការអន្តរជាតិនោះអាចទទួលយកបានថាវាអាចកម្រិតត្រឹមអាកប្បកិរិ-យាដែលមានលក្ខណ:ដូចគ្នា ហើយនិងអនុវត្តជាទូទៅនៅតាមមូលដ្ឋាន ដែលបង្ហាញថាពិតជាមានគោលនយោបាយនៅថ្នាក់ជាតិមែន ដើម្បីឱ្យអនុវត្តនៅគ្រប់កន្លែងទាំងអស់នៅក្នុងពេលតែមួយដែលមានការផ្សព្វផ្សាយទៅដល់បុគ្គល។

មានការ -- មានសេចក្តីសម្រេចរបស់ គូណារ: ដែលជាការប្តឹងឧទ្ធរណ៍នៅចំពោះមុខតុលាការសម្រាប់អតីតយូហ្គោស្លាវី គឺកថាខណ្ឌ៩៨ ហើយក៏មានសេចក្តីសម្រេចរបស់ ប្លាកូស៊ីវិក គឺសាលក្រមរបស់សាលាដំបូង គឺកថាខណ្ឌ៧២ -- ៧២១ (សូមទោស)។ ខ្ញុំមិនមានអត្ថបទជាភាសាបារាំងនៅចំពោះមុខទេ។

អង្គជំនុំជម្រះយល់រកឃើញថាភស្តុតាងនៃការប្រព្រឹត្តរួមគ្នាក្នុងការសម្លាប់រង្គាល តាមរយ:ការចាប់ខ្លួន ឃុំខ្លួន និងសម្លាប់ព្រមទាំងកម្មេចទៅលើមនុស្សដែលជាជនជាតិម៉ូស្លីម បូស្នៀរជាង ៧០០០នាក់។ ហើយវត្តមាននៃផែនការទាំងអស់នេះក្នុងការសម្លាប់ប្រជាជនទាំងបុរសស្ត្រី ជាង៧.០០០នាក់នោះគឺគ្រោងធ្វើឡើងក្នុងរយ:ពេលត្រឹមតែ៥ថ្ងៃ។ ដូច្នេះហើយផែនការនេះគឺមិនអាចធ្វើទៅបានទេប្រសិនបើគ្មានការរួមសហការពីសមាជិកដែលជាសហឧក្រិដ្ឋកម្មរួម។

[១១:២០:៣៨]

ដូច្នេះនេះ ដើម្បីផ្តល់ឧទាហរណ៍ ជាភស្តុតាងជូនអង្គជំនុំជម្រះដែលបង្ហាញអំពីការពិតនៅថ្នាក់មូលដ្ឋាន។ របៀបបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយនេះគឺថា គឺរួមផ្សំគ្នាថា មានគោលនយោបាយនៅក្នុងឯកសាររបស់មជ្ឈិមបក្សដែលបង្កើតគោលនយោបាយដើម្បីឱ្យយើងសន្និដ្ឋានថាមានគោលនយោ-បាយនៅក្នុងសុន្ទរកថានៅក្នុងឯកសាររបស់បក្សនានា ហើយនិងដើម្បីបង្ហាញគោលនយោបាយទាំងអស់នេះតាមរយ:ការដែលថាមាននៅក្នុងមូលដ្ឋានហើយនឹងត្រូវបានអនុវត្តជាទូទៅនៅគ្រប់កន្លែង។ ដូច្នេះ ខ្ញុំមិនគិតថាដើមបណ្តឹងរដ្ឋប្បវេណីគាត់មានចេតនាទៅផុតពីនេះទេ គឺគាត់គ្រាន់តែចង់បង្ហាញអត្ថិភាពនៃគោលនយោបាយ ក៏ប៉ុន្តែតាមរបៀបផ្សេងពីយើង ពីអ្វីដែលយើងបានធ្វើកាលពីប៉ុន្មានថ្ងៃកន្លងមកនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

[១១:២១:៤៧]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន នេះជាអ្វីដែលខ្ញុំព្យាយាមជំទាស់ហើយ -- ព្យាយាមចៀសវាងហើយនៅពេលដែលខ្ញុំជំទាស់កាលពីម្សិលមិញនិងម្សិលម៉្ងៃនោះ គឺថាយើងងាកចេញយ៉ាងប៉ិនប្រសព្វទៅកាន់សវនាការផ្សេងទៀតហើយ។ នេះគឺជាចំណុចច្បាស់លាស់ណាស់។ យើងតែងតែនិយាយជានិច្ចនៅចំពោះមុខអង្គជំនុំជម្រះថា កង្វល់របស់យើងតែមួយគត់នោះគឺថា គឺយើងអាចការពារកូនក្តីរបស់យើងឲ្យបានត្រឹមត្រូវដោយដឹងច្បាស់ថាទោះជានៅក្នុងសំណុំរឿង ០០២/០១ ឬក៏សំណុំរឿង ០០២/០២ - /០៣ នោះយើងដឹងថាតើយើងត្រូវឆ្លើយតបទៅនឹងអ្វីឲ្យបានច្បាស់លាស់។ ដូច្នេះជាក់ស្តែងនៅថ្ងៃនេះ អ្វីដែលសហព្រះរាជអាជ្ញា ហើយនិងតំណាងដើមបណ្តឹងរដ្ឋប្បវេណីនិយាយនោះគឺថា យើងមិនអាចនិយាយអំពីគោលនយោបាយបីផ្សេងទៀតដែលមិនពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ នេះ ដោយមិននិយាយអំពីការអនុវត្តនៅតាមមូលដ្ឋាននោះទេ។ អ៊ីចឹងតាមផ្លូវច្បាប់ តើមានន័យយ៉ាងម៉េចអ្វីដែលពួកគាត់បានលើកឡើងនោះ? មានន័យថា អង្គជំនុំជម្រះអនុញ្ញាតឲ្យមានការបង្ហាញឯកសារបន្ត ស្តីអំពីគោលនយោបាយដែលវាមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០២/០១នោះ មានន័យថាភស្តុតាងមួយចំនួនមិនត្រូវស្ថិតនៅក្នុងកម្មវត្ថុនៃសំណុំរឿង ០០២/០១នេះ ដោយមិនដាក់ឲ្យអង្គជំនុំជម្រះវាយតម្លៃ។

[១១:២៣:៣៦]

ដូច្នេះ ចំពោះយើង យើងមិនមានភស្តុតាងតាមរយៈសាក្សីដែលមកផ្តល់សក្ខីកម្ម យើងមិនអាចចោទសួរពួកគាត់បានអំពីចំណុចទាំងអស់នេះទេ។ គឺថាពេលដែលមកនោះយើងមិនអាចពង្រីកទៅលើចំណុចទាំងអស់ហ្នឹងទេ។ ហើយនៅក្នុងសារណាបញ្ចប់របស់យើង ក៏យើងមិនអាចនិយាយទៅដល់គោលនយោបាយដែលមិនពាក់ព័ន្ធនឹងសវនាការរបស់យើងនេះដែរ។ ដូច្នេះតើឲ្យខ្ញុំការពារកូនក្តី ការពារជនជាប់ចោទយ៉ាងម៉េចកើត ប្រសិនបើយើងត្រូវឆ្លើយទៅនឹងបញ្ហាដែលកំណត់ដោយអង្គជំនុំជម្រះផង ហើយនិងកំណត់ដោយសវនាការផ្សេងផង។ ដូច្នេះ ខ្ញុំគិតថាការដែលខ្ញុំធ្វើការជំទាស់បែបនេះគឺថាដើម្បីចៀសវាងកុំឲ្យមានបញ្ហា ពីព្រោះថានៅក្នុងសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ហើយនិងនៅក្នុងឧបសម្ព័ន្ធដែលខ្ញុំបានលើកឡើងកាលពីថ្ងៃចន្ទ ដែលអង្គជំនុំជម្រះយោងទៅលើសេចក្តីសម្រេចរបស់ខ្លួនE284 គឺថាបានអង្គជំនុំជម្រះសម្រេចច្បាស់ណាស់គឺថានិយាយតែអំពីទួលពោធិ៍ជ្រៃ ហើយនិងការជម្លៀសប្រជាជនដោយបង្ខំ។ ដូច្នេះគឺថានៅពេលដែលយើងនិយាយអំពីទម្រង់នៃការទទួលខុសត្រូវគឺត្រូវតែនៅក្នុងក្របខ័ណ្ឌដែលកំណត់ដោយអង្គជំនុំជម្រះ។ នេះជាការលំបាកដែលយើងជួបប្រទះហើយ។

[១១:២៥:០៥]

ខ្ញុំ-- គឺថាខ្ញុំមិនចង់ងើបឡើងម្តង៥នាទីម្តងមកជំទាស់បែបនេះទេ។ ដូច្នេះ ខ្ញុំសូមឲ្យ -- ខ្ញុំសូមនិយាយយឺតៗដើម្បីបកប្រែកាន់តែមានលក្ខណៈច្បាស់លាស់។ មិនមែនដោយសារតែថាខ្ញុំមិនងើបឡើងជំទាស់នោះ -- ហើយមូលហេតុនៃការជំទាស់របស់ខ្ញុំមិនទៅដដែលទេ គឺថាខ្ញុំនៅតែរក្សាការជំទាស់ដដែល។ ចំពោះយើងៗគិតថា សវនាការនេះគឺថាការជំនុំជម្រះក្តីនេះមិនមានយុត្តិធម៌ទេ ពីព្រោះថាវាងាកចេញអំពីក្របខ័ណ្ឌដែលកំណត់នៅក្នុងសំណុំរឿង០០២/០១ ហើយបន្ទាប់មក តើយើងចេញទៅនិយាយអំពីអ្វីជាកម្មវត្ថុនៃសវនាការ ០០២/០២ ឬ០៣ នៅពេលក្រោយទៀតនោះ។ ដូច្នេះដើម្បីគោល -- សម្រាប់បញ្ហានេះហើយដែលកើតឡើង ប្រសិនបើយើងនិយាយអំពីអង្គហេតុដែលអង្គជំនុំជម្រះមិនបានកំណត់នៅក្នុងដីកាស្តីពីការបំបែកនីតិវិធីនោះទេ។ ប្រសិនបើយើងនិយាយអំពីអង្គហេតុដែលមិនពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចបំបែកនីតិវិធីនោះទេ យើងនឹងមានបញ្ហានៅក្នុងការជំនុំជម្រះក្តីនៅពេលខាងមុខទៀត។ ដូច្នេះនេះជាការបង្កបញ្ហាហើយ។

ដូច្នេះយើងឃើញហើយថា សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីគាត់បង្ហាញឯកសារខុសពីអ្វីដែលយើងបានកំណត់។ គាត់បានបញ្ជាក់ថាគាត់បានបង្ហាញអំពីការអនុវត្ត និងអំពីអត្ថិភាពដោយសារតែវាជាប់ពាក់ព័ន្ធគ្នា។ ដូច្នេះ ខ្ញុំគិតថាអ្វីដែលគាត់លើកឡើងនេះ គឺថាយើងត្រូវតែពិភាក្សាគ្នានៅក្នុងសវនាការ នៅក្នុងការជំនុំជម្រះក្តីលើកក្រោយទៀតនោះទេ។ ព្រោះថាវាខុសពីអ្វីដែលយើងបានកំណត់ជាមុនហើយ។

[១១:២៦:៥៦]

អ៊ីចឹង បើសិនជាយើងអត់អនុវត្តអ៊ីចឹងដដែល តើយើងធ្វើ -- យើងចេញសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីធ្វើអី បើយើងយកអង្គហេតុមកបូកច្របូកច្របល់គ្នាបែបនេះនោះ ហើយយើងខ្ញុំក៏មិនដឹងថាឆ្លើយតបយ៉ាងម៉េចដែរ។ ដូច្នេះ ខ្ញុំសូមឲ្យអង្គជំនុំជម្រះគិតពិចារណាទៅលើចំណុចនេះ ពីព្រោះថា នេះវាមិនចំណុចដែលយើងត្រូវធ្វេសប្រហែសនោះទេ។ នេះជាចំណុចដែលយើងកំណត់នៅក្នុងសំណុំរឿងរបស់យើង។ ខ្ញុំសូមរំឭកថា នៅពេលដែលអង្គជំនុំជម្រះផ្តល់ជូនវេទិកាទៅដល់សហមេធាវីការពារក្តី ខៀវ សំផន នេះ គឺថាយើងចង់ដឹងថាតើយើងត្រូវឆ្លើយតបទៅនឹងអ្វីឲ្យបានពិតប្រាកដ? ប្រសិនបើមានការងាកចេញទៅរកគោលនយោបាយផ្សេងទៀតនោះ។ យើងគិតថា ការជំនុំជម្រះក្តីនេះមិនយុត្តិធម៌ទេ។ យើងមិនអាចឆ្លើយតបបានទេ។ ដូច្នេះ សិទ្ធិរបស់ជនជាប់ចោទនោះ ត្រូវដឹងថា តើត្រូវ

ឆ្លើយទៅនឹងអ្វី? ដូច្នេះនៅពេលដែលមានការងាកចេញពីគោលនយោបាយមួយ ទៅគោលនយោបាយមួយផ្សេងទៀតបែបនេះហ្នឹង គឺថាយើងពិបាកធ្វើការណាស់។ អ៊ីចឹងការជំនុំជម្រះក្តីយើងនេះ គឺមិនមានយុត្តិធម៌ទេ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ដដែលថា យើងមិនអាចឲ្យមានការងាកចេញបែបនេះទេ។ បើសិនជាងាកចេញបែបនេះនោះ ការសម្រេចស្តីពីការបំបែកនីតិវិធីនោះ គ្មានន័យ គ្មានខ្លឹមសារអ្វីទេ។

[១១:២៨:១០]

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន! ដើម្បីជាប្រតិចារឹក ខ្ញុំសូមគាំទ្រការលើកឡើងរបស់មេធាវីការពារក្តី ខៀវ សំផន។ យើងកាលពីម្សិលមិញនេះនិងថ្ងៃនេះ យើងមិនមែននិយាយអំពីគោលនយោបាយរួមទេ គឺនិយាយអំពីគោលនយោបាយពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម។ ដូចដែលខ្ញុំបញ្ជាក់ពីខាងដើមកូនក្តីរបស់ខ្ញុំមិនត្រូវបានចោទប្រកាន់នៅក្នុងវគ្គសវនាការនេះ អំពីបទចោទពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ រួមទាំងការអនុវត្តផែនការណាមួយក្នុងចំណោមផែនការទាំងប្រាំ។

ដូច្នេះ យើងជួបប្រទះបញ្ហានៅពេលនេះ ប្រសិនបើ ដូចដែលមេធាវីការពារក្តីអ៊ីចឹងលើកឡើងថា បើសិនជាយើងចូលទៅដល់បញ្ហាគោលនយោបាយដូចដែលខ្ញុំលើកឡើងអ៊ីចឹង គឺថាយើងគ្មានលទ្ធភាពណាមួយអាចការពារខ្លួនបាននោះទេ។

ជាថ្មីម្តងទៀត យើងយល់អំពីផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធីនេះ។ បញ្ហាពីរដែលវាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនោះ គឺថាយើងមិនជំទាស់ដោយសារតែវាពាក់ព័ន្ធទៅនឹងមន្ត្រីរដ្ឋការ លន់ នល់ និងទាហាន លន់ នល់ ហើយវាពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃ ទើបខ្ញុំមិនជំទាស់។ ក៏ប៉ុន្តែនៅពេលនេះ យើងនិយាយអំពីការរៀបការដោយបង្ខំ វាមិនពាក់ព័ន្ធនៅក្នុងដំណាក់កាលសំណុំរឿង ០០២/០១ នោះទេ។ ដូច្នេះ ថាតើយើងធ្វើការដោះស្រាយយ៉ាងម៉េចទៅនឹងភាពដែលអាចមានលម្អៀងនៅក្នុងនេះដែលវាកើតចេញពីផលវិបាក អនុញ្ញាតឲ្យមានការលើកឡើងអំពីការអនុវត្តគោលនោបាយនេះ។

[១១:២៩:៥៩]

នៅពេលនេះ យើងស្ថិតនៅក្នុងស្ថានភាពមួយដែលមានការលំបាក។ យើងខ្ញុំយល់ឃើញថា ផលវិបាក -- យើងយល់អំពីផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធី ក៏ប៉ុន្តែនៅពេលនេះវាបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់។ ប្រសិនបើយើងលើកឡើងអំពីគោលនយោបាយអនុវត្តផែនការទាំងបី ហើយយើងមិនឲ្យ -- យើងលើកឡើងអំពីភស្តុតាងទាំងអស់នេះ យើងនឹងមានបញ្ហានៅក្នុងវគ្គសវនាការយើង

នាពេលនេះ។

**ប្រធានអង្គជំនុំ៖**

មានបញ្ហាថ្មីទេ? ឬក៏បញ្ហាដដែល ព្រោះបញ្ហាដដែលយើងបានជំទាស់តវ៉ា គឺលើកឡើងតែម្តងទេ លោកតំណាងសហព្រះរាជអាជ្ញា។ បើពុំដូច្នេះទេយើងមិនអាចដោះស្រាយបញ្ហានេះបានទេ។

លោកតំណាងសហព្រះរាជអាជ្ញាយល់ទេ? បើមានបញ្ហាដដែល គឺអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកលើកទៀតទេ ពីព្រោះអង្គជំនុំជម្រះបានជម្រាបហើយការតបទៅនឹងការលើកឡើងរបស់ភាគីម្ខាងទៀត ភាគីម្ខាងហ្នឹងលើកបានតែម្តងទេ។

**លោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមត្រឡប់លើកមកនិយាយអំពីបញ្ហានេះតែ៣០*សេហ្គុង* ទេ លោកប្រធាន។ ឆ្លើយតបទៅនឹងចម្លើយរបស់ខាងការពារក្តីលោកប្រធាន តែ៣០វិនាទីទេលោកប្រធាន។ លោកប្រធានអនុញ្ញាតឲ្យខ្ញុំលើកឡើងទេលោកប្រធាន?

[១១:៣១:៣០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញរយៈពេលខ្លីណោះ! ដើម្បីឲ្យជ្រះស្រឡះទៅបញ្ហានេះ ខំស្អុតស្នាញជារៀងរាល់ថ្ងៃដូច្នេះ។

**លោក វាំងសង់ វ៉ាយជ៍ ដេស្មាឯល៖**

បាទ លោកប្រធានខ្ញុំគ្រាន់តែចង់និយាយថា ជាច្រើនខែមកហើយដែលភាគីទាំងអស់ដឹងថាការបង្ហាញឯកសារនេះនឹងកើតមានឡើងនៅពេលណាមួយ។ ហើយយើងតែងតែនិយាយថា យើងនឹងបង្ហាញឯកសារនេះលើគោលនយោបាយទាំងប្រាំ ដូចដែលមាននៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦ ទៅដល់១៥៩។ បញ្ហាដែលយើងពិភាក្សាគ្នានៅពេលនេះ គឺអំពីរបៀបបង្ហាញអត្ថិភាពនៃគោលនយោបាយទាំងអស់នោះ។ យើងមិនចង់ឲ្យតុលាការពន្លាតសំណុំរឿង០០២/០១នេះទេ លោកប្រធាន។

[១១:៣២:២៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៨:២២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីសម្រេចលើ

សេចក្តីជំទាស់តវ៉ារបស់ភាគីមេធាវីការពារក្តី ចំពោះបញ្ហាដែលបានលើកឡើងអម្បាញ់មិញនេះ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះទទួលស្គាល់ថាឯកសារដែលភាគីមានបំណងចង់លើកឡើងគួសបញ្ជាក់ក្នុងពេលធ្វើសវនាការលើឯកសារគន្លឹះទាំងអស់នេះ ឯកសារហ្នឹងវាអាចមានចំណុចពាក់ព័ន្ធទៅនឹងអត្ថិភាព ឬក៏ការបង្កើតនូវគោលនយោបាយ និងការអនុវត្តគោលនយោបាយទាំងអស់នោះ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសូមធ្វើការគូសបញ្ជាក់ថា ភាគីមានសិទ្ធិផ្តល់យោបល់ទៅលើគ្រប់ទិដ្ឋភាពនៃឯកសារទាំងឡាយដែលបានលើកឡើងនៅក្នុងសវនាការនេះ។ ជាពិសេសលើកឡើងអំពីភាពពាក់ព័ន្ធ និងតម្លៃនៃភស្តុតាងឯកសារ។

[១១:៣៩:៤៥]

អង្គជំនុំជម្រះនឹងធ្វើការសម្រេចលើបញ្ហាតម្លៃនៃភស្តុតាងក្នុងពេលរៀបចំសាលក្រម។ អង្គជំនុំជម្រះសូមបញ្ជាក់ផងដែរថាសំណុំរឿង០០២/០១ រួមបញ្ចូលគោលនយោបាយដែលពាក់ព័ន្ធទៅនឹងគោលនយោបាយដែលមានអត្ថិភាព និងបានបង្កើតឡើងតែប៉ុណ្ណោះ។ ហើយនិងការអនុវត្តគោលនយោបាយជម្លៀសទីក្រុង គឺមិនពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះឡើយ។ លោកប្រធាន ខ្ញុំមើលគិតថាការលើកឡើងរបស់ខ្ញុំនេះ គឺវាផ្តោតខ្លឹមសាររួមនៃការណែនាំរបស់យើងរួចហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។ បាទជាបន្តផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធជាមួយនឹងអង្គហេតុសហឧក្រិដ្ឋកម្មរួម។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ដូចជាទម្លាប់ ខ្ញុំសូមអានសម្រង់ខ្លីៗទេ ហើយខ្ញុំមិនបញ្ចាំងលើអេក្រង់ទេ ប៉ុន្តែខ្ញុំឱ្យលេខ ERN រាល់ដង។ ដូច្នេះ ខ្ញុំសូមចាប់ផ្តើមជាមួយគោលនយោបាយនៃការបង្កើតសហករណ៍ ហើយនិងជំរំការងារ។ ជាបឋមខ្ញុំសូមសង្កត់ធ្ងន់ទៅលើអ្វីដែលកំណត់ជាក់លាក់ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាកាលពីម្សិលមិញ។ ឧទាហរណ៍ដូចទាក់ទងទៅនឹងការបង្កើនផលិតកម្មស្បៀងអាហារមួយចំនួន។

[១១:៤២:០០]

ខ្ញុំសូមលើកយកឯកសារមួយ D22/1002, ERN ជាភាសាបារាំងគឺ 0086166 -- 68 (បាទ សូមទោស), អង់គ្លេស 00839950, ERN ជាភាសាខ្មែរគឺ 00518426។ ដើមបណ្ដឹងរដ្ឋប្បវេណីកាលនោះគាត់នៅកំពង់ស្ពឺ។ គាត់បានលើកឡើងថា ខ្ញុំសូមដកស្រង់៖ "នឿន បានឲ្យខ្ញុំធ្វើការនៅក្នុងស្រែ ហើយលើកហ្នឹង ខ្ញុំត្រូវស្ទូងនៅក្នុងថ្នាល។ មិត្តនឿន បង្ខំឲ្យខ្ញុំស្ទូងឲ្យបាន១២០កណ្ដាប់ក្នុងមួយថ្ងៃ។ បើសិនជាអ្នកណាម្នាក់មិនអាចធ្វើបាន របបបបរនឹងត្រូវកាត់បន្ថយ។ នៅក្នុងករណីនេះ ខ្ញុំក៏ដូចជាប្រជាជនដទៃទៀតដែរ។ យើងបង្ខំចិត្តធ្វើការគ្មានឈប់ឈរ"។ ក្រោមហ្នឹងបន្តិចគាត់និយាយបន្តទៀតថា នៅក្រុមរបបហ្នឹងមានពាក្យស្លោកមួយដែលនិយាយថា "ទុកមិនចំណេញ ដកចេញមិនខាត"។ នេះខ្ញុំលើកឡើងអំពីពាក្យពេចន៍របស់ខ្មែរក្រហមដែលគាត់និយាយទៅកាន់ប្រជាជននៅសម័យនុ៎ង--

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនបាទ! សូមអញ្ជើញមានការជំទាស់តវ៉ាពីក្រុមមេធាវីការពារក្ដី។

សូមអញ្ជើញលោកស្រីមេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន! ត្រង់ចំណុចនេះ ការដកស្រង់ផ្នែកដំបូងនៃសហភាតារបស់ខ្ញុំទាក់ទងទៅនឹងការបង្កើតគោលនយោបាយនេះ ពុំមានទាក់ទងអ្វីនឹងគោលនយោបាយទេ បើសិនជាគាត់បាននិយាយត្រឹមតែថាពាក្យ លើកឡើងពាក្យស្លោកនោះ ខ្ញុំមិនជំទាស់ទេ។ ក៏ប៉ុន្តែ ដល់តែអានផ្នែកមួយចំនួនដែលមិនទាក់ទងទៅនឹងគោលនយោបាយនោះ -- ខ្ញុំគាំទ្រសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ហើយប៉ុន្តែទោះជាយ៉ាងណាក្ដី បើសិនជាគ្រាន់តែចង់លើកពីពាក្យស្លោកហ្នឹងនោះបានហើយ ក៏ប៉ុន្តែមិនត្រូវលើកឡើងអំពីការអនុវត្ត ឬក៏របៀបស្ទូងសំណាបអ្វីនោះទេ។ អានេះមិនមានទាក់ទងអ្វីនឹងគោលនយោបាយដែលយើងបានលើកឡើងអំបាញ់មិញនេះទេ។ ឧទាហរណ៍ដូចថាជាសេចក្ដីណែនាំរបស់មជ្ឈិមបក្សអីជាដើមនេះ។

[១១:៤៥:២៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានខ្ញុំគ្រាន់តែដកស្រង់សម្រង់មួយដែលមាននិយាយថា ខ្មែរក្រហមម្នាក់បង្ខំឲ្យផលិតឲ្យបានបរិមាណណាមួយ។ នេះគឺជាការឆ្លុះបញ្ចាំងអំពីគោលនយោបាយដែលគេដាក់ទៅឲ្យអនុវត្តក្នុងតំបន់មួយ។ នេះជាគោលនយោបាយ អ៊ីចឹងអ្នកឯងត្រូវតែធ្វើឲ្យបានស្ទូងឲ្យបាន១២០ កណ្ដាប់ក្នុង១ថ្ងៃ

ប្រសិនបើអ្នកឯងធ្វើមិនបានទេ គឺថាកាត់បន្ថយរបបបបរ។ នេះគឺជាពាក្យពេចន៍របស់កម្មាភិ បាលថ្នាក់ទាបដែលប្រហែលជាអនុវត្តគោលនយោបាយដែលដាក់ចេញពីមជ្ឈិមបក្សលោកប្រធាន។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធានខ្ញុំសូមអនុញ្ញាតឆ្លើយ។ ក៏ប៉ុន្តែឥឡូវនេះវាដូចជាពស់ខាំកន្ទុយខ្លួនឯងអ៊ីចឹងឯង។ បើយើងថាដើម្បីបង្ហាញពីអត្ថិភាពនៃគោលនយោបាយនោះតាមរយៈការអនុវត្តនេះគឺថា នេះវាប្រាសចាកពីសេចក្តីសម្រេចរបស់តុលាការហើយ បើចង់និយាយថាតើសេចក្តីសម្រេចហ្នឹងមិនអាចអនុវត្តបាន ឬក៏យ៉ាងម៉េច? យើងចង់និយាយថាការអនុវត្តគោលនយោបាយនេះវាជាភស្តុតាងនៃអត្ថិភាពនៃគោលនយោបាយនេះ។ អ៊ីចឹងយើងត្រូវតែនិយាយទាំងពីរបញ្ចូលគ្នាតែម្តងទៅ ហើយវាពេលនេះវាខុសពីវិសាលភាពសំណុំរឿងយើងនេះហើយ។ អ៊ីចឹងត្រូវលើកមកនិយាយទាំងអស់ទៅ បើមិនអ៊ីចឹងទេវាមានភាពចម្រូងចម្រាសហើយ។ មិនមានភាពសមហេតុផលសមផលទេ ដែលក្នុងការដែលយើងត្រូវរឹតត្បិតថាមកនិយាយត្រឹមតែថា គោលនយោបាយ អត្ថិភពនៃគោលនយោបាយ ហើយមិននិយាយពីការអនុវត្ត។ ត្រូវនិយាយទាំងពីរតែម្តង។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៧:៥០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីការពារក្តីអន្តរជាតិលោក ខៀវ សំផន មិនត្រឹមត្រូវទេ។ នេះស្ថិតនៅក្នុងវិសាលភាពដែលអង្គជំនុំជម្រះបានណែនាំរួចហើយអម្បាញ់មិញនេះ អំពីគោលនយោបាយនិងពាក់ព័ន្ធនឹងការអនុវត្តក្នុងក្របខ័ណ្ឌដែលអង្គជំនុំជម្រះបានណែនាំ ទី១។ ទី២ សូមឲ្យមេធាវីការពារក្តីទុកពេលវេលាសមស្របដែលអង្គជំនុំជម្រះផ្តល់ជូនទៅភាគីការពារក្តីធ្វើការអត្ថាធិប្បាយ រួចធ្វើការកត់សម្គាល់នៅពេលចុងក្រោយ បន្ទាប់ពីការបញ្ចប់នូវការដាក់បង្ហាញឯកសារគន្លឹះនេះទៅគឺអង្គជំនុំជម្រះផ្តល់ភាគីការពារក្តីធ្វើការអត្ថាធិប្បាយធ្វើការកត់សម្គាល់ពាក់ព័ន្ធទៅនឹងភាពយកបាន ជាភស្តុតាង ភាពទទួលយកជាភស្តុតាង ឬក៏តម្លៃនៃភស្តុតាងដែលអង្គជំនុំជម្រះបានណែនាំនៅក្នុងអនុស្សរណៈរបស់ខ្លួនរួចហើយ ចៀសវាងមានការបង្អាក់គ្រប់ពេលវេលាដូច្នេះគឺមិនអាចទៅមុខរួចទេ។ គឺអាចលើកឡើងជារួម ឬក៏លើកឡើងតាមករណីជាក់ស្តែងនៃឯកសារនីមួយៗដែលភាគីខាងចោទប្រកាន់បានដាក់បង្ហាញ នេះ។

សូមតំណាងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្តទៀត!

[១១:៤៩:២០]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមចូលទៅនិយាយពីឯកសារទី២ ដែលជាឯកសារ D22/152 គឺជាចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដដែល ហើយខ្ញុំសូមបញ្ចាក់ភ្លាមតែម្ដង។ ខ្ញុំបង្ហាញតែចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទេលោកប្រធាន។ ERN លេខ-- ឃ្លាដែលខ្ញុំនឹងលើកមកនេះគឺ ERN ជាភាសាបារាំង គឺ 00905152, ERN ជាភាសាអង់គ្លេសគឺ 00414896, ERN ភាសាខ្មែរគឺ 00368784។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់យ៉ាងខ្លីទេ។ ខ្ញុំសូមដកស្រង់៖ “ខ្មែរក្រហមកោះហៅប្រជុំពេលយប់នៅពេលប្រជុំនោះ គេឲ្យសេចក្ដីណែនាំ (បីគោនក្នុងមួយហិចតា...។ល។)”។ សូមបញ្ចប់ការដកស្រង់ត្រឹមនេះលោកប្រធាន។

បន្ទាប់មកទៀតទាក់ទងទៅនឹងការសាងសង់ប្រព័ន្ធស្រោចស្រពនៅក្នុងប្រទេស ហើយសហព្រះរាជអាជ្ញាបានលើកអំពីបញ្ហាពីនេះហើយ ហើយខ្ញុំសូមលើកយកឯកសារ D22/2066, ERN ជាភាសាបារាំង 00894013, ជាភាសាអង់គ្លេសគឺ 00890970 ទៅដល់ 71, ERN ជាភាសាខ្មែរគឺ 00544536។

[១១:៥១:៤២]

ដើមបណ្ដឹងរដ្ឋប្បវេណីនេះកាលណោះជាកុមារទេ កាលដែលកើតរឿងនេះឡើង គាត់បានសរសេរនៅក្នុងចម្លើយសូមតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ គាត់និយាយថា “អ្នកទាំងអស់គ្នាត្រូវបានបង្ខំឲ្យធ្វើលើកភ្លឺស្រែ ហើយនិងជីករណ្ដៅ ហើយពួកគេត្រូវឲ្យចេញពីកន្លែងមួយទៅកន្លែងមួយទៅធ្វើ -- ទៅលើកភ្លឺ ហើយនិងជីករណ្ដៅទៀត”។

ទាក់ទងទៅនឹងការសាងសង់ប្រព័ន្ធស្រោចស្រពដដែលនេះ ខ្ញុំសូមលើកយកឯកសារមួយទៀតគឺឯកសារ E3/1676 គឺជាដើមបណ្ដឹងរដ្ឋប្បវេណីមួយ កាលនោះគាត់នៅក្រចេះ។ លេខ ERN ជាភាសាបារាំងគឺ 00811456, ជាភាសាអង់គ្លេសគឺ 00812379, ជាភាសាខ្មែរគឺ 00496842។

ដើមបណ្ដឹងរដ្ឋប្បវេណីនេះលើកឡើងដូចតទៅនេះ៖ “ខ្មែរក្រហម (ដែលខ្ញុំមិនស្គាល់ឈ្មោះទាំងនោះ) បានឲ្យលើកភ្លឺ ភ្លឺស្រែ ចូលព្រៃកាប់ដើមឈើធំៗ ហើយនិងកាប់គ្រែងដោយចបរ។ ពេលលើកស្រែពួកខ្មែរក្រហមគេតម្រូវ និងដាក់លក្ខខណ្ឌដាច់ខាត គឺ១ថ្ងៃលើកភ្លឺឲ្យបាន៥០ម៉ែត្រ ក្នុង១ថ្ងៃ៥០ម៉ែត្រ។ បើមិនអីចឹងទេនឹងត្រូវបាត់ខ្លួន”។ សូមបញ្ចប់ការដកស្រង់។

[១១:៥៤:០១]

ទាក់ទងនឹងការសាងសង់ប្រព័ន្ធស្រោចស្រពនេះដដែល ខ្ញុំលើកយកឯកសារ D22/1954, ERN ជាភាសាបារាំងគឺ 00540871, ជាភាសាអង់គ្លេសគឺ 00853159, ជាភាសាខ្មែរគឺ 00555779។ ដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងតូចទៅនេះ ខ្ញុំសូមដកស្រង់ "គេដកយកស្រូវមួយផ្នែកបន្ទាប់ពីរដូវចម្រូតប្រមូលស្រូវ អ្នកដែលនៅលីវ អ្នកដែលមានកម្លាំងត្រូវបញ្ជូនទៅធ្វើការងារលើកទំនប់ ហើយនិងជីកប្រឡាយទឹក។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំនោះលោក ពុង បានសង្កេតឃើញថា ការងារហ្នឹងកើតឡើងជាប់ជាលំដាប់ ហើយចំណែករបបអាហារវិញកាន់តែចុះទៅៗ។ ពីដើមប្រជាជនស្ម័គ្រចិត្តធ្វើការដើម្បីកសាងប្រទេសជាតិ ប៉ុន្តែធាតុពិតនៃការរួមចំណែករបស់ពួកគេ ស្ថិតនៅក្នុងភាពស្រពេចស្រពិលអស់រយៈពេលជាច្រើនឆ្នាំ"។

ខ្ញុំសូម -- ទាក់ទងទៅនឹងបញ្ហាការសាងសង់ប្រព័ន្ធស្រោចស្រពដដែលនេះ ខ្ញុំសូមលើកយកឯកសាមួយទៀត គឺឯកសារ D22/195។ ERN ជាភាសាបារាំងគឺ 00898049 ហើយ ERN ជាភាសាអង់គ្លេសគឺ 00434305 ទៅដល់ 06, ERN ជាភាសាខ្មែរគឺ 00397780 ទៅ 81។

[១១:៥៦:១៣]

ដើមបណ្តឹងរដ្ឋប្បវេណីនៅស្វាយរៀងពេលដែលកើតហេតុនេះឡើង។ គាត់ពិពណ៌នាអំពីការសាងសង់ប្រឡាយ ទំនប់ និងធ្វើស្រែជាដើមនេះ។ ហើយគាត់លើកឡើងដូចតទៅនេះ ខ្ញុំសូមដកស្រង់ "កុមារត្រូវបញ្ជូនទៅកុមារ"។ សូមបញ្ចប់ការដកស្រង់។

ហើយក្រោមហ្នឹងបន្តិចគាត់និយាយ សូមដកស្រង់៖ "យើងត្រូវកាប់ភ្ការដីហ្នឹង២០អាក្នុង១ថ្ងៃ បើមិនអីចឹងទេត្រូវគេសម្លាប់។ បើយើងធ្វើមិនបានទេ យើងនឹងមិនទទួលរបបបបរទេ"។

ឥឡូវនេះខ្ញុំសូមលើកអំពីចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀត ទាក់ទៅនឹងការសង់ទំនប់១មករា ដែលផ្ទុះបញ្ចាំងពីគោលនយោបាយសហករណ៍។ សហព្រះរាជអាជ្ញាបានលើកឡើងពីបញ្ហានេះដែរម្សិលមិញ គឺឯកសារ D22/1947a, ERN ជាភាសាបារាំងគឺ 00905155, ជាភាសាអង់គ្លេសគឺ 00851264 ទៅដល់ 65, ជាភាសាខ្មែរគឺ 00578135។

[១១:៥៨:០០]

ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ – កាលសម័យនោះគាត់នៅកំពង់ធំ – បានលើកឡើងដូចតទៅនេះ៖ "ក្រោយមកទៀត ខ្ញុំត្រូវបានពួកខ្មែរក្រហមឲ្យខ្ញុំទៅនៅភូមិជម្លៀស ឲ្យទៅលើកទំនប់នៅទំនប់

១មករា នៅខេត្តកំពង់ធំ ប្រហែលជាដើមឆ្នាំ៧៧។ នៅពេលនោះពួកខ្មែរក្រហមមានដូចជា សុង សៀន ជាដើមបានទទួលបញ្ជាពីថ្នាក់លើ ហើយចាត់តាំងឲ្យប្រុសៗរាប់រយនាក់ទៅចូលរួមលើកទំនប់ ១មករា នៅកំពង់ធំ"។ សូមបញ្ចប់ការដកស្រង់។

លោកប្រធានខ្ញុំមានឯកសារមួយទៀតនៅទាក់ទងនឹងផ្នែកចំណុចមួយនេះនៃគោលនយោបាយ។ តើខ្ញុំអាចលើកឡើងបានទេ?

ឥឡូវខ្ញុំសូមដកស្រង់ឯកសារ D22/129 គឺជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែលនៅកំពង់ឆ្នាំង សម័យនោះ ហើយគាត់បាននិយាយអំពីព្រលានយន្តនៅកំពង់ឆ្នាំង។ ERN ជាភាសាបារាំងគឺ 0090 9841, ជាភាសាអង់គ្លេសគឺ ERN 00398344, ERN ជាភាសាខ្មែរគឺ 00365048។

[១១:៥៩:៥៤]

ដើមបណ្ដឹងរដ្ឋប្បវេណីនេះលើកឡើងដូចតទៅនេះ៖ "គេឲ្យខ្ញុំជីកប្រឡាយ ហើយនិងលើកភ្លឺនៅបឹងជើងឯក ហើយនៅពេលនោះអង្គការបានបង្ខំឲ្យខ្ញុំធ្វើការទាំងយប់ទាំងថ្ងៃ ហើយនិងឲ្យខ្ញុំហូបតែបបរកន្លះវែកតែប៉ុណ្ណោះក្នុងមួយពេល។ ដោយគេចាត់ទុកថាខ្ញុំពាក់ព័ន្ធនឹងរបប លន់ នល់ នោះ គេតាមដានខ្ញុំរហូតៗ"។ ហើយក្រោមហ្វឹងបន្តិចហ្វឹង គាត់លើកឡើងថា "នៅឆ្នាំ១៩៧៧ គេបានបញ្ជូនខ្ញុំទៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ដើម្បីវាយថ្មភ្នំទាំងយប់ទាំងថ្ងៃ រហូតដល់ចុងឆ្នាំ១៩៧៨"។ សូមបញ្ចប់ការដកស្រង់។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកស្រីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលាសវនាការនេះ ហើយនិងឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១នាទី ដល់ម៉ោង ១៣:៣១នាទី)*

[១៣:៣១:៤៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុសហឧក្រិដ្ឋកម្មរួម។ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណ ជម្រាបសួរលោកប្រធាន និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ ខ្ញុំសូមបន្តពាក់ព័ន្ធទៅនឹងគោលនយោបាយស្តីពីសហករណ៍ និងជំរំធ្វើការដដែល។ កាលពីព្រឹកមិញនេះ ខ្ញុំបានលើកឡើងអំពីធាតុចាំបាច់ដែលជាគោលដៅក្នុងការបង្កើនផលិតកម្ម ការបង្កបង្កើនផល។

ឥឡូវនេះ ខ្ញុំនិយាយអំពីគោលដៅទី២ ដែលត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញារួចមកហើយ។ ដែលនិយាយថាសហករណ៍អាចឲ្យគ្រប់គ្រង់និងស្វែងរកខ្មាំង។ ដូច្នេះ ខ្ញុំសូមចាប់ផ្តើមអានឯកសារD22/2751។ គាត់គឺជាដើមបណ្តឹងរដ្ឋប្បវេណីដែលពេលនោះគាត់ស្ថិតនៅតាកែវ។ ERN មានដូចតទៅ៖ 00899639 ជាភាសាបារាំង, 00873677 ជាភាសាអង់គ្លេស, 00556118 ជាភាសាខ្មែរ។ សម្រង់នេះគឺខ្លីទេ។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបានឆ្លើយថា "នៅទីនោះ គ្រួសារខ្ញុំគេហៅថាពួក១៧មេសា ហើយវាបង្ខំឲ្យគ្រួសារខ្ញុំធ្វើការច្រើនជាងពួកមូលដ្ឋាន ហើយវាឲ្យពួកខ្ញុំហូបតិចជាងពួកមូលដ្ឋាន"។

[១៣:៣៤:២៩]

បន្តមកទៀត ខ្ញុំសូមលើកឡើងនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខ D22/1242, ERN ជាភាសាបារាំងគឺ 00906225, ជាភាសាអង់គ្លេស 00891214, ជាភាសាខ្មែរគឺ 00523379។ ដើមបណ្តឹងរដ្ឋប្បវេណីនេះដែលនោះគាត់នៅកំពង់ឆ្នាំង គាត់បានឆ្លើយថា "បើប្រជាជនណាម្នាក់ឈឺ ហើយទៅធ្វើការមិនកើត គឺពួកវាតែងតែនិយាយថាឈឺសតិអារម្មណ៍។ នៅពេលចាប់ផ្តើមសម្រាកពីការងារនៅពេលល្ងាច គឺមេកងឈ្លបចាប់ផ្តើមត្រួតពិនិត្យមើលតាមផ្ទះនីមួយៗ និងប្រមូលសម្ភារៈដែលនៅជាប់ខ្លួនដូចជានាឡិកា ប្រាក់ គឺពួកវាដកហូតទាំងអស់ និងឃ្លាំមើលថាតើប្រជាជនណាមានមុខងារអ្វីមុខជាប់និន្នាការ លន់ នល់ ជាដើម"។ សូមបញ្ចប់ការដកស្រង់។

ចុះមកក្រោមបន្តិចទៀតមក គាត់ក៏បានសរសេរបន្តទៀតថា “ប្រជាជនដែលត្រូវគេជម្លៀសត្រូវបានគេចាត់ទុកថាប្រជាជន១៧ មេសា ហើយត្រូវពួកវាឃ្លាំមើលគ្រប់ពេលវេលាទាំងអស់”។

[១៣:៣៦:១៣]

ជាបន្តទៅទៀតនេះ ខ្ញុំសូមលើកឡើងនូវឯកសារ D22/143 គាត់ជាដើមបណ្តឹងរដ្ឋប្បវេណីដែលពេលនោះនៅកំពង់ធំ។ ERN ជាភាសាបារាំងគឺ 00898347, ជាភាសាអង់គ្លេស 00402949, ជាខ្មែរ 00365377។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបានលើកឡើងនូវពាក្យដែលប្រើប្រាស់ដោយខ្មែរក្រហមដើម្បីកំណត់ខ្មាំង។ ពាក្យទាំងអស់នេះត្រូវបានសហព្រះរាជអាជ្ញាលើកឡើងរួចមកហើយដែលមានសរសេរនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ក៏ដូចជាឯកសារផ្សេងៗទៀតដែលជាឯកសារផ្លូវការរបស់របបខ្មែរក្រហម។ ដើមបណ្តឹងរដ្ឋប្បវេណីបានសរសេរថា “អ្នកណាខ្ជិលច្រអូស ពួកខ្មែរក្រហមវាយធ្វើទារុណកម្ម ហើយចោទថាប្រឆាំងនឹងអង្គការ”។

នៅក្នុងគោលដៅដែលនេះ ខ្ញុំនឹងលើកឡើងនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ D22/147 ដែលពេលនោះគាត់នៅស្វាយរៀង។ ERNជាភាសាបារាំង 00896817, ជាភាសាអង់គ្លេស 00402961, ERNជាភាសាខ្មែរ 00368682។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានឆ្លើយថា៖ “ខ្ញុំដឹងពីប្រពន្ធពូ កោប លាង ប្អូនប្រុសម្តាយខ្ញុំឈ្មោះ យាយនាង ប្រាប់ថាប្តីគាត់ហូបមិនគ្រប់គ្រាន់ឈឺរាក ធ្វើការមិនកើត ខ្មែរក្រហមមិនឲ្យថ្នាំលេបដោយចោទថាខ្ជិលច្រអូស។ គាត់ឈឺរហូតដល់ស្លាប់នៅផ្សារកអណ្តើក”។

[១៣:៣៨:៥៣]

ពាក់ព័ន្ធទៅនឹងពាក្យដែលបានប្រើនៅក្នុងគោលនយោបាយខ្មែរក្រហមដដែល ខ្ញុំសូមលើកឡើងនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ D277/8។ ERN ជាភាសាបារាំង 00424136, ERN ជាភាសាអង់គ្លេស 00384787, ខ្មែរ 00375548។ នេះគឺជាកំណត់ហេតុស្តាប់ចម្លើយរបស់ការិយាល័យសហព្រះរាជអាជ្ញា -- សូមទោស សហចៅក្រមស៊ើបអង្កេត ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា “ខ្ញុំត្រូវបានគេធ្វើបាបនៅពេលដែលខ្ញុំឈឺ ខ្មែរក្រហមមិនជឿថាខ្ញុំឈឺទេ។ ពួកគេចោទខ្ញុំថា ខ្ជិល ហើយខ្ញុំត្រូវទទួលទារុណកម្ម”។

ជាបន្តទៅទៀតនេះ ខ្ញុំសូមលើកឡើងនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ D22/2011 ដែលពេលនោះគាត់នៅពោធិ៍សាត់។ ERN ជាភាសាបារាំង គឺ 00900237, ជាភាសាអង់គ្លេសគឺ

00893689 ទៅដល់ 90, ជាភាសាខ្មែរ 00541770។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបានឆ្លើយថា៖ “នៅក្នុងពេលស្ទូងទាហាន និងឈ្លបខ្មែរក្រហមពិនិត្យមើលប្រជាជនជម្លៀសជានិច្ចដែលជម្លៀសទៅភូមិបាក់រត់ ពីព្រោះគេចាត់ទុកពួកនោះថាជាប្រជាជន១៧ មេសា។ អ្នកណាដែលជាមន្ត្រីរាជការអ្នកពាណិជ្ជកម្មនិស្សិតត្រូវតែប្រាប់ការពិតដើម្បីឲ្យកាន់តំណែងដដែលវិញ។ ជាបន្តិចម្តងៗ អតីតមន្ត្រីរដ្ឋការចេញទៅហើយមិនដែលត្រឡប់មកវិញទេ”។

[១៣:៤១:៤៧]

ឥឡូវនេះ ខ្ញុំសូមលើកឡើងនូវឯកសារ D22/2014a, ERN ជាភាសាបារាំង 00903104, ជាភាសាអង់គ្លេសគឺ 00890965, ជាភាសាខ្មែរគឺ 00580736។ គឺពាក់ព័ន្ធទៅនឹងបញ្ហាក្តាប់និងស្វែងរកខ្មាំង និងលក្ខណៈវិនិច្ឆ័យក្នុងការកំណត់ខ្មាំង ដើមបណ្តឹងរដ្ឋប្បវេណីនេះបានសរសេរថា៖ “ពេលដែលខ្ញុំរស់នៅឃុំខ្លាយ ស្រុកឈូក ខេត្តកំពត ខ្ញុំធ្លាប់ត្រូវបានគេហៅឲ្យចូលរួមប្រជុំនៅវត្តដំណាក់ត្រយឹងក្នុងស្រុកឈូក ខេត្តកំពត។ ខ្ញុំទៅទីនោះប្រហែលជាឆ្នាំ១៩៧៧ ពេលខ្ញុំចូលរួមប្រជុំនោះគេបានហៅប្រជាជនទាំងអស់ដែលបានចូលរួមឲ្យមើលបុរសម្នាក់ស្ត្រីពីរនាក់ដែលគេចោទថាខុសសីលធម៌។ ពួកគេទាំងបីនាក់នេះត្រូវបានគេចាប់ចង ហើយខ្មែរក្រហមនិយាយថាកុំឲ្យយកគំរូតាមអ្នកទាំងបីនេះ ព្រោះខ្មែរក្រហមនឹងកម្ទេចអ្នកទាំងបីនេះចោល”។

ឥឡូវនេះ ខ្ញុំសូមចូលទៅគោលដៅផ្សេងទៀតនៃគោលនយោបាយស្តីសហករណ៍ និងជំរំការងារដែលជាគោលដៅកម្ទេចភាពជាឯកជន ហើយនិងបង្កើតរបបមួយដែលជាសមូហភាព។

[១៣:៤៣:៥៧]

ខ្ញុំសូមលើកឡើងនូវឯកសារ D22/1644, ERN ជាភាសាបារាំង 00895187, ជាភាសាអង់គ្លេស 00891247 ទៅដល់ 48, ជាភាសាខ្មែរ 00532347 ដើមបណ្តឹងរដ្ឋប្បវេណីនេះលើកឡើងអំពីការបំបែកគ្រួសារទៅតាមក្រុមផ្សេងៗ។ គាត់សរសេរថា “ឆ្នាំ១៩៧៦ ពួកឈ្លបខ្មែរក្រហមបានរៀបចំជាកង ជាក្រុម ទៅតាមវ័យតាមកម្លាំងពលកម្ម។ គ្រួសារខ្ញុំក៏ដូចជាប្រជាជនដទៃ ត្រូវបានចាត់តាំងឲ្យបែកគ្នាខ្ញុំមានសមាជិកគ្រួសារ ប្រាំពីរនាក់គឺឪពុក ម្តាយ រូបខ្ញុំ ប្អូនស្រីខ្ញុំ ក្មួយស្រី កូនប្រុស និងកូនស្រី។ កូនៗរបស់ខ្ញុំទាំងពីរនៅកងកុមារ។ កូនរបស់ប្អូនខ្ញុំនៅជាមួយយាយ ខ្ញុំនៅកងកណ្តាល។ ប្អូនខ្ញុំ ទេព ពេជ្រ នៅកងចល័ត។

ឥឡូវនេះ ខ្ញុំសូមលើកឡើងនៅឯកសារ D22/2903, ERN ជាភាសាបារាំង 00779607, ERN

ជាភាសាអង់គ្លេស 00779605 ទៅដល់ 06, ERN ជាភាសាខ្មែរ 00558351។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានលើកឡើងអំពីការហូបរួម។ គាត់បានសរសេរថា៖ “ដើមឆ្នាំ៧៦ គេអត់ឲ្យយើងហូបនៅផ្ទះទេ គឺថាមានតែរបស់បន្តិចបន្តួចប៉ុណ្ណោះ ហើយអ្វីៗដែលយើងមានគឺអង្គការរឹបអូស ហើយយកទៅដាក់សមូហភាពនៅក្នុងសហករណ៍។ កម្មសិទ្ធិឯកជនមិនត្រូវបានអនុញ្ញាតទៀតទេ។ គេបញ្ជាឲ្យយើងហូបរួមនៅក្នុងចង្ក្រានបាយ ផ្ទះបាយ”។

[១៣:៤៧:០០]

ឥឡូវនេះ ខ្ញុំសូមលើកឡើងនៅឯកសារ D22/3765, ERN ជាភាសាបារាំង 00892710, ERN ជាភាសាអង់គ្លេស 00892762, ជាភាសាខ្មែរ 00875009។ គាត់បានលើកឡើងនូវសុន្ទរកថារបស់ខ្មែរក្រហមពាក់ព័ន្ធទៅនឹងសមូហភាព។ គាត់និយាយថា៖“ខ្មែរក្រហមបានឲ្យយើងនៅក្នុងភូមិដែលស្ថិតនៅក្នុងព្រៃ ហើយបញ្ជាឲ្យយើងសង់ខ្ទមរស់នៅដោយខ្លួនឯង។ យើងហូបរួម គេមិនអនុញ្ញាតឲ្យហូបតែម្នាក់ឯងទេ ពួកគេបែងចែកការងារឲ្យធ្វើ គឺឲ្យបុរសស្ត្រី មនុស្សចាស់ និងកុមារ នៅ -- គឺធ្វើការតាំងពីព្រលឹមទល់ព្រលប់រហូតទៅដល់ម៉ោងដប់យប់ឯណោះ ទើបយើងអាចសម្រាកបាន”។

ឥឡូវនេះ ខ្ញុំសូមលើកឡើងនៅឯកសារ D22/524។ ដែលពេលនោះ គាត់នៅបាត់ដំបង គាត់ក៏បានលើកឡើងអំពីការបំបែកគ្រួសារឲ្យនៅផ្សេងពីគ្នា។ ERN ជាភាសាបារាំង 00897129, ជាភាសាអង់គ្លេស 00890599, ជាភាសាខ្មែរ 00496952។ ខ្ញុំសូមមិនអានសម្រង់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះទេ ខ្ញុំគ្រាន់តែពន្យល់ថា គាត់ប្រាប់ថាខ្មែរក្រហមតម្រូវឲ្យបំបែកគ្រួសារឲ្យរស់នៅដាច់ដោយឡែកពីគ្នា។

ឯកសារចុងក្រោយពាក់ព័ន្ធទៅនឹងសហករណ៍ និងជំរំការងារ ខ្ញុំសូមលើកឡើងនូវឯកសារលេខ D22/836។ ដែលពេលនោះគាត់នៅខេត្តកណ្ដាល គឺនៅតំបន់កណ្ដាល។ ERN ជាភាសាបារាំងគឺ 00860969, ជាភាសាអង់គ្លេស 00893532, ជាភាសាខ្មែរ 00504601។ គាត់បានសរសេរថា “យើងជាកសិករ ទាហានខ្មែរក្រហមបានរឹបអូសទ្រព្យសម្បត្តិពីប្រជាជននៅផ្ទះ ដើម្បីយកមកដាក់ជាសមូហភាព។ ពួកគេបង្គាប់ឲ្យប្រជាជនទាំងស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ”។ ខ្ញុំសូមបញ្ចប់គោលនយោបាយនេះ។

[១៣:៥០:៣៤]

ឥឡូវនេះខ្ញុំសូមចូលទៅដល់គោលនយោបាយអប់រំកសាង គឺអប់រំកសាងសមាសភាពមិនល្អ និង

ការកម្ទេចខ្មាំង។ ខ្ញុំនឹងនិយាយអំពីគោលដៅនៃគោលនយោបាយ ដែលត្រូវបានលើកឡើកដោយព្រះរាជអាជ្ញារួចមកហើយ។

ជាដំបូងខ្ញុំសូមលើកឡើងនូវឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីលេខ D22/1557។ ERN ជាភាសាបារាំង 00905218, ជាភាសាអង់គ្លេស 00888498, ជាភាសាខ្មែរគឺ 00530391 ទៅដល់ 92។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបាននិយាយថា "យើងត្រូវតែនិយាយ ប្រសិនបើកាលពីមុនយើងជាមន្ត្រីរដ្ឋការ ជាកងទ័ព ឬជាសិស្ស និស្សិត។ ពួកគេបានប្រាប់ឲ្យយើងនិយាយការពិតទាំងអស់ ហើយបើយើងនិយាយការពិត យើងអាចទៅកាន់មុខតំណែងចាស់របស់យើងវិញបាន។ ការប្រជុំនេះត្រូវបានដឹកនាំដោយឈ្មោះ បៀន។ បងថ្លៃរបស់ខ្ញុំឈ្មោះ លី អេង បានសារភាពថាគាត់ជាទាហាន លន់ នល់។ អ្នកដែលបានឆ្លើយប្រាប់ពីការពិតពីអតីតកាលរបស់ខ្លួន ត្រូវបានបញ្ជូនទៅអប់រំ ដើម្បីជួយកសាងប្រទេស។ ក្រោយមកពួកគាត់ក៏បាត់ខ្លួនរហូត"។

បន្ទាប់មកទៀតដើមបណ្តឹងរដ្ឋប្បវេណីរូបនេះក៏បានសរសេរតទៅទៀតថា "១ខែ ឬ២ខែក្រោយពីប្អូនរបស់ខ្ញុំស្លាប់ គឺនៅដើមឆ្នាំ១៩៧៦ អង្គការបានប្រកាសម្តងទៀត អ្នកដែលជាប់និន្នាការធ្វើការ ធ្វើទាហាន ឲ្យប្រាប់គេឲ្យត្រង់ នឹងបញ្ជូនទៅរៀនសូត្រដើម្បីមកកសាងប្រទេសជាតិវិញ"។

[១៣:៥៣:២២]

ឥឡូវនេះខ្ញុំសូមលើកឡើងនូវឯកសារលេខ D22/2896, ERN ជាភាសាបារាំងគឺ 00807149, ជាភាសាអង់គ្លេស 00793363, ជាភាសាខ្មែរ 00558233។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានសរសេរថា "នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺយើងដឹងជាទូទៅហើយ វាថ្ងៃដែលកងទ័ពខ្មែរក្រហមទទួលជ័យជម្នះលើលោកសេនាប្រមុខ លន់ នល់។ បន្ទាប់មក គោលនយោបាយរបស់ពួកខ្មែរក្រហមបានចាប់ផ្តើមបែងចែក និងជម្លៀសប្រជាជនខ្មែរជាច្រើនបែប ច្រើនវណ្ណៈ។ ទី១ គេបែងចែកប្រជាជនជាប្រជាជន១៧មេសា។ ទី២ គេបែងចែកមន្ត្រីរដ្ឋការក្នុងរបប លន់ នល់។ ពួកខ្មែរក្រហមធ្វើការសាកសួរមន្ត្រីរដ្ឋការក្នុងសម័យ លន់ នល់ ថាតើពួកគាត់ធ្វើអ្វីខ្លះ? ពួកខ្មែរក្រហមប្រកាសថា បើមន្ត្រីរដ្ឋការក្នុងសម័យ លន់ នល់ ធ្វើការអី ពួកខ្មែរក្រហមនឹងទៅឲ្យបម្រើការងារនោះវិញ។ ពេលនោះដោយប្រជាជនចង់បានការងារធ្វើ ក៏បង្កើនឋានៈរបស់ខ្លួនថា ខ្លួនបម្រើការនៅក្នុងក្រសួងនោះក្រសួងនេះទៅ។ ក្រោយពីពួកខ្មែរក្រហមស៊ើបសួររួចអស់ហើយ ពួកខ្មែរក្រហមក៏នាំមន្ត្រីរដ្ឋការទាំងអស់នោះយកទៅសម្លាប់ចោល ដោយប្រើពាក្យថាយកទៅរៀនសូត្របន្ថែម។ ក៏ប៉ុន្តែពាក្យថារៀនសូត្រនេះគឺមានន័យថា

យកទៅសម្លាប់ចោលហើយ។ នេះគឺជាដំណាក់កាលដំបូងនេះគម្រោងរបស់ពួកគេ។ ជំហានបន្ទាប់នោះពួកគេបោសសម្អាតប្រជាជន១៧ មេសា"។

ឥឡូវនេះខ្ញុំសូមលើកឡើងនូវឯកសារលេខ D22/623, ERN 00849889 ជាភាសាបារាំង, ជាភាសាអង់គ្លេស 00893530, ជាភាសាខ្មែរ 00499873។ ខ្ញុំមិនអាននូវសម្រង់ឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ខ្ញុំគ្រាន់តែបញ្ជាក់ជូនថាដើមបណ្តឹងរដ្ឋប្បវេណីនេះលើកឡើងអំពីអត្ថិភាពនៃគោលនយោបាយបង្កើតមន្ទីរសន្តិសុខនៅទូទាំងប្រទេសកម្ពុជានៅសម័យកម្ពុជាប្រជាធិបតេយ្យ។

[១៣:៥៦:៤៧]

ពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌ អប់រំសមាសភាពមិនល្អ និងការកម្ទេចខ្មាំងដដែលនេះ ខ្ញុំលើកឡើងប្រធានបទមួយទៀតគឺការកំណត់អំពីសញ្ញាណខ្មាំង។ ដូចដែលខាងសហព្រះរាជអាជ្ញាបានលើកឡើងរួចមកហើយ។

ជាដំបូងខ្ញុំសូមលើកឡើងនូវដើមបណ្តឹងរដ្ឋប្បវេណីលេខ D277/6, ERN ជាភាសាបារាំង 004 26411, ជាភាសាអង់គ្លេស 00377369, ជាភាសាខ្មែរ 00375525។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ "ខ្ញុំបានឃើញប្រជាជនជាច្រើនត្រូវបានគេចាប់ខ្លួន។ យើងត្រូវបានគេប្រាប់ថា ពួកទាំងនេះត្រូវបានបញ្ជូនទៅអប់រំកែប្រែ។ ប៉ុន្តែយើងមិនដែលឃើញពួកគេត្រឡប់មកវិញទេ។ យើងដឹងថាការបញ្ជូនទៅអប់រំកែប្រែគឺយកទៅសម្លាប់។ ប្រជាជនអាចត្រូវបានគេចាប់ខ្លួន ប្រសិនបើពួកគេលួចម្ហូបអាហារ ឬក៏ពួកគេមានប្រវត្តិរូបមិនល្អ។ ឧទាហរណ៍ដូចជាអតីតមន្ត្រីរដ្ឋការក្នុងសង្គមមុនជាដើម"។

[១៣:៥៨:៥៩]

ឥឡូវនេះ ខ្ញុំសូមលើកឡើងនូវឯកសារ D22/352 ដែលស្ថិតនៅក្នុងតំបន់ក្រចេះ -- សូមទោស D22/452, ERN ជាភាសាបារាំងគឺ 00813223, ជាភាសាអង់គ្លេស 00818604, ជាភាសាខ្មែរ 00495978។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះឆ្លើយថា -- ខ្ញុំសូមដកស្រង់៖ "ពេលយប់ ពួកកងទ័ពឈ្លបពួកឈ្លបឃ្លាំមើលយើងរហូត ហើយបើយើងប្រើពាក្យថាយាមឲ្យត្រឹមត្រូវ ឲ្យប្រយ័ត្នយកចិត្តទុកដាក់ប្រសិនបើថ្លោះធ្លោយចំពេលអ្នកណាទទួលខុសត្រូវនោះ គេចោទយើងថាចូលដៃជាមួយពួកខ្មាំង"។

ដើមបណ្តឹងរដ្ឋប្បវេណីនេះបន្ថែមទៀតថា-- ខ្ញុំសូមដកស្រង់៖ "នៅពេលយាម -- ពេលយប់យើងត្រូវយាមដើម្បីការពារពីខ្មាំង។ យើងអត់មានកាំភ្លើងទេ មានតែកាំបិត និងពូថៅ។ នៅពេលយាម

យប់នោះ គឺថាយើងស្ថិតនៅក្រោមការឃ្លាំមើលរបស់ពួកឈ្លបរហូត។ ហើយគេមើលយើង ថាតើយើងប្រើពាក្យថា យាមឲ្យត្រឹមត្រូវឲ្យប្រុងប្រយ័ត្ន យកចិត្តទុកដាក់។ បើធ្លោះធ្លោយចំវេនយាមណា ត្រូវទទួលខុសត្រូវដោយខ្លួនឯង ហើយគេអាចចោទថាចូលដៃជាមួយពួក សេ.អ៊ី.អា ទៀត។ ដូច្នេះ មិនថាក្រុមគេ ក្រុមនាងខ្ញុំទេ យាមតែងតែប្រុងប្រយ័ត្នជានិច្ច មិនហ៊ានដេក មិនហ៊ានពួនទេ។ មេក្រុមមកត្រួតពិនិត្យ៣ថ្ងៃម្ដង ដើម្បីមើលថា តើការងារដែលគេដាក់ឲ្យធ្វើហ្នឹង យើងធ្វើតាមផែនការឬក៏អត់”។

[១៤:០១:២៧]

ឥឡូវនេះ ខ្ញុំសូមលើកឡើងនូវឯកសារលេខ D22/3744, ERN ជាភាសាបារាំង 00891077, ជាភាសាអង់គ្លេស 00889676, ជាភាសាខ្មែរ 00875443។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានសរសេរថា៖ “ពួកកុម្មុយនីស្តគំរាមកំហែងយើងជានិច្ច ពីព្រោះពួកគេមានចេតនាសម្លាប់ប្រជាជនថ្មីទាំងអស់នៅក្នុងរបបនេះ។ ពួកគេនិយាយឲ្យច្បាស់ថា ទុកក៏មិនចំណេញដកចេញក៏មិនខាត។ ដល់ពួកគេចោទប្រជាជនថ្មីថាគេងប្រវ័ញ្ចពីការងារ។ ដូច្នេះត្រូវតែកម្ទេចចោល”។

ឥឡូវនេះ ខ្ញុំចូលដល់ឯកសារD22/32, ERN ជាភាសាបារាំង 00899928, ជាភាសាអង់គ្លេស 00332219, ជាភាសាខ្មែរ00279752។ ខ្ញុំលើកឡើងឃ្លានេះមិនពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយទេ ក៏ប៉ុន្តែគឺពាក់ព័ន្ធទៅនឹងពាក្យដើម្បីកំណត់ខ្មាំង។ ដើមបណ្ដឹងរដ្ឋប្បវេណីនេះបានសរសេរថា៖ “ក្រោយមក នៅឆ្នាំ១៩៧៨ដដែល ប៉ារបស់ខ្ញុំបានទៅលួចបបរបាយជ្រូកគេយកមកឲ្យម៉ាក់ខ្ញុំ និងខ្ញុំញាំ។ ពេលនោះ គេមកទាន់ គេក៏ចាប់ប៉ាខ្ញុំទៅអប់រំ”។

ចំពោះមូលហេតុដដែលនេះ ខ្ញុំសូមលើកឡើងនូវឯកសារ D22/3765 ដែលបានលើកឡើងអំពីការលួចដែលចាត់ទុកថាជាខ្មាំង។ ERN ជាភាសាបារាំង 00892711, ជាភាសាអង់គ្លេស 0089 2763, ជាភាសាខ្មែរ 00875010។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានសរសេរថា “ចំពោះខ្មែរផ្សេង ខ្ញុំឃើញខ្មែរក្រហមនាំយកទៅសម្លាប់ចោទដោយគ្មានត្រាប្រណី ដោយពួកគាត់គ្រាន់តែលួចបំពង់ឫស្សីដាក់ទឹកត្នោត ឬក៏លួចស៊ុតមាន់ ស៊ុតទា ឬក៏លួចមាន់។ អ្នកខ្លះត្រូវបានគេចោទថាលួចបេះស្រូវយកទៅចំអិនហូប។ ខ្ញុំសូមបញ្ជាក់ថា កូនប្រុសពីរនាក់របស់ខ្ញុំត្រូវបានសម្លាប់ចោល ដោយសារតែពួកវាលួចអាហារបន្តិចបន្តួចដើម្បីកុំឲ្យឃ្លាន”។

[១៤:០៥:២៩]

ឯកសារចុងក្រោយពាក់ព័ន្ធទៅនឹងការកំណត់ខ្មាំង។ ខ្ញុំសូមលើកឡើងនូវឯកសារ D22/1643,

ERN ជាភាសាបារាំង 00895189, ជាភាសាអង់គ្លេស 00891250, ជាភាសាខ្មែរ 00532349។ នេះនិយាយអំពីការលួចទៀតហើយ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានសរសេរថា៖ “ក្មួយរបស់ខ្ញុំមួយឈ្មោះ ទេព ព្រួញ ដែលជាកងចល័តកុមារ ជាកូនរបស់ ទេព ជឹម និងឈ្មោះ យ៉ែម បានលួចមាន់មួយដែលគេចិញ្ចឹម។ ក្មេងៗផ្សេងទៀតបានរាយការណ៍ ហើយពួកឈ្លបក៏យកក្មួយនោះទៅដាក់នៅមណ្ឌលកែប្រែ ឬមណ្ឌលឃុំឃាំង”។

ឥឡូវនេះខ្ញុំចូលទៅប្រធានបទផ្សេងទៀត គឺពាក់ព័ន្ធទៅនឹងការអប់រំកែប្រែសមាសភាពមិនល្អ និងការកម្ទេចខ្មាំងដដែលគឺ ពាក់ព័ន្ធទៅនឹងពាក្យដែលកំណត់ដោយគោលនយោបាយទាំងអស់នេះក្នុងការស្វែងរកខ្មាំង ការកំណត់ខ្មាំងនៅក្នុងសហករណ៍។

ឯកសារទី១ ដែលខ្ញុំនឹងដកស្រង់នេះ គឺជាឯកសារ D22/2068។ ខ្ញុំសូមអភ័យទោស ខ្ញុំនឹងអានឯកសារនេះជាភាសាអង់គ្លេសទេ ពីព្រោះថាពុំមានការបកប្រែជាភាសាបារាំងទេសព្វថ្ងៃនេះ ឥឡូវនេះ។ ERN ជាភាសាអង់គ្លេសគឺ 00893383, ជាភាសាខ្មែរគឺ 00544560។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងដូចតទៅនេះជាភាសាអង់គ្លេស៖

[១៤:០៧:៥៥]

(អានជាភាសាអង់គ្លេស៖) “ទាហានខ្មែរក្រហមទាំងនោះ គឺពូកែខាងស៊ើបតាមដានណាស់ ពួកវាដើរទៅដើរមកសួរ ហើយស្វែងរកទាហាន ស្វែងរកប្រជាជនណាដែលជាពេទ្យ គ្រូបង្រៀន ទាហាន ឬក៏ជាសាស្ត្រាចារ្យ ហើយបន្ទាប់មកសម្លាប់ពួកគាត់ព្រមទាំងក្រុមគ្រួសារទាំងមូលតែម្ដង។ ខ្ញុំដឹងថាប្រវត្តិរបស់ប្ដីខ្ញុំមិនអាចលាក់បាំងជារៀងរហូតបាននោះទេ”។ (បញ្ចប់ការអានជាភាសាអង់គ្លេស)

ឥឡូវនេះ ខ្ញុំសូមដកស្រង់ដើមបណ្ដឹងរដ្ឋប្បវេណី D22/1414 ដែលនៅពោធិ៍សាត់នៅក្នុងរបបខ្មែរក្រហម។ ERN ជាភាសាបារាំងគឺ 00893960, ជាភាសាអង់គ្លេសគឺ 00891235, ជាភាសាខ្មែរគឺ 00528133។ ដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងដូចតទៅនេះ៖ “ពួកគាត់ត្រូវបានគេតាមដានដោយអ្នកស៊ើបអង្កេតតូចៗ។ គ្រួសារខ្ញុំត្រូវចាត់ទុកជាប្រជាជន១៧មេសា ឪពុកម្ដាយខ្ញុំត្រូវបានគេតាមដានគ្រប់ជំហាន។ ពួកគេឃ្លាំមើលសួរបងប្អូនខ្ញុំថា ឪពុកម្ដាយខ្ញុំធ្វើអី ហើយដោយសួរថាបើសិនជា-- សួរថាតើឪពុកម្ដាយយើងហ្នឹងមានកាន់តំណែងខ្ពស់ដែរឬក៏អត់? ចាស់ៗ ឬក្មេងទាំងនោះសុទ្ធតែចាញ់កលពួកវាទាំងអស់ដូចជាអ្នកខ្លះដែលធ្វើជាអាជីវករ អ្នកខ្លះជាទាហាន ខ្លះជាគ្រូដែលចាត់ទុកថាជាប់និន្នាការនោះ គឺពួកវាឃោសនាឲ្យទៅធ្វើការនៅកន្លែងចាស់នោះវិញ។ ហើយពួកទាំងនោះសុទ្ធតែឆ្លើយថាធ្វើនេះធ្វើ

នោះហើយត្រូវពួកវាដឹកទាំងឡានៗយកទៅ"។

ឥឡូវនេះខ្ញុំសូមលើកយកដើមបណ្តឹងរដ្ឋប្បវេណី D22/3072។ កាលនោះគាត់នៅខេត្តក្រចេះ ហើយបន្ទាប់មកទៀតនៅខេត្តកំពង់ចាម។ ERN ជាភាសាបារាំងគឺ 00846054, ERN ជាភាសាអង់គ្លេសគឺ 00569922 ទៅដល់ 23, ហើយ ERN ជាភាសាខ្មែរគឺ00863960 ទៅដល់ 61។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបានលើកឡើងដូចតទៅនេះ៖ "១ខែក្រោយមកខ្ញុំត្រូវបានគេចាត់ទុកថាជាមនុស្សប្រឆាំងនឹងកុម្មុយនីស្ត ហើយគេបានព្រមានខ្ញុំថា គេនឹងបញ្ជូនខ្ញុំទៅតំបន់ភ្នំដើម្បីទទួលការអប់រំទាក់ទងទៅនឹងរបបកុម្មុយនីស្តនេះ"។

[១៥:១១:៤៦]

ហើយខាងក្រោមហ្នឹងបន្តិចដើមបណ្តឹងរដ្ឋប្បវេណីនេះក៏បានលើកឡើងផងដែរថា "ក្រោយពីពេលយើងទៅដល់កំពង់ចាម ពួកគេបានរៀបចំមីទ្ទិងមួយមានមនុស្ស២០០០នាក់ គេចង់ឲ្យយើងជឿលើអង្គការ ឲ្យយើងខិតខំប្រឹងប្រែងធ្វើការដើម្បីបម្រើអង្គការ ហើយឲ្យយើងលះបង់នូវគំនិតស្វនត្ត និងត្រូវចេះដាក់ខ្លួនជានិច្ច"។

ហើយនៅក្រោមហ្នឹងបន្តិចទៀត ដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា "ពីរដង១ឆ្នាំពួកគេសុំឲ្យយើងនិទានរឿងរបស់យើងទៅឲ្យប្រធានភូមិដើម្បីឲ្យដឹងច្បាស់ថាមិនមានអ្នកណាម្នាក់កុហកទេ។ ជួនកាលគេចោទ មានអ្នកកុហកចំពោះអ្នកដែលគេមិនចូលចិត្តនោះ។ ហើយអ៊ីចឹងអ្នកដែលគេមិនចូលចិត្តនោះគេមកយប់ហើយមកចាប់យកទៅ ហើយមិនដែលឃើញអ្នកទាំងអស់នោះត្រឡប់មកវិញទេ"។

ឥឡូវខ្ញុំសូមលើកយកដើមបណ្តឹងរដ្ឋប្បវេណី D22/328, ERNជាភាសាបារាំងគឺ 00901469, ហើយជាភាសាអង់គ្លេសគឺ 00864492, ជាភាសាខ្មែរគឺ 00484726។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបាននិយាយដូចតទៅនេះ៖ "ក្រោយមកខ្មែរក្រហមបានកោះហៅមនុស្សមួយចំនួនទៅប្រជុំដើម្បីស្តាប់របាយការណ៍ដែលពួកគេបានធ្វើ។ មិត្តឈឹម ដែលជាប្រធានភូមិបាននិយាយនៅក្នុងពេលប្រជុំនោះថា អ្នកដែលពួកយើងចាប់ពីមុននោះគឺជាពួកប្រឆាំងនឹងគេ (ខ្ញុំមិនដឹងថាពួកហ្នឹងប្រឆាំងនឹងអ្នកណាទេ)។ ដូចនេះត្រូវតែកម្ទេចចោលសូមមិត្តៗទាំងអស់ប្រយ័ត្នខ្លួនថ្ងៃក្រោយ។ បើពួកណាហ៊ានប្រឆាំងទៀតប្រយ័ត្នងាប់ដូចអាខ្មាំងប៉ុន្មាននាក់នោះ"។

[១៥:១៥:៣០]

ឥឡូវនេះខ្ញុំសូមលើកយកដើមបណ្តឹងរដ្ឋប្បវេណី D22/1836a-- ខ្ញុំសូមអភ័យទោសដោយសារ

អត់មានជាភាសាបារាំងទេ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅកំពង់ចាមកាលនោះនៅពេលដែលគាត់លើកឡើងនេះ។ ERNជាភាសាអង់គ្លេសគឺ 00834848, ជាភាសាខ្មែរគឺ00579044។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានឆ្លើយយ៉ាងដូច្នេះ។ សូមដកស្រង់ជាភាសាអង់គ្លេស។

(អានជាភាសាអង់គ្លេស៖) “បន្ទាប់មកក្នុងឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានចោទខ្ញុំថា ជាពួករាជការ ពួកសក្តិភូមិ ហើយបានធ្វើប្រវត្តិរូបខ្ញុំ និងបញ្ជូនខ្ញុំ និងក្រុមគ្រួសារឲ្យមកមណ្ឌលគិរី”។

(បញ្ចប់ការអានជាភាសាអង់គ្លេស)

ឥឡូវនេះ ខ្ញុំសូមលើកឡើងពីដើមបណ្ដឹងរដ្ឋប្បវេណី D217/3 ដែលជាកំណត់ហេតុស្ដាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេត។ ERN ជាភាសាបារាំងគឺ 00372052 ទៅដល់ 53, ជាភាសាអង់គ្លេសគឺ 00353702 ហើយទៅដល់ 04, ហើយជាភាសាខ្មែរគឺ 00349497 ទៅដល់ 100។

[១៤:១៧:៥០]

ខ្ញុំសូមដកស្រង់ មានសំណួរមួយសួរទៅដើមបណ្ដឹងរដ្ឋប្បវេណីនេះ “សំណួរ៖ តើមេខ្មែរក្រហមនៅក្នុងភូមិរបស់លោកបានចាប់ផ្ដើមសួរចម្លើយ និងចាប់ខ្លួនមនុស្សហើយឬនៅ? តើពួកគេមានបញ្ហាឲ្យប្រជាជនធ្វើការធ្ងន់ធ្ងរទេ? តើពួកគេមានគោរពសិទ្ធិរបស់ប្រជាជនទេ?” ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ “ឆ្លើយ៖ ពេលនោះ ខ្មែរក្រហមមិនបានធ្វើបាបប្រជាជនទេ។ គេបានប្រកាសឲ្យប្រជាជនដែលបានធ្វើការនៅក្នុងរបប លន់ នល់ និងអ្នកចេះដឹងទាំងអស់មកបង្ហាញខ្លួន។ អ្នកដែលបង្ហាញខ្លួនត្រូវបានគេយកទៅរៀនសូត្រ”។

សម្រង់ទី២ នៃការស្ដាប់ចម្លើយគាត់នេះ ខ្ញុំបានផ្ដល់លេខ ERN អម្បាញ់មិញនេះហើយ។ ផ្នែកទី២នេះគឺទាក់ទងទៅនឹងស្វ័យទិតៀន។ សំណួរ -- គេចោទសំណួរទៅកាន់គាត់ “តើលោកធ្លាប់ចូលរួមប្រជុំស្វ័យទិតៀនដែរឬទេ?” ចម្លើយ៖“មានការប្រជុំស្វ័យទិតៀនដែលប្រជាជនរាយការណ៍ទៅខ្មែរក្រហមអំពីអ្នកដែលខ្ជិលធ្វើការងារ។ ប្រសិនបើមាននរណាត្រូវបានគេរាយការណ៍ពីរដង ហើយមិនបានផ្លាស់ប្ដូរចរិតទេ ខ្មែរក្រហមនឹងយកអ្នកទាំងនោះទៅសម្លាប់”។

[១៤:១៨:៤២]

ឥឡូវនេះ ខ្ញុំសូមនិយាយអំពីធាតុសំខាន់មួយទៀតនៃគោលនយោបាយនេះ ដែលថាគោលនយោបាយក្នុងការអប់រំសមាសធាតុល្អ ហើយនិងការបំបាត់ខ្មាំងនេះ វាពាក់ព័ន្ធទៅនឹងបងប្អូនជិតស្និទ្ធនៃប្រជាជន។ ឥឡូវនេះ ខ្ញុំសូមលើកយកដើមបណ្ដឹងរដ្ឋប្បវេណី D22/193, លេខ ERN គឺ00446588។

ពុំមានការបកប្រែជាភាសាអង់គ្លេសទេ។ សូមអភ័យទោស ខ្ញុំច្រឡំ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ពីព្រោះថាពុំមានការបកប្រែជាភាសាខ្មែរ-បារាំងនោះទេ។ ERN ជាភាសាអង់គ្លេសគឺ 00446588, ជាភាសាខ្មែរ គឺ 00388697 បាទ ពុំមាន ERN ជាភាសាបារាំងទេ ឥឡូវនេះ។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបាននិយាយថា៖ "ក្នុងឆ្នាំ១៩៧៧ ខ្ញុំត្រូវបានគេដកចេញពីសហគមន៍ ហើយបានដាក់ឲ្យធ្វើការនៅកន្លែងធ្វើការដែលសាច់ញាតិរបស់ពួកក្បត់ធ្វើការ។ កន្លែងធ្វើការហ្នឹងវានៅឆ្ងាយពីសហគមន៍"។

ខ្ញុំសូមលើកយកដើមបណ្ដឹងរដ្ឋប្បវេណី D22/342, ERN ជាភាសាបារាំងគឺ 00920506, ជាភាសាអង់គ្លេស គឺ00864551, ជាភាសាខ្មែរគឺ00484873។ គាត់លើកឡើងដូចតទៅនេះ -- ខ្ញុំសូមបញ្ជាក់ថានៅពេលនោះគាត់នៅកំពង់ចាម។ ខ្ញុំសូមដកស្រង់៖ "កក្កដា ឆ្នាំ១៩៧៨ អង្គការខ្មែរក្រហមបានបញ្ជូនឪពុកម្ដាយ បងប្អូន និងញាតិសន្ដានខ្ញុំ១៦នាក់ មានឈ្មោះដូចខាងក្រោមយកទៅសម្លាប់នៅខេត្តកំពង់ចាម ដោយចោទថាជាខ្មាំងខ្សែរយៈ សោ ភឹម មេខ្មែរក្រហមក្បត់អង្គការបដិវត្តន៍"។

[១៤:២១:៣២]

ឥឡូវនេះ ខ្ញុំសូមដកស្រង់យកដើមបណ្ដឹងរដ្ឋប្បវេណី E3/3963, ERN ជាភាសាបារាំងគឺ 00333881, ជាភាសាអង់គ្លេសគឺ 00242252, ជាភាសាខ្មែរគឺ 00198 -- សូមអានម្ដងទៀត 0019 8403។ គាត់លើកឡើងដូចតទៅនេះ "គឺជាគុកឥតជញ្ជាំង នៅនេះសុទ្ធតែស្រី ប្រពន្ធទាហាន និងប្រជាជនថ្មី ឬក៏ "អ្នក១៧មេសា" ដែលគេឲ្យតែបបរលាយព្រលឹតក្នុងមួយខ្ទះឆ្នោតតែប៉ុណ្ណោះ"។

ឥឡូវខ្ញុំសូមលើកយកដើមបណ្ដឹងរដ្ឋប្បវេណី D22/3461 ដែលនិយាយអំពីគ្រួសារទាហាន លន់ នល់ និងរាជការលន់នល់ -- រដ្ឋការលន់នល់ ហើយនិងក្រុមគ្រួសារគាត់តែម្ដង។ ERN ជាភាសាបារាំងគឺ 00859055, ជាភាសាអង់គ្លេសគឺ 00856522, ជាភាសាខ្មែរគឺ 00566393។ គាត់លើកឡើងដូចតទៅនេះ៖ "៧ថ្ងៃក្រោយមកពួកវាបានដឹងថា ខ្ញុំជាប្រពន្ធទាហាន អ៊ីចឹងក៏មកចាប់ខ្ញុំយកទៅធ្វើបាប"។

លោកប្រធាន ខ្ញុំចប់ក្នុងការបង្ហាញអត្ថបទទាក់ទងទៅនឹងគោលនយោបាយ ទាក់ទងនឹងសមាសធាតុមិនល្អហើយ។ ឥឡូវខ្ញុំសូមចូលទៅនិយាយអំពីក្រុមជាក់លាក់ គោលនយោបាយពាក់ព័ន្ធនឹងក្រុមជាក់លាក់។ ប៉ុន្តែបើលោកប្រធានគិតសុំសម្រាកឥឡូវ អាចសម្រាកឥឡូវបានលោកប្រធាន ឬក៏ឲ្យខ្ញុំបន្តទៀត?

**ប្រធានអង្គជំនុំ៖**

លោកស្រីត្រូវការពេលវេលាទំនងប្រហែលជាប៉ុន្មានទៀត?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំចង់និយាយអំពីគោលនយោបាយពីរទៀត។ បើសិនជាខ្ញុំគិតមិនច្រឡំទេ ឥឡូវនេះខ្ញុំចំណាយព្រឹកមិញហ្នឹងអស់២០នាទី ឥឡូវនេះ៥០នាទី។ ខ្ញុំគិតថា ខ្ញុំត្រូវការប្រហែលជា៥០នាទីទៀតដែរលោកប្រធាន។ ខ្ញុំមិនដឹងថារសៀលនេះខ្ញុំអាចបង្ហាញចប់ ឬក៏អត់ទេ ក៏ប៉ុន្តែបើសិនជាយ៉ាងម៉េចយ៉ាងម៉ាប្រហែលជាខ្ញុំត្រូវការព្រឹកស្អែកហ្នឹង៣០នាទីទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមស្របនឹងសម្រាកដែលហើយ។ អង្គជំនុំជម្រះប្រកាសសម្រាបចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:២៥នាទី ដល់ម៉ោង ១៤:៤៨នាទី)*

[១៤:៤៨:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះ ខ្ញុំសូមលើកឡើងអំពីគោលនយោបាយពាក់ព័ន្ធទៅនឹងក្រុមជាក់លាក់មួយចំនួន ក្រុមគោលដៅ។ ជាបឋមខ្ញុំសូមលើកឡើងពីក្រុមដែលត្រូវបានកំណត់នៅក្នុងនយោបាយរបស់ខ្មែរក្រហម។ ខ្ញុំសូមលើកឡើងនូវឯកសារ D246/10។ ដើមបណ្តឹងរដ្ឋប្បវេណីនេះគាត់នៅព្រៃវែងនៅពេលនោះ។ ខ្ញុំសូមដកស្រង់សម្រង់ពីររបស់គាត់ ERN ជាភាសាបារាំងគឺ 00381128, ជាភាសាអង់គ្លេស00373230, ជាភាសាខ្មែរ00381020។ និងទំព័របន្ទាប់សម្រាប់សម្រង់ទី២។

ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានសរសេរថា៖“អង្គការបានចែកក្រមាពណ៌ខៀវ-សឲ្យប្រជាជន

ម្នាក់ៗ។ យើងរង់ចាំ១ថ្ងៃ ហើយត្រូវបានគេឲ្យឡើងជិះឡានយោធាចិនឆ្ពោះទៅស្ថានីយ៍រថភ្លើង។ យើងឡើងជិះរថភ្លើងនៅពេលយប់ ហើយយើងបានធ្វើដំណើរជាច្រើនម៉ោង។ នៅពេលដែលយើងមកដល់ស្រុកបាកាន គឺពេលយប់ម្តងទៀតហើយ។ យើងទទួលបានអាហារនៅពេលដែលយើងចូលរថភ្លើង"។

ហើយទៅនឹងសំណួរដែលសួរដោយសហចៅក្រមស៊ើបអង្កេត ដែលប្រាប់ថា "សូមរៀបរាប់ខ្ញុំអំពីក្រមាពណ៌ស និងពណ៌ខៀវ? គាត់ឆ្លើយថា អ្នកដែលត្រូវគេឲ្យក្រមាពណ៌សនិងខៀវ ជាអ្នកមកពីភូមិភាគបូព៌ានៃប្រទេសកម្ពុជា ដែលនឹងត្រូវសម្លាប់ ពីព្រោះយើងជាមុខសញ្ញាដែលត្រូវបានគេចាត់ទុកថាជាសត្រូវ ដោយសារយើងនៅជិតព្រំដែនវៀតណាម និងត្រូវបានគេមើលឃើញថាជាមិត្តរបស់វៀត-ណាម។ ខ្មែរក្រហមបានចែកក្រមាទាំងនេះដើម្បីកំណត់ចំណាំអ្នកដែលនឹងត្រូវសម្លាប់"។

[១៤:៥១:៥២]

ឯកសារមួយទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺ D22/33 គាត់ពេលនោះនៅតាកែវ។ គាត់និយាយអំពីពុទ្ធសាសនិកជន។ ជាភាសាបារាំង 00901477, ជាភាសាអង់គ្លេស 00332196, ជាភាសាខ្មែរ 00279767។ គាត់បានរៀបរាប់ថា៖ "បន្ទាប់ពីចូលឆ្នាំ វត្តភ្នំឆ្នាក្លាយជាកន្លែងគុកសម្រាប់ធ្វើទារុណកម្មដល់ប្រជាជនទាំងឡាយដែលត្រូវបានគេគិតថាជាខ្មាំង(សត្រូវរបស់អង្គការ)។ ដោយសារតែអ្នកបួសជាច្រើននៅជាលោកសង្ឃនៅក្នុងវត្តភ្នំឆ្នានោះ ក៏មានការកោះហៅជាថ្មីផ្តល់ឲ្យទៅធ្វើការកែប្រែ។ ពេលនោះ ខ្ញុំនិងអ្នកបួសដទៃទៀត ត្រូវបានអង្គការបង្ខំឲ្យផ្សឹកពីសង្ឃ"។

ឥឡូវនេះ ខ្ញុំសូមលើកឡើងអំពីឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី D22/3675a ដែលជាជនជាតិចាម ដែលពេលនេះគាត់នៅកំពង់ឆ្នាំង។ ERN ជាភាសាបារាំងគឺ 00894118, អង់គ្លេស 0089 1063, ខ្មែរ 00588456។ គាត់បានរៀបរាប់ថា-- ខ្ញុំសូមដកស្រង់ "ចំពោះបញ្ហាសាសនា ប្រពៃណី និងទំនៀមទម្លាប់របស់បងប្អូនជនជាតិចាម ពួកខ្មែរក្រហមបានធ្វើការហាមប្រាមឲ្យអនុវត្តជាដាច់ខាតដែលមានដូចជា មិនឲ្យគោរពសាសនា មិនឲ្យមានការធ្វើថ្វាយបង្គំព្រះ បង្ខំឲ្យពួកខ្ញុំហូបសាច់ជ្រូក បង្ខំឲ្យស្រីៗត្រូវកាត់សក់ខ្លី និងហាមកុំឲ្យនិយាយភាសាចាម។ ពួកវាបានបំផ្លាញក្តារសម្រាប់គោរពព្រះរបស់ពួកយើង។ ពួកវាឡើងគ្រប់ផ្ទះរបស់បងប្អូនចាមដើម្បីស្វែងរកគម្ពីគូរ៉ង់ និងសៀវភៅដទៃទៀត ឲ្យតែមានអក្សរចាម វាយកទៅបំផ្លិចបំផ្លាញចោលអស់គ្មានសល់។ ពួកវាបានដុតដំផ្លាញព្រះវិហារសាសនា មិនឲ្យគោរព ដោយយកព្រះវិហារនោះទៅផ្ទុកស្បៀងចំណីអាហារវិញ"។

[១៤:៥៤:៥៦]

ឥឡូវនេះ ខ្ញុំសូមលើកឡើងនូវឯកសារ D246/15។ ដែលគាត់ពេលនោះនៅពោធិ៍សាត់។ គាត់លើកឡើងអំពីស្ថានភាពរបស់ខ្មែរក្រោម។ ជាភាសាបារាំង 00426390, ជាភាសាអង់គ្លេស 00388620, ជាភាសាខ្មែរ 00385135។ គាត់ឆ្លើយទៅនឹងសំណួររបស់អ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតថា "តើមូលហេតុអ្វីដែលលោកត្រូវបានចាប់ខ្លួននៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧? ឆ្លើយ៖ ពីព្រោះនៅពេលនោះ ពួកខ្មែរបានចាប់ផ្តើមចម្រាញ់ប្រជាជនដើម្បីស្វែងរកខ្មែរកម្ពុជាក្រោម ដែលពួកគេចោទប្រកាន់ថាជាខ្មែរយួន -- ជាខ្មែរយួន។ ខ្ញុំត្រូវបានគេចាប់ចង និងបញ្ជូនទៅកាន់មន្ទីរឃុំឃាំងនៅភូមិវាល"។

ពេលនេះ ខ្ញុំសូមលើកឡើងនូវឯកសារ D22/2011។ គាត់ពេលនោះគឺនៅពោធិ៍សាត់។ គាត់និយាយអំពីស្ថានភាពរបស់អតីតទាហាន លន់ នល់។ ជាភាសាបារាំង 00900237, ជាភាសាអង់គ្លេស 00893689, ជាភាសាខ្មែរ 00541770។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះគាត់បានរៀបរាប់ថា-- ខ្ញុំសូមដកស្រង់ "ក្នុងពេលស្ទូង ទាហាន និងឈ្លបខ្មែរក្រហមត្រួតពិនិត្យដែលជម្លៀសទៅបាក់រទេះ ពីព្រោះគេចាត់ទុកពួកគាត់ជាប្រជាជន១៧មេសា។ ពួកគេនៅបន្តប្រកាសថា អ្នកណាជាមន្ត្រីរដ្ឋការ អាជីវករ សិស្សនិស្សិត ត្រូវតែនិយាយការពិត ដើម្បីទៅកាន់មុខតំណែងចាស់វិញ។ ជាបន្តិចដងៗ អតីតរដ្ឋការទាំងនោះ ត្រូវពួកវាយកទៅ ហើយមិនឃើញត្រឡប់មកវិញទេ"។ ឥឡូវនេះខ្ញុំសូមលើកឡើងនូវដើមបណ្តឹងរដ្ឋប្បវេណី D404/2/3.2--

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

[១៤:៥៨:០៧]

**កញ្ញា អង់តា ហ្គីសេស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ គឺចង់សួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី។ ឯកសារហ្នឹងយើងរកមើលនៅក្នុងសំណុំរឿង ហើយអត់មានឃើញលេខ E3 ទេ ហើយវាអត់មាននៅក្នុងកំណត់ជើងទំព័រនៅក្នុងដីកាដំណោះស្រាយនោះទេ។ ហើយនៅក្នុងឧបសម្ព័ន្ធនៃបញ្ជីរបស់ភាគី របស់សហព្រះរាជអាជ្ញា ឬក៏របស់ភាគីផ្សេងនោះ ក៏មានអត់ឃើញដែរ។ ដូច្នេះ ខ្ញុំគិតថាឯកសារនេះ ជាឯកសារថ្មី។ ដូច្នេះអង្គជំនុំជម្រះមិនគួរឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញឯកសារនេះនៅក្នុងសវនាការទេ លោកប្រធាន។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំនឹងពិនិត្យមើលថាតើមាននៅក្នុងបញ្ជី ឬក៏អត់? ខ្ញុំសូមបញ្ជាក់ថា ដោយសារតែឯកសារដើមបណ្ដឹងរដ្ឋប្បវេណីនេះ មិនទាន់ដាក់ឯកសារជាលេខ E3 នៅឡើយនោះទេ។ ដូច្នេះ ខ្ញុំគិតថាឯកសារនេះមាននៅក្នុងបញ្ជីរបស់ខ្ញុំ។ អ៊ីចឹងខ្ញុំមើលសិន បន្តិចទៀតនេះខ្ញុំនឹងឆ្លើយជូនលោកស្រីថាមាន ឬក៏មិនមាន។

ក្នុងពេលទន្ទឹងរង់ចាំពិនិត្យមើលនេះ ខ្ញុំសូមបន្តទៅមុខទៀតលោកប្រធាន។

[១៤:៥៩:៣៣]

**ប្រធានអង្គជំនុំ៖**

បន្តឯកសារផ្សេងទៀតទៅ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

ខ្ញុំអម្បាញ់មិញនេះ ខ្ញុំដូចជាមិនទាន់ច្បាស់ តើលោកមេធាវីការពារក្ដីគាត់ជំទាស់ទៅលើឯកសារមួយណា? D22/2011 ឬក៏យ៉ាងណា?

**កញ្ញា អង់តា ហ្គីសសេ៖**

គឺសូមជំទាស់ទៅនឹងឯកសារ D404/2/3.2.8។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណ។ ខ្ញុំចូលទៅចំណុចផ្សេងទៀតនៃគោលនយោបាយដែលប្រឆាំងទៅលើក្រុមគោលដៅមួយចំនួន ជាពិសេសពាក់ព័ន្ធទៅនឹងគោលដៅនៃនយោបាយនេះ គឺថាលុបបំបាត់ចោលនូវភាពខុសៗគ្នា។ ដូច្នេះ ខ្ញុំសូមលើកឡើងនូវឯកសារ D22/164។ ជាភាសាបារាំងគឺ 00898349, អង់គ្លេសគឺ 00417861, ខ្មែរ 00369050។ ខ្ញុំសូមដកស្រង់សម្រង់ខ្លីពីរចេញពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ។ ខ្ញុំសូមដកស្រង់ "នៅពេលនោះ ខ្មែរក្រហមបានចាត់ទុកចាមជាសត្រូវលេខ១ ខ្មែរក្រហមចង់បញ្ជូនចាមទៅសម្លាប់ចោលដោយទុកឲ្យពួកគាត់អត់ឃ្លាន និងមានជំងឺនៅក្នុងភូមិផ្សេងៗ"។

[១៥:០១:៤០]

បន្តមកទៀតដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានបន្ថែមទៀតថា៖ "នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបំបិទសាសនាសាសនាឥស្លាមគឺជាមុខព្រួញសំខាន់ក្នុងការកម្ចាត់ចោល។ ខ្មែរក្រហមហាមដាច់ខាតមិនឲ្យជនជាតិចាម សំពះយ៉ាំង (សំពះព្រះ) មិនឲ្យនិយាយភាសាចាម ហើយរាល់ទំនៀមទម្លាប់របស់ចាម

ដូចជាទទូរក្រមា ស្លៀកសម្លៀកបំពាក់ចាមត្រូវហាមឃាត់។

ខ្មែរក្រហមមិនអនុញ្ញាតឲ្យស្ត្រីជនជាតិចាមទុកសក់វែងឡើយ។ អ្នកដែលមិនព្រមអនុវត្តតាមត្រូវយកទៅសម្លាប់ចោល។ ឥឡូវនេះខ្ញុំចូលទៅឯកសារ D22/3849, ERN ជាភាសាបារាំង 00848071, អង់គ្លេស 00571043, ខ្មែរគឺ 00863995។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានរៀបរាប់អំពីគ្រួសាររបស់គាត់ និងសមាជិកគ្រួសារជាច្រើន។ គាត់បាននិយាយថា -- ខ្ញុំសូមដកស្រង់ "មូលហេតុតែមួយគត់ដែលពួកគាត់ត្រូវបានសម្លាប់នោះ គឺដោយសារថាយើងជាជនជាតិកម្ពុជា, ជនជាតិដើមចិន គឺខ្មែរ-ចិន"។

[១៥:០៣:៣៥]

ឥឡូវនេះខ្ញុំសូមលើកឡើងនូវឯកសារ D22/932a។ គាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីមកពីរតនគិរី ជនជាតិភាគតិចទំពួន។ ជាភាសាបារាំង 00898367, ជាភាសាអង់គ្លេស 00903179, ខ្មែរ 0058 2129។ គាត់បានរៀបរាប់ថា -- ខ្ញុំសូមដកស្រង់ "មុនឆ្នាំ១៩៧៥ ខ្ញុំរស់នៅក្នុងភូមិជ្រៃ ឃុំឡាបាំង ស្រុកលំផាត់ ខេត្តរតនគិរី មានជនជាតិទំពួនរស់នៅរាប់រយគ្រួសារ។ ជនជាតិទំពួនទាំងអស់ គោរពជំនឿគោរពទៅលើអារក្សអ្នកតា និងកប់នៅព្រៃកប់ខ្មោច។ ហើយមានមេកន្ទ្រាញពីរនាក់ ឈ្មោះ ក្រាក់ ទៀង និង ក្រាក់ ទុន ជាអ្នកមើលរៀបចំសែនព្រេនដល់អារក្សអ្នកតាសុំសេចក្ដីសុខជូនជនជាតិទំពួនទាំងអស់។

ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ក្រោមការគ្រប់គ្រងអំណាច ពេលនោះខ្មែរក្រហមបានធ្វើការផ្សព្វផ្សាយដល់ជនជាតិទំពួនទាំងអស់ឲ្យឈប់គោរពជំនឿទៅលើអារក្សអ្នកតា។ ចំណែកឯមេកន្ទ្រាញទាំងពីរនាក់ត្រូវបានអង្គការខ្មែរក្រហមហៅទៅរៀនសូត្រ ហើយក៏បាត់ខ្លួនរហូតដល់បច្ចុប្បន្ន។ ចាប់ពីពេលនោះជនជាតិទំពួនទាំងអស់នៅក្នុងភូមិជ្រៃ លែងបានគោរពលើអារក្សអ្នកតា ខ្ទមអ្នកតា ព្រៃកប់ខ្មោចត្រូវបានបំផ្លាញចោលទាំងអស់"។

[១៥:០៦:០៤]

សុំលើកឡើងនូវដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិភាគតិចចារ៉ាយ គឺឯកសារ D22/489a, ជាភាសាបារាំង 00893691, ជាភាសាអង់គ្លេស 00891271, ខ្មែរ 00577131។ គាត់បានរៀបរាប់ថា "ក្រោយថ្ងៃទី១៧ មេសា ៧៥ ខ្មែរក្រហមបានឃាត់មិនឲ្យជឿលើជំនឿអ្នកតា ពេលនោះគេបានចាត់តាំងជនជាតិចារ៉ាយមួយឈ្មោះ រុន ជីន ឲ្យធ្វើជាប្រធានសហករណ៍។ គាត់ជាអ្នកផ្សព្វផ្សាយព័ត៌មានដើម្បីកុំឲ្យចារ៉ាយជឿទៅលើជំនឿអ្នកតា។ អាស្រ័យហេតុនេះហើយបានជាពួកគាត់លែងបានរៀបចំពិធីបុណ្យសាសនាអ្វីទៀតហើយ"។

ឥឡូវនេះខ្ញុំចូលទៅឯកសារដើមបណ្ដឹងរដ្ឋប្បវេណី D22/1651a, ERN ជាភាសាបារាំង 0089 8045, អង់គ្លេស 00903220, ខ្មែរ 00583194។ ពេលនោះគឺគាត់នៅកំពង់ចាម។ គាត់បានរៀបរាប់ថា៖ "វាហាមមិនឲ្យមានជំនឿលើសាសនាណាទេ"។ ហើយចុះក្រោមមកទៀតគាត់បានបន្ថែមទៀតថា៖ "ខ្ញុំមិនដឹងពីការសម្លាប់ព្រះសង្ឃទេ ក៏ប៉ុន្តែខ្ញុំដឹងថាវាផ្សឹក ខ្មែរក្រហមឲ្យមកធ្វើការនៅតាមមូលដ្ឋាន"។

[១៥:០៨:១៩]

ឥឡូវនេះខ្ញុំចូលដល់ឯកសារ D22/2014a, ជាភាសាបារាំង ERN 00903105, ជាភាសាខ្មែរ-- សុំទោសគឺ អង់គ្លេសទេគឺ 00890965, ខ្មែរ ERN00580737។ គាត់បានរៀបរាប់អំពីព្រះពុទ្ធសាសនា គាត់លើកឡើងថា៖ "នៅវត្តដំណាក់ត្រយឹង ខ្ញុំពុំឃើញមានរូបព្រះពុទ្ធរូប និងពុំឃើញមានលោកសង្ឃទេ វិហារបាក់បែកអស់។ ខ្ញុំឮសូរប្រជាជនដូចគ្នានិយាយថា វត្តដំណាក់ត្រយឹងនេះជាគុកដែលសម្រាប់ដាក់អ្នកទោស"។

ដើមបណ្ដឹងរដ្ឋប្បវេណី D22/3518a, ERN ជាភាសាបារាំង 00898089, ជាភាសាអង់គ្លេស 00856209, ខ្មែរ 00585460។ គាត់បានរៀបរាប់ថា៖ "ពួកខ្មែរក្រហមបានបង្ខំឲ្យហូបសាច់ជ្រូក បើមិនហូបគេសម្លាប់ចោល។ ដូច្នេះនាងខ្ញុំបង្ខំចិត្តត្រូវតែហូប។ ពួកវាតែងតែនិយាយថា ពួកអាចាមត្រូវឲ្យហូបសាច់ជ្រូកមិនហូបត្រូវតែយកវាទៅសម្លាប់ចោលឲ្យអស់"។

[១៥:១០:០៤]

ឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី D22/3532a, ERN ជាភាសាបារាំង 00891055, ជាភាសាអង់គ្លេស 00891053, ជាភាសាខ្មែរ 00585427។ គាត់បានរៀបរាប់ថា៖ "វត្តសំរោងក្នុងស្រុកទូកមាស ត្រូវបានកម្ទេចចោលដើម្បីធ្វើជារោងបាយ។ វិហារឥស្លាមត្រូវគេយកទៅធ្វើទ្រុងជ្រូក ហើយបងប្អូនខ្មែរឥស្លាមត្រូវបានគេបង្ខំឲ្យហូបសាច់ជ្រូក បើមិនហូបគេនឹងសម្លាប់ចោល។ បន្ទាប់មកពួកវាក៏បង្ខំឲ្យពួកយើងចិញ្ចឹមជ្រូកទៀតផង។ គម្ពីរកូរ៉ាន់ ត្រូវបានវាកម្ទេចចោលគ្មានសល់។ ការសំពះយ៉ាំង ត្រូវបានហាមឃាត់ជាដាច់ខាត បើប៊ានធ្វើនឹងត្រូវសម្លាប់ចោល"។

ទិដ្ឋភាពចុងក្រោយពាក់ព័ន្ធទៅនឹងគោលនយោបាយទៅលើក្រុមគោលដៅមួយចំនួន ជាពិសេសគឺពាក់ព័ន្ធនឹងទាហាន និងមន្ត្រីរដ្ឋការរបស់សាធារណរដ្ឋខ្មែរ។ ខ្ញុំសូមលើកឡើងនូវឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីលេខ D22/3។ ដែលគាត់នៅសៀមរាបពេលនោះ។ ជាភាសាបារាំង 00632663, ជាភាសាអង់គ្លេស ERN 00156856, ខ្មែរ 00157098។ គាត់ឆ្លើយថា៖ "នៅថ្ងៃទី១៨ មេសា ឆ្នាំ

១៩៧៥ មន្ត្រីរដ្ឋការនៅខេត្តសៀមរាប ត្រូវបានកោះហៅឲ្យទៅប្រជុំនៅសាលាខេត្តសៀមរាប។ នៅក្នុងកិច្ចប្រជុំនោះ គេបានប្រកាសតម្រូវឲ្យមន្ត្រីរដ្ឋការទៅទទួលការអប់រំចំនួន៣ថ្ងៃដើម្បីទទួលសម្តេចនរោត្តមសីហនុ ដោយប្រាប់ថា មិនចាំបាច់យកអីវ៉ាន់ទៅជាមួយនោះទេ។ គេមិនឃើញមន្ត្រីរដ្ឋការដែលត្រូវគេយកទៅអប់រំនោះត្រឡប់មកវិញទេ។ នៅសម័យនោះ ខ្ញុំជាជាងជួសជុលម៉ូតូ ប៉ុន្តែខ្ញុំមិនមែនជាមន្ត្រីរដ្ឋការទេ។ ដូច្នេះ ខ្ញុំមិនត្រូវបានគេតម្រូវឲ្យទៅអប់រំនោះទេ។ មន្ត្រីរដ្ឋការទាំងអស់នោះត្រូវយកទៅសម្លាប់ ពីព្រោះខ្ញុំបានឃើញសាកសពជាច្រើននៅក្នុងលេណដ្ឋាន នៅបារាយទឹកថ្លា ដែលនៅទីនោះធ្លាប់ជាសមរភូមិប្រយុទ្ធរវាងទាហាន លន់ នល់ និងទាហានខ្មែរក្រហម"។

[១៥:១៣:០១]

ពាក់ព័ន្ធទៅនឹងទិដ្ឋភាពនេះដដែល ខ្ញុំនឹងលើកឡើងនូវឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីលេខ D246/13, ERN ជាភាសាបារាំង 00424100, ជាភាសាអង់គ្លេស គឺ00387500, ខ្មែរ 00385096។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គាត់នៅពោធិ៍សាត់។ សហចៅក្រមស៊ើបអង្កេតបានស្តាប់ចម្លើយរបស់គាត់៖ "សំណួរ៖ តើឪពុករបស់លោកស្រីជាទាហាន លន់ នល់ មែនទេ? ចម្លើយ៖ គាត់ជាអតីតយោធារបស់សម្តេចឪ។ បន្ទាប់មកទៀត គាត់ក្លាយទៅជាទាហានលន់ នល់ ហេតុនេះហើយបានជាខ្មែរក្រហមបាញ់សម្លាប់គាត់។ មិនមែនមានតែឪពុកខ្ញុំម្នាក់ទេដែលត្រូវបានបាញ់សម្លាប់នៅពេលនោះ ប៉ុន្តែមានមនុស្សផងទៃទៀតក៏ត្រូវបានបាញ់សម្លាប់ផងដែរ ព្រោះពួកគាត់មិនអាចរត់រួច"។

[១៥:១៤:១៩]

ពាក់ព័ន្ធទៅនឹងបញ្ហាទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ដដែលនេះ ខ្ញុំនឹងអាននូវសម្រង់របស់ដើមបណ្តឹងរដ្ឋប្បវេណី D22/1999, ជាភាសាបារាំង 00576068, ជាភាសាអង់គ្លេស 00842172, ជាភាសាខ្មែរ 00540448។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏នៅពោធិ៍សាត់ផងដែរ។ គាត់បានរៀបរាប់ថា៖ "១ខែក្រោយមកខ្ញុំទៅភូមិទួលព្រុំ ឃុំកោះគរ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ គ្រួសាររបស់ខ្ញុំចូលទៅរស់នៅមិនទាន់បានស្រួលបួលស្រាប់តែពេលនោះប្រហែលជាខែមិថុនា ឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំឈ្មោះ វ៉ា ណន ត្រូវបានកងទ័ពខ្មែរក្រហមដែលខ្ញុំមិនបានស្គាល់ឈ្មោះ ចូលមកចាប់ឪពុករបស់ខ្ញុំយកទៅសម្លាប់ដោយគ្មានមូលហេតុ។ ហើយអ្នកដែលមកចាប់ឪពុករបស់ខ្ញុំនោះមានគ្នាចំនួនបួននាក់។ ប៉ុន្តែខ្ញុំមិនដែលស្គាល់ពួកគេទេ ហើយពួកទាំងបួននោះខ្ញុំដឹងថាពួកគេដឹងថាច្បាស់ឪពុករបស់ខ្ញុំធ្វើជាប៉ូលិសក្នុងរបប លន់ នល់។ គឺការពិតឪពុករបស់ខ្ញុំពិតជាធ្វើប៉ូលិសនៅក្នុងរបប លន់ នល់ ពិតប្រាកដមែន។

ហើយក្រោយមកទើបខ្ញុំដឹងឪពុករបស់ខ្ញុំ វ៉ា ណន ត្រូវកងទ័ពខ្មែរក្រហមយកទៅវាយចោលនៅឯជើងភ្នំ ស្រុកបាកាន ខេត្តពោធិ៍សាត់"។

[១៥:១៦:០៥]

ខ្ញុំសូមលើកឡើងនូវឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីលេខD246/14, ERNជាភាសាបារាំង គឺ 00424111, ជាភាសាអង់គ្លេស 00387497, ខ្មែរ 00385092។ គាត់លើកឡើងអំពីការចាប់ខ្លួន ហើយគាត់ឆ្លើយទៅនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេត "តើលោកដឹងថាហេតុអ្វីបានជាគ្រួសារខ្មែរកម្ពុជាក្រោមមួយនេះត្រូវបានគេចាប់ខ្លួនទេ? ឆ្លើយ៖ ខ្ញុំដឹងថាគ្រួសារនេះត្រូវបានគេចោទថាជាយួន ឬវៀតណាម"។

ឥឡូវនេះខ្ញុំសូមលើកឡើងនូវឯកសារ D22/266, ERNជាភាសាបារាំង 00894013, ជាភាសាអង់គ្លេស 00890971, ជាភាសាខ្មែរ 00544536។ ពេលនោះគាត់នៅស្វាយរៀង គាត់បានរៀបរាប់ថា "ដោយឮថាវៀតណាមនឹងជិតចូលមកដល់ហើយ ខ្មែរក្រហមបានធ្វើការអង្កេតដើម្បីរកមើលមនុស្សដែលមកពីស្វាយរៀង។ ពួកគេយកទៅសម្លាប់ចោល សូម្បីតែទារកនៅក្នុងអង្រឹងនោះក៏ពួកវាមិនទុកដែរ ពីព្រោះពួកវាថាពួកស្វាយរៀងគឺជាយួន"។

[១៥:១៨:០៦]

ឯកសារចុងក្រោយពាក់ព័ន្ធទៅនឹងគោលនយោបាយនេះ ខ្ញុំសូមលើកឡើងនូវឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីលេខ D246/7, ERNជាភាសាបារាំងគឺ 00426371, ជាភាសាអង់គ្លេស 0038 4413, ជាភាសាខ្មែរ 00373404។ គាត់ឆ្លើយទៅនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធទៅនឹងបងប្រុសរបស់លោកដែលត្រូវជាលោកសង្ឃដែលត្រូវបានគេចាប់ដោយខ្មែរក្រហម។ "សំណួរ៖ ហេតុអ្វីបានជាលោកស្រីដឹងថា បងប្រុសឈ្មោះ ឡុង វ៉ាន់នី ត្រូវបានគេយកទៅសម្លាប់? ឆ្លើយ៖ ខ្ញុំគិតថាគាត់ជាអ្នកចេះដឹង និងតែងតែរិះគន់ខ្មែរក្រហម។ ហេតុដូច្នេះហើយបានជាគេយកគាត់ទៅសម្លាប់ចោល"។ ខ្ញុំសូមបញ្ចប់ការបង្ហាញឯកសារពាក់ព័ន្ធទៅនឹងគោលនយោបាយ។

ឥឡូវនេះខ្ញុំសូមអនុញ្ញាតក្នុងការពិនិត្យមើលទៅលើឯកសារ ដែលមេធាវីការពារក្ដី ខៀវ សំផន បានជំទាស់អម្បាញ់មិញនេះ។

គេប្រាប់ខ្ញុំថា ឯកសារ D404/2/3.2.8 នេះមាននៅក្នុងបញ្ជីយើងទាំងអស់ ហើយជាពិសេសនោះគឺនៅបញ្ជីថ្ងៃទី០៤ មីនា ដែលនៅក្នុងបញ្ជីនោះ ឯកសារនេះបានទទួលលេខថ្មីគឺ D22/3820a។

ឥឡូវខ្ញុំសូមលើកនិយាយពីឯកសារនេះដោយសង្ខេប។ ERN ជាភាសាបារាំងគឺ 00899194, ជាភាសាអង់គ្លេសគឺ 00607801, ជាភាសាខ្មែរ 00615766។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបានលើកឡើងដូចតទៅនេះ "ឪពុករបស់ខ្ញុំបានមកដល់មន្ទីរពេទ្យ ហើយបានឃើញសាកសពម្តាយរបស់ខ្ញុំ ហើយនៅមានកំដៅនៅឡើយ។ ឪពុកខ្ញុំត្រូវបានគេសម្លាប់នៅឆ្នាំ១៩៧៧ គាត់ត្រូវបានគេចោទប្រកាន់ថា ជាមូលធន ឬក៏ពួកសក្តិភូមិ។ ឪពុកខ្ញុំជាជនជាតិចិនមកពីប្រទេសចិន។ ម្តាយខ្ញុំក៏ជាចិនដែរ។ ឪពុកខ្ញុំត្រូវបានសម្លាប់ដោយសារគាត់ជាចិន ហើយដោយសារតែគាត់ជាអ្នកមាន។ កងឈ្លបហើយនិងកម្មាភិបាលទាំងអស់ធ្លាប់រស់នៅក្នុងសហគមន៍ជាមួយឪពុកម្តាយរបស់ខ្ញុំ។ ដូច្នេះហើយគេដឹងថា ឪពុកម្តាយខ្ញុំជាចិន"។ បើអ៊ីចឹង ខ្ញុំសូមបញ្ចប់ពីការបង្ហាញឯកសារលើគោលនយោបាយនេះ ហើយខ្ញុំនឹងចូលទៅដល់គោលនយោបាយលើការរៀបការដោយបង្ខំ។

[១៥:២១:៤១]

លោកប្រធាន ជាថ្មីម្តងទៀត ខ្ញុំនិយាយអំពីទិសដៅនៃគោលនយោបាយទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ការរៀបការ ឬក៏រៀបការដោយបង្ខំ ដូចដែលសហព្រះរាជអាជ្ញាបានវិភាគកាលពីព្រឹកមិញរួចមកហើយ។ ហើយជាបឋមហ្នឹង ខ្ញុំសូមលើកយកចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលជាធាតុសំខាន់មួយនៃគោលនយោបាយនេះ គឺថាការរៀបការនេះ ត្រូវតែអនុញ្ញាត ហើយគោរពក្បួនច្បាប់ត្រឹមត្រូវ ដោយអង្គការ ឬក៏អាជ្ញាធរតាមមូលដ្ឋានជាដើម។

ជាបឋម ខ្ញុំសូមលើកយកដើមបណ្តឹងរដ្ឋប្បវេណី D22/503, ERN ជាភាសាបារាំងគឺ 0091 6922, ERN ជាភាសាអង់គ្លេសគឺ 00891273, ហើយនិងជាភាសាខ្មែរគឺ 00496605។ ដើមបណ្តឹងរដ្ឋប្បវេណីនេះ និយាយដូចតទៅនេះ "នៅឆ្នាំមួយពាន់-- ចុងឆ្នាំ១៩៧៨ គេបង្ខំឲ្យខ្ញុំរៀបការជាមួយកម្មាភិបាល សេង ហាន ដែលបានស្នើឲ្យអង្គការរៀបការជាមួយខ្ញុំ។ អង្គការបានទទួលសំណើរបស់គាត់ ហើយបានរៀបចំរៀបការ ដែលនៅក្នុងឱកាសនោះ យើងត្រូវតែធ្វើការប្តេជ្ញាជាមួយគ្នា"។

[១៥:២៣:១៣]

ដើមបណ្តឹងរដ្ឋប្បវេណី D22/506។ ERN ជាភាសាបារាំងគឺ 00893515, ជាភាសាអង់គ្លេសគឺ 00891274, ហើយជាភាសាខ្មែរគឺ 00496650-51។ គាត់លើកឡើងដូចតទៅនេះ សូមដកស្រង់ "ដោយសំណាងល្អ ខ្ញុំបានគេចពីការរៀបការនេះរួច ការបង្ខំនេះរួច ក៏ប៉ុន្តែខ្ញុំពុំមានឱកាសណាគេចរួចទេ នៅលើទី៣នេះ ពីព្រោះថា លោក យុង ដែលត្រូវរៀបការ -- រៀបចំរៀបការដោយបង្ខំនោះបាត់ទៅ

ហើយអ្នកផ្សេងមក ពីព្រោះថាលោក យុង នេះ ត្រូវបានអង្គការចាប់ហើយ យកទៅសម្លាប់ហើយ ដោយសារតែគេចោទថាគាត់ហ្នឹង ក្បត់អង្គការ"។

ឥឡូវនេះ ខ្ញុំសូមលើកយកដើមបណ្ដឹងរដ្ឋប្បវេណី D22/64a, ERN ជាភាសាបារាំងគឺ 0089 4119, ERN ជាភាសាអង់គ្លេសគឺ 00891282, ជាភាសាខ្មែរគឺ 00578236។ គាត់លើកឡើងដូចតទៅនេះ៖ "ខ្ញុំមិនប៊ានជំទាស់ទេ ដោយសារមិត្ត អ៊ុន ប្រាប់ខ្ញុំថាគ្មានណាអាចជំទាស់បញ្ជាបានទេ។ គាត់បានលើកឡើងដូចតទៅនេះ នារីៗទាំងអស់ត្រូវតែគោរពបញ្ជាអង្គការ បើសិនជាអ្នកណាម្នាក់មិនគោរព អ្នកនោះត្រូវតែសម្លាប់ចោល"។

[១៥:២៥:០៣]

ដើមបណ្ដឹងរដ្ឋប្បវេណី D22/16a, ERN ជាភាសាបារាំងគឺ 00881712, អង់គ្លេសគឺ 0085 3936 ទៅដល់ 37 ហើយនិងជាភាសាខ្មែរគឺ 00584547 ទៅដល់ 48។ ដើមបណ្ដឹងរដ្ឋប្បវេណី រូបនេះបានរៀបរាប់ថា -- រៀបរាប់អំពីការរៀបការរបស់គាត់ក្នុងពេលជាមួយនឹង៦០គូផ្សេងទៀត។ គាត់និយាយដូចតទៅនេះ៖ "មុនពេលរៀបការប្រធានភូមិគេធ្វើសុន្ទរកថាមួយដើម្បីរំឭកយើងថា មិនត្រូវបណ្ដែតបណ្ដោយខ្លួនទេ ហើយត្រូវតែខំប្រឹងប្រែងដើម្បីធ្វើការបម្រើអង្គការ ហើយនិងសុំឲ្យគូរៀបការទាំងអស់ឲ្យស្រឡាញ់គ្នា ហើយនិងស្មោះត្រង់ជាមួយអង្គការ។ ហើយគេបានសុំឲ្យខ្ញុំនិយាយជូសមុខឲ្យគូរៀបការជាមួយគ្នាទាំង៦០គូទៀត"។

ឥឡូវនេះខ្ញុំសូមលើកគោលការណ៍ ឬក៏សេចក្ដីណែនាំមួយចំនួនដែលអង្គការដាក់ចេញ ទាក់ទងទៅនឹងការរៀបការដោយបង្ខំ ឬក៏សម្ព័ន្ធ ឬក៏ឋានៈរបស់បុគ្គលទាំងឡាយដែលគេបង្ខំឲ្យរៀបការ។

[១៥:២៦:៣៧]

ខ្ញុំសូមដកស្រង់ដើមបណ្ដឹងរដ្ឋប្បវេណី E9/32.2.14, ERN ជាភាសាបារាំងគឺ 00891889, ERN ជាភាសាអង់គ្លេសគឺ 00891888, ជាភាសាខ្មែរគឺ 00678181។ គាត់លើកឡើងដូចតទៅនេះ៖ "ចុងឆ្នាំ៧៥ ខ្ញុំធ្វើការនៅក្នុងក្រសួងភ័ស្ដុភារដែលពេលនោះគេហៅថាមន្ទីរស-៨០។ ថ្ងៃមួយប្រធានមន្ទីរបានហៅខ្ញុំមកធ្វើទាំងអស់គ្នាដែលមានប្រហែល២០០នាក់ សុទ្ធតែធ្វើការជាមួយគ្នានៅទីនេះ។ នៅពេលប្រជុំមានស្ត្រីប្រហែលជាង៣០នាក់។ នៅទីនោះមានប្រធានម្នាក់ដែលក្នុងចំណោមបីនាក់នោះ ឈ្មោះ មុត, ភឹម ហើយនិង ផុន មិនដែលស្គាល់ -- មិនដឹងណាមួយនោះទេ ដែលបានអានន្ទូវបទបញ្ជាដែលចេញដោយថ្នាក់ដឹកនាំរបបនោះ។ ចំណុចខ្លះៗដូចជាចាប់ពីពេលនេះទៅសមាជិកមន្ទីរ៨០ អាចរៀប-

ការតែជាមួយគ្នាទេ។ ស្រឡាញ់គ្នាគឺមានព្រំដែនកំណត់ មិនអនុញ្ញាតឲ្យប្រើពាក្យអូនបង (ដែលជាពាក្យថាស្នេហាផ្អែមល្ហែម) ហើយមិនឲ្យសរសេរសំបុត្រស្នេហាឆ្លងឆ្លើយគ្នាទេ"។

ចុះបន្ទាត់មកទៀត "បុរសជាបក្ខជនត្រូវតែរៀបការជាមួយស្ត្រីជាបក្ខជនដែរ"។ ហើយចុះបន្ទាត់មកទៀត "ការរៀបចំពិធីអាពាហ៍ពិពាហ៍ពីនោះត្រូវលុបចោល"។

[១៥:២៨:៣៥]

ដើមបណ្តឹងរដ្ឋប្បវេណី D125/39, ERN ជាភាសាបារាំងគឺ 00272777, ជាភាសាអង់គ្លេសគឺ 00225533, ជាភាសាខ្មែរគឺ 00196824។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះលើកឡើងដូចតទៅនេះ សូមដកស្រង់ "ពេលដែលអ្នកទោសដែលគេចោទប្រកាន់ថាបានប្រព្រឹត្តកំហុសសីលធម៌ មានសាហាយត្រូវតែយកទៅអប់រំរយៈពេល៣ខែ។ អ្នកដែលប្រព្រឹត្តកំហុសមេម៉ាយ ឬពោះម៉ាយ ឬក៏នៅលីវត្រូវសុំឲ្យរៀបការ។ នេះគឺជាគោលនយោបាយថ្នាក់លើ"។

ឥឡូវនេះខ្ញុំសូមលើកយកដើមបណ្តឹងរដ្ឋប្បវេណី D199/18 ដែលកាលណោះ គាត់នៅក្រសួងកិច្ចការសង្គមកិច្ច។ ERN ជាភាសាបារាំងគឺ 00342208, ជាភាសាអង់គ្លេសគឺ 00345228, ភាសាខ្មែរគឺ 00349555 ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ លើកឡើងដូចតទៅនេះសូមដកស្រង់ "អ្នកស្រី ស៊ូជាប្រធានរបស់ខ្ញុំបានសម្រេចដោយមានការអនុញ្ញាតពី អៀង ធីរិទ្ធ ថាខ្ញុំត្រូវតែរៀបការជាមួយ វ៉ាសែ។ នៅសម័យនោះនៅក្រោមរបបខ្មែរក្រហម គឺមេជាអ្នកសម្រេចក្នុងបញ្ហាទាំងអស់នេះ។ យើងមិនអាចរៀបការជាមួយអ្នកណាដែលយើងចង់បាននោះទេ។ សម្រាប់រូបខ្ញុំ ខ្ញុំមានការជំពាក់ចិត្តចំពោះលេខាពិសេសរបស់ អៀង ធិរិទ្ធ ប៉ុន្តែខ្ញុំមិនប៊ានប្រឆាំងនឹងសេចក្តីសម្រេចនោះបានទេ ហើយជាពិសេសនោះខ្ញុំមិនអាចប៊ានបង្ហាញ ឬក៏មានទំនាក់ទំនងស្នេហាជាមួយបុរសណាម្នាក់បានទេ ពីព្រោះថាវាជាឧក្រិដ្ឋ-កម្មមួយ។ មុននឹងរៀបការជាមួយ វ៉ាសែ នោះ ខ្ញុំបានឃើញគាត់តែពីរដងប៉ុណ្ណោះ"។

[១៥:៣១:១៣]

គឺខ្ញុំសូមលើកយកដើមបណ្តឹងរដ្ឋប្បវេណី D278/2, ERN ជាភាសា បារាំងគឺ 00422432, ជាភាសាអង់គ្លេសគឺ 00400458, ជាភាសាខ្មែរគឺ 00390287។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ឆ្លើយតបទៅនឹងសំណួររបស់ចៅក្រមស៊ើបអង្កេតគាត់និយាយដូចតទៅនេះ "មិនមានអ្នកណាដែលប៊ានប្រកែកមិនរៀបការនោះទេ ពីព្រោះថាជាបញ្ជារបស់អង្គការ។ ក៏ប៉ុន្តែខ្ញុំមិនដឹងថាមានអ្វីកើតឡើងចំពោះអ្នកដែលប្រឆាំងនឹងបញ្ជានេះទេ។ ខ្មែរក្រហមមានគោលការណ៍របស់គេដែលថាអ្នកមូលដ្ឋានមិនអនុញ្ញាត

ឲ្យរៀបការជាមួយប្រជាជនថ្មីទេ”។ នេះជាការបកប្រែជាភាសាបារាំង។

ឥឡូវនេះខ្ញុំសូមលើកយកចម្លើយ បណ្តាចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទីមួយចំនួនទៀត ដែលបង្ហាញអំពីធាតុសំខាន់នៃគោលនយោបាយអត្ថិភាពនៃនយោបាយនេះ។ ហើយដែលបានរៀបរាប់ថា “អង្គការដឹកនាំត្រួតពិនិត្យរៀបចំ ហើយនិងកំណត់តម្រូវឲ្យមានការរៀបការដោយបង្ខំ”។

[១៥:៣២:១៦]

ខ្ញុំសូមលើកយកដើមបណ្តឹងរដ្ឋប្បវេណី D22/139a, ERN ជាភាសាបារាំង 00898344 ទៅដល់ 45, អង់គ្លេសគឺ 00863874 ទៅដល់ 75, ជាភាសាខ្មែរគឺ 00580448 ដល់ 49។ គាត់លើកឡើងដូចតទៅនេះ “នៅឆ្នាំ៧៧ ខែមេសា (មុនចូលឆ្នាំខ្មែរ) ពេលនោះអង្គការបក្សស្រុកបន្ទាយមាស ខេត្តកំពតឈ្មោះ ចាប បានចុះមកប្រជុំនៅឃុំទទុង ហើយបានរៀបចំកម្មវិធីអាពាហ៍ពិពាហ៍នៅក្នុងសហករណ៍ភូមិទួលខ្ពស់។ ដោយមុនថ្ងៃរៀបការ១ថ្ងៃអង្គការយុវជនមេភូមិបានដើរប្រាប់ឈ្មោះអ្នកដែលត្រូវរៀបការទាំងប្រុសស្រីឲ្យទៅចូលរួមប្រជុំនៅផ្ទះបាយកុំខាន ពីព្រោះអង្គការបក្សស្រុកមកជាអធិបតី”។

ក្រោមហ្នឹងបន្តិចគាត់បន្ថែមថា៖ ពិធីនេះបានចាប់ផ្តើមឡើងជាមួយនឹងប្រធានកងឈ្មោះ រុន មកពីភូមិព្រៃសំណាង ឃុំស្រែជា ស្រុកកំពង់ត្រាច។ គាត់បានឡើងប្រកាសហេតុ ហើយបើកកម្មវិធី “អង្គការមានផែនការថ្មី ត្រូវរៀបចំអាពាហ៍ពិពាហ៍ជាប្រវត្តិសាស្ត្រ ហើយនេះជាដំបូងក្នុងស្រុកបន្ទាយមាស ដែលរៀបចំដោយអង្គការបក្ស ស្រុកបានចុះមករៀបចំកម្មវិធីនេះ”។ បន្ទាប់មកទៀត មេកងនោះបានហៅឈ្មោះនិងប្រុសស្រី ខាងប្រុស ខាងស្រី។ កាលណោះមានចំនួន៤០គូ -- ៤២គូ ហើយមានមេមាយ ១២គូ ហើយនិងយុវជនយុវនារី៣០គូ។

ដើមបណ្តឹងរដ្ឋប្បវេណី D22/2974, លេខERNជាភាសាបារាំងគឺ00894114, ERN ជាភាសាអង់គ្លេស គឺ00891040, ជាភាសាខ្មែរគឺ 00559294។ គាត់បានលើកឡើងដូចតទៅនេះ “គូនីមួយៗត្រូវប្តេជ្ញាចិត្តបន្តបន្ទាប់គ្នា គេណែនាំឲ្យគេស្រឡាញ់គ្នា ហើយនិងបំពេញការងារដែលអង្គការដាក់ឲ្យ ហើយនិងខំប្រឹងប្រែងឲ្យ -- តាមដែលអាចធ្វើទៅបានដើម្បីបង្កើតកូនជូនបក្ស”។

[១៥:៣៦:១១]

ឯកសារ D22/620, ERN ជាភាសាបារាំងគឺ 00900951, ERN ជាភាសាអង់គ្លេសគឺ 00891279 ដល់ 80, ERN ជាភាសាខ្មែរគឺ 00499824 ដល់ 25។ គាត់លើកឡើងដូចតទៅនេះ “គេឲ្យយើងប្តេជ្ញាចិត្តតាមពាក្យដែលគេប្រាប់: ពីថ្ងៃនេះទៅ យើងក្លាយជាប្តីប្រពន្ធនឹងគ្នា យើងត្រូវតែ

ស្រឡាញ់គ្នា ហើយនិងខំប្រឹងប្រែងធ្វើការដើម្បីបម្រើអង្គការ ហើយនិងបង្កើតកូនឲ្យអង្គការ ហើយមិនត្រូវប្រឆាំងនឹងអង្គការទេ”។

ដើមបណ្តឹងរដ្ឋប្បវេណី D22/1291a, ERN ជាភាសាបារាំងគឺ 00893362, ជាភាសាអង់គ្លេសគឺ 00891223, ជាភាសាខ្មែរគឺ 00584380 ដល់ 81។ គាត់លើកឡើងដូចតទៅនេះ -- ទាក់ទងនឹងការរៀបការដោយបង្ខំ ដែលគេបង្ខំឲ្យគាត់ការ ហើយនិងនិយាយអំពីមេគាត់ម្នាក់។ គាត់និយាយថា៖ “អង្គការរៀបចំការរៀបការ ហើយត្រូវតែគោរពបទបញ្ជារបស់អង្គការ។ ខ្ញុំជំទាស់ ប៉ុន្តែឥតប្រយោជន៍ គាត់បានប្រាប់ខ្ញុំថាគេបានកំណត់ធ្វើយ៉ាងដូច្នេះហើយ អ៊ីចឹងត្រូវតែគោរពរាល់សេចក្តីសម្រេចរបស់អង្គការ។ អ៊ីចឹងខ្ញុំមិនអាចជំទាស់អ្វីបាននោះទេ។ ពេលនោះ ខ្ញុំស្ថិតនៅក្នុងរយៈពេលអប់រំក្នុងគុកដែលខ្ញុំត្រូវបានគេចោទថា ខ្ញុំជាជនក្បត់ ហើយខ្ញុំទទួលរងនូវការសួរចម្លើយផងដែរនៅពេលនោះ”។

[១៥:៣៨:២២]

ដើមបណ្តឹងរដ្ឋប្បវេណី D22/1067a, ERN ជាភាសាបារាំងគឺ 00578977, ERN ជាភាសាអង់គ្លេសគឺ 00846968, ជាភាសាខ្មែរគឺ 00578979 ដល់ 80។ ដើមបណ្តឹងរដ្ឋប្បវេណីនេះ លើកឡើងដូចតទៅនេះ “នៅប្រហែលពាក់កណ្តាលឆ្នាំ១៩៧៥ គេបង្ខំឲ្យខ្ញុំរៀបការ មកអូរបែកខ្អម បង្ខំឲ្យខ្ញុំមកអូរបែកខ្អម ឲ្យធ្វើស្រែចម្ការ ដោយសារប្រវត្តិរូបខ្ញុំអាក្រក់។ កាលណោះនោះ គេបានគំរាមកំហែងខ្ញុំ គេរំឭកខ្ញុំថា ខ្ញុំមានប្រវត្តិរូបអាក្រក់ គេថាខ្ញុំជាមនុស្សខ្ជិលច្រអូស ហើយថាឪពុកម្តាយខ្ញុំធ្វើការឲ្យរបបលន់ នល់ អ៊ីចឹងខ្ញុំត្រូវតែទទួលការរៀបការហ្នឹង បើមិនដូច្នោះទេ គេនឹងសម្លាប់ខ្ញុំ។ កាលនោះ ខ្ញុំភ័យណាស់ ពីព្រោះថាឪពុកម្តាយខ្ញុំ ជាប្រជាជន១៧មេសា”។

ដើមបណ្តឹងរដ្ឋប្បវេណី D22/1860 -- 3858a, ERN ជាភាសាបារាំងគឺ 00916921, ERN ជាភាសាអង់គ្លេសគឺ 00853176, ERN ជាភាសាខ្មែរគឺ 00584796។ “ពេលនោះគេបង្ខំឲ្យយើងស្បថ ហើយឲ្យចាប់ដៃគ្នាចំពោះមុខអង្គការថាយើងត្រូវតែស្រឡាញ់គ្នា ហើយនិងបម្រើអង្គការអស់មួយជីវិត”។ បញ្ចប់ការដកស្រង់។

[១៥:៤០:២៦]

ហើយជាចុងក្រោយដើមបណ្តឹងរដ្ឋប្បវេណី D22/2976, ERNជាភាសាបារាំងគឺ 00894115, ERN ជាភាសាអង់គ្លេសគឺ 00861042 និង ERN ជាភាសាខ្មែរគឺ 00559320។ ខ្ញុំសូមលើកពាក្យដែលសហព្រះរាជអាជ្ញាបានប្រើកាលពីព្រឹកមិញទាក់ទងទៅនឹងការរៀបការដោយបង្ខំនេះ។ ដើមបណ្តឹង

រដ្ឋប្បវេណីនេះលើកឡើងថា "ទោះជាយ៉ាងណាក៏ដោយ គេបានបង្ខំឲ្យទទួលការរៀបការដោយបង្ខំនេះ គេបានណែនាំខ្ញុំកុំឲ្យជំទាស់ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គការ ពីព្រោះថាអង្គការជាឪពុកម្ដាយរបស់យើង"។

លោកប្រធាន ខ្ញុំបញ្ចប់ការក្នុងការធ្វើបទបង្ហាញទាក់ទងនឹងអត្ថិភាពនៃគោលនយោបាយនេះហើយ។ ហើយខ្ញុំសូមចប់ត្រឹមនេះហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះ ពាក់ព័ន្ធជាមួយនឹងអង្គហេតុតួនាទីរបស់ជនជាប់ចោទ។

[១៥:៤២:០១]

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ សហភាគីរបស់យើងនឹងមកដល់ដើម្បីបង្ហាញឯកសារទាក់ទងនឹងតួនាទីរបស់លោក នួន ជា។ ប្រហែលជាត្រូវការពីរបីនាទីទៀតមកដល់ ហើយយើងភ្ញាក់ផ្អើលដែរដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញលឿនយ៉ាងនេះ។

អ៊ីចឹងខ្ញុំសូមអស់លោក លោកស្រីចៅក្រមមេត្តារង់ចាំបន្តិចបាទ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ ដោយសារតែនៅពេលនេះខ្វះ១៥នាទី ហើយបទបង្ហាញទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទ នួន ជា គឺអាចមានរយៈពេលវែង។ ប្រសិនជាលោកប្រធានគិតថាអាចបន្តទៅពេលស្អែក ឬក៏នេះគឺជាការអាស្រ័យទៅលើលោកប្រធាន ដែលត្រូវកំណត់ថាត្រូវបង្ហាញនៅពេលនេះ ឬក៏យ៉ាងណាបាទ?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាហើយ។ អំមិញថាសូមឲ្យលោកបន្តការដាក់បង្ហាញឯកសារគន្លឹះ ពាក់ព័ន្ធជាមួយនឹងអង្គហេតុ តួនាទីរបស់ជនជាប់ចោទ។ ដូច្នេះលោកសូមអនុវត្តទៅតាមនេះ ដើម្បីជំរុញល្បឿននៃការដាក់បង្ហាញឯកសារនេះ។ ប្រសិនបើអាចចប់នៅថ្ងៃស្អែកខាងភាគីចោទប្រកាន់នោះ គឺជាការល្អហើយសម្រាប់ភាគីការពារក្ដី និងក្ដាប់នូវបញ្ហាទាំងអស់នេះបាន នឹងមានឱកាសក្នុងការពិភាក្សាលើបញ្ហានេះជាមួយនឹងកូនក្ដីរបស់គាត់ និងការកំណត់ពេល

វេលាឆ្លើយតបសមស្របនៅក្នុងសប្តាហ៍ក្រោយ។

[១៥:៤៤:០២]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំនឹងបង្ហាញឯកសារនេះ។

ជាបឋមសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។ នៅពេលនេះខ្ញុំនឹងបង្ហាញនូវឯកសារមួយចំនួនទាក់ទងទៅនឹងតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់លោក នួន ជា ដែលជាជនជាប់ចោទនៅទីនេះ។

ជាមួយគ្នានេះដែរ ខ្ញុំក៏សូមអនុញ្ញាតពីលោកប្រធានដើម្បីដាក់បញ្ចាំង -- ប្រហែលដោយសារតែដូចដែលលោកសហព្រះរាជអាជ្ញាអន្តរជាតិបានជម្រាបជូនអ៊ីចឹង។ ដោយសារតែការបង្ហាញរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលឿនពេក។ អ៊ីចឹងការរៀបចំវាមិនទាន់ស្រេចបាច់។ អ៊ីចឹងខ្ញុំប្រហែលជាមិនត្រូវការដាក់បញ្ចាំងទេបាទ។

ឯកសារដំបូងដែលត្រូវយកមកបង្ហាញនៅពេលនោះ គឺទាក់ទងទៅនឹងតួនាទី ភារកិច្ចរបស់លោក នួន ជា នៅក្នុងគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា។ ហើយជាមួយគ្នានេះដែរ ខ្ញុំនិងសហការីរបស់ខ្ញុំបានធ្លាប់បង្ហាញឯកសារដែលជាកំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍ជាច្រើនកន្លងមករួចហើយ នៅក្នុងបទបង្ហាញឯកសារពីលើកមុន។ ហើយនៅពេលនេះ ខ្ញុំនឹងមិនបង្ហាញឯកសារទាំងនោះម្តងទៀតទេ។ ខ្ញុំនឹងយកឯកសារដែលជាកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ផ្សេងពីមុនមកបង្ហាញនៅពេលនេះ។

ឯកសារដំបូងនេះ គឺទាក់ទង -- គឺជាកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ ដែលជាកំណត់ហេតុប្រជុំ--

[១៥:៤៦:១៦]

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិន លោកតំណាងសហព្រះរាជអាជ្ញា។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំប្រហែលជាយល់ខុស ប៉ុន្តែខ្ញុំមិនប្រាកដទេថា ខ្ញុំបានទទួលឯកសារពីខាងព្រះរាជអាជ្ញា គឺឯកសារដែលត្រូវបង្ហាញទាក់ទងទៅនឹងតួនាទីរបស់ នួន ជា ឬក៏អត់នោះ

ខ្ញុំគិតថា យើងមិនទាន់បានទទួលនោះទេ។

**លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្សាឯល៖**

បាទលោកប្រធាន។ បាទ ប្រហែលជាយើងសុំឲ្យផ្ទៀងផ្ទាត់បញ្ជីឯកសារដែលយើងមិនបានផ្តល់ជាមុននេះ ក៏ប៉ុន្តែទន្ទឹមនឹងនេះ វាជាការអនុវត្តដែលយើង ដែលថាយើងធ្វើជាការគួរសមទេ មិនមែនជាកាតព្វកិច្ចទេ ផ្តល់ឯកសារឲ្យគេមុននេះ។ ក៏ប៉ុន្តែទោះយ៉ាងណាក្តី សុំឲ្យតុលាការយោគយល់ដល់យើងសល់ពេលរយៈពេល១០នាទីនេះ យើងមិនទាន់មានបញ្ជីទេ។ អ៊ីចឹងក្រោយពីសវនាការនេះ យើងនឹងបញ្ជូនបញ្ជីនេះ ជូនតុលាការ និងភាគី។ សូមអរគុណលោកប្រធាន។

[១៥:៤៧:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥៤:១៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោកប្រធានបានស្នើសុំឲ្យខ្ញុំបញ្ជាក់ដល់សហព្រះរាជអាជ្ញាថាខ្លួនអាចចាប់ផ្តើមនៅដំណាក់កាលបន្ទាប់នៃការធ្វើបទបង្ហាញនៅពេលព្រឹក។ ហើយអង្គជំនុំជម្រះសូមទទួលស្គាល់ថាការផ្តល់នូវបញ្ជីឯកសារដែលត្រូវបង្ហាញហ្នឹងគឺជាការ -- មិនមែនជាការចាំបាច់ទេ ប៉ុន្តែវាជួយយ៉ាងខ្លាំងទៅដល់អង្គជំនុំជម្រះក៏ដូចជាភាគី។ ដូច្នេះគួរតែផ្តល់នៅពេលនេះ ឬក៏យ៉ាងយូរនៅថ្ងៃស្អែកព្រឹក។ ហើយយើងសូមថ្លែងអំណរគុណបើសិនជាអាចធ្វើបាន។

ហើយលោកប្រធានក៏បានស្នើខ្ញុំផងដែរឲ្យចំណាយពេលវេលានៅសល់ប៉ុន្មាននាទីចុងក្រោយនេះ ដើម្បីសួរទៅខាងព្រះរាជអាជ្ញា ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណី ថាតើតាមការប៉ាន់ស្មានរបស់ខ្លួនថាតើភាគីព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីត្រូវការពេលវេលាប្រហែលជាប៉ុន្មានដែរនៅក្នុងការធ្វើបទបង្ហាញ? ព្រោះថាតាមការដឹងរបស់យើង គឺខាងព្រះរាជអាជ្ញានៅសល់១ថ្ងៃ។ ចំណែកខាងដើមបណ្តឹងរដ្ឋប្បវេណីនៅសល់កន្លះថ្ងៃ។ ដូច្នេះ យើងចង់ឲ្យមានការឆ្លើយតបដើម្បីធ្វើការប៉ាន់ស្មាន ក៏ដូចជាការរៀបចំកាលវិភាគរបស់យើង។

[១៥:៥៥:៣៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកស្រីចៅក្រម។ ចំពោះសហព្រះរាជអាជ្ញាយើងមិនធ្វើ -- មិនសួរលើសពេលវេលាតាមកំណត់នោះទេ ប្រហែលជាតិចជាង១ថ្ងៃទេលោកប្រធាន។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោក លោកស្រី ចៅក្រម។ ខាងដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនបង្ហាញឯកសារពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទទេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ដូច្នេះហើយគឺថាខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺលោកមិនត្រូវការប្រើប្រាស់ពេលកន្លះថ្ងៃដូចដែលបានស្នើសុំនោះទេ តើមែនទេ?

**លោក ពេជ អង្គ៖**

បាទ គឺត្រឹមត្រូវហើយ។

[១៥:៥៦:២៤]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោក។ នៅក្នុងពេលរសៀលនេះគឺថាមេធាវីការពារក្តី នួន ជា បានស្នើសុំពេលវេលាបន្ថែមដើម្បីឱ្យខ្លួនអាចធ្វើការឆ្លើយតបចំពោះការធ្វើបទបង្ហាញឯកសារជាគន្លឹះគឺការធ្វើបទបង្ហាញជាពិសេសដោយខាងព្រះរាជអាជ្ញាគឺថាដំបូងយើងមិនទទួលស្គាល់ទៅលើ ទទួលយល់ព្រមតាមសំណើនោះទេ ដោយសារតែមានការពង្រីកវិសាលភាព។ ប៉ុន្តែយ៉ាងណាក៏ដោយ ឯកសារត្រូវបានពង្រីកក្នុងចំនួនយ៉ាងច្រើន។ ហេតុដូច្នេះហើយវាមាននូវបញ្ហាជាច្រើនដែលមេធាវីការពារក្តីត្រូវការពេលវេលាដើម្បីស្រាវជ្រាវបន្ថែម។ ហេតុដូច្នេះហើយអង្គជំនុំជម្រះសូមបញ្ជាក់ថាចំពោះការឆ្លើយតបទៅនឹងការធ្វើបទបង្ហាញពីឯកសារដោយព្រះរាជអាជ្ញានិងមេធាវីហ្នឹង គឺយើងពន្យារពេល១អាទិត្យគឺយើងចាប់ផ្តើមនៅសប្តាហ៍ក្រោយគឺនៅថ្ងៃទី០៨ ខែកក្កដា។ ដូច្នេះនៅសប្តាហ៍ក្រោយហ្នឹង គឺយើងនឹងធ្វើការស្តាប់សាក្សីគឺសាក្សីនៅក្នុងបញ្ជីបន្ថែមដែលអង្គជំនុំជម្រះបានប្រកាសនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ គឺយើងនឹងរៀបចំសវនាការនៅព្រឹកថ្ងៃចន្ទ។ ដូច្នេះហើយវាតម្រូវឱ្យខាងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញធ្វើការរៀបចំបន្ថែម។

ដូច្នេះយើងមិនទាន់អាចជម្រាបបានទេ ថាតើសាក្សីរូបណាដែលអាចមកចូលរួម ប៉ុន្តែយើងនឹង

ប្រាប់ជាព័ត៌មាននៅថ្ងៃស្អែក ឬក៏យ៉ាងយូរបំផុតថ្ងៃខានស្អែក។ ដូច្នេះ ទៅតាមកាលវិភាគដែលយើងបានរៀបចំគឺយើងធ្វើទៅតាមបែបនេះលើកលែងតែមានបញ្ហាអ្វីជាបញ្ហាសំខាន់។ នៅពេលនោះ គឺអង្គជំនុំជម្រះនឹងធ្វើការសម្រេចទៅលើសំណើក៏ដូចជាសំណើរបស់ខាងមេធាវីការពារក្តី នួន ជា។

សូមអរគុណលោកប្រធាន។ ចាតើខ្ញុំរៀបរាប់ទៅលើអ្វីដែលលោកប្រធានចង់ឲ្យខ្ញុំនិយាយអស់ហើយឬនៅ?

[១៥:៥៨:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ពេញលេញរួចហើយលោកស្រី។

បាទ ឥឡូវនេះ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី២៧ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តការដាក់បង្ហាញឯកសារគន្លឹះរបស់ភាគីនៅចំពោះមុខអង្គជំនុំ។ សូមភាគីក្នុងរឿងក្តី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការ និងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩ នាទី)*